ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្របខណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់ វិស័យជលផលឆ្នាំ ២០១០-២០១៩




## ជលផលសម្រាប់អនាគត







វគ្គ ១

# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# រដ្ឋបាលជលផល

  

# បុព្វកថា

ស្រូវនិងត្រីគឺជាអាហារប្រចាំថ្ងៃយ៉ាងសំខាន់របស់ប្រជាជនកម្ពុជាតាំងពីដើមរៀងមកហើយត្រីមានសារៈសំខាន់ចំពោះប្រជាជនកម្ពុជាមិនអាចពិពណ៌នា និងកាត់ថ្លៃបានឡើយ។ ជាមួយគ្នានេះដែរ ត្រីផ្តល់នូវសារជាតប្រូតេអ៊ីនប្រមាណជាង ៨០% នៃប្រូតេអ៊ីនសាច់ ដែលប្រជាជនកម្ពុជាបរិភោគ។ ឆ្លងកាត់ស្ថានភាពដ៏លំបាកក្នុងរយៈពេល ៣០ ឆ្នាំកន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានខិតខំពុះពារគ្រប់ឧបសគ្គ និងមិនចេះនឿយហត់ក្នុងការជំរុញឱ្យវិស័យជលផលមានការរីកចម្រើន ដើម្បីធានាបាននូវផលត្រីគ្រប់គ្រាន់សម្រាប់ប្រជាជនកម្ពុជាគ្រប់រូបបរិភោគ។ រដ្ឋបាលជលផល ដែលជាសេនាធិការរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានកាតព្វកិច្ចយ៉ាងសំខាន់ក្នុងការអនុវត្តឱ្យសម្រេចបាននូវគោលដៅដ៏ថ្លៃថ្លានេះ។

សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីគោលនយោបាយវិស័យជលផលជាតិ ដែលត្រូវបានចុះហត្ថលេខាដោយសម្តេចនាយករដ្ឋមន្ត្រីនៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៥ ទទួលស្គាល់ថា វិស័យជលផលមានសារៈសំខាន់យ៉ាងខ្លាំងចំពោះជីវភាពរស់នៅរបស់ប្រជាជន និងសេដ្ឋកិច្ចជាតិ។ ការរួមចំណែករបស់វិស័យជលផលចំពោះគោលដៅនៃការការពារបរិស្ថាន ការអភិរក្សជីវចម្រុះ ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម អភិបាលកិច្ចល្អ និងការកាត់បន្ថយភាពក្រីក្រ គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ហើយគោលដៅទាំងនេះនៅតែមានតម្លៃនៅពេលបច្ចុប្បន្ន។ សេចក្តីថ្លែងការណ៍គោលនយោបាយនេះ ក៏បានដាក់ចេញនូវទស្សនវិស័យរបស់រាជរដ្ឋាភិបាលសម្រាប់វិស័យជលផលថាៈ

*"គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានជលផលប្រកបដោយនិរន្តរភាព ដើម្បីរួមចំណែកធានាសន្តិសុខស្បៀង លើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន ការរីកចម្រើននៃសេដ្ឋកិច្ចសង្គម និងការអភិវឌ្ឍប្រទេសជាតិ"*

ផ្តើមចេញពីគោលនយោបាយ និងទស្សនវិស័យនេះ វិស័យជលផលត្រូវបានគ្រប់គ្រងដោយច្បាប់ស្តីពីជលផល ដែលព្រះមហាក្សត្របានឡាយព្រះហត្ថលេខាដាក់ឱ្យប្រើប្រាស់នៅក្នុងឆ្នាំ ២០០៦។ ច្បាប់នេះមានទិសដៅធានាការគ្រប់គ្រងវិស័យ និងធនធានជលផល ការលើកកម្ពស់ការអភិវឌ្ឍវារីវប្បកម្ម ការគ្រប់គ្រងផលិតកម្ម ការកែច្នៃផលនេសាទ និងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាគ្រប់រូប។ លើសពីនេះទៀត ច្បាប់ស្តីពីជលផលត្រូវបានរៀបចំឡើង ដើម្បីជាប្រយោជន៍ដល់ផ្នែកសេដ្ឋកិច្ចសង្គម និងបរិស្ថាន ដែល



រួមទាំងការធានានូវការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព ការអភិរក្សជីវចម្រុះ និងថែរក្សានូវមរតកវប្បធម៌ធម្មជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ កំណែទម្រង់ដែលបានធ្វើឡើងនៅក្រោមច្បាប់ស្តីពីជលផល បានផ្តល់នូវប្រយោជន៍យ៉ាងធំធេងដល់ប្រជាជនកម្ពុជា។

ក្របខណ្ឌផែនការយុទ្ធសាស្ត្រនេះបង្ហាញពីឆន្ទៈ និងបំណងប្រាថ្នារបស់រាជរដ្ឋាភិបាលដែលចង់ឃើញវិស័យជលផល នៅតែបន្តមានការអភិវឌ្ឍនៅក្នុងពេលអនាគត ហើយប្រាថ្នាចង់ឱ្យប្រជាជនកម្ពុជាទទួលបាននូវផលប្រយោជន៍ពីវិស័យជលផលជារៀងរហូត។ ផ្អែកតាមអនុសាសន៍ដ៏ថ្លៃថ្លារបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាពិសេសដើម្បីសម្រេចបានគោលដៅទាំងនេះ យើងត្រូវអនុវត្តឱ្យបានសម្រេចនូវកិច្ចការសំខាន់ៗមួយចំនួនដូចខាងក្រោមៈ

- រៀបចំបង្កើតស្រះជម្រកត្រីសហគមន៍ឱ្យមាននៅគ្រប់ឃុំ និងគ្រប់សហគមន៍ ដើម្បីធ្វើឱ្យផលស្តុកត្រីសម្បូរពាសពេញនៅតាមវាលស្រែនៅទូទាំងប្រទេសកម្ពុជា
- បង្កើនផលិតកម្មវារីវប្បកម្ម ហើយធានាថា យើងអាចជៀសផុតពីហានិភ័យ ដែលបណ្តាលមកពីជំងឺ និងភាពកខ្វក់ស្របតាមច្បាប់ស្តីពីជលផល និងបង្ការបាននូវការរួចចេញនៃប្រភេទត្រីក្រៅស្រុកចូលក្នុងធម្មជាតិ
- កាត់បន្ថយនូវភាពងាយរងគ្រោះ ដែលបណ្តាលមកពីការគំរាមកំហែងកំពុងកើតមានបច្ចុប្បន្ន ក៏ដូចជានៅថ្ងៃអនាគត មកលើធនធានទឹក ដែលជាធនធានសំខាន់សម្រាប់វិស័យជលផល រួមទាំងការប្រែប្រួលអាកាសធាតុផងដែរ។ យើងត្រូវធ្វើការងារនេះតាមរយៈមធ្យោបាយការពាររួមគ្នា និងបន្សាំទៅនឹងការប្រែប្រួលនៃអាកាសធាតុ
- ធ្វើឱ្យប្រសើរឡើងនូវគុណភាព និងសុវត្ថិភាពនៃផលផលិតផលជលផលតាមកម្រិតស្តង់ដារមួយ ដើម្បីជំរុញការនាំចេញទៅកាន់ទីផ្សារពិភពលោកឱ្យបានច្រើន និងទទួលបានផលចំណេញខ្ពស់
- ធានាឱ្យបាននូវការរួមចំណែករបស់វិស័យជលផល ចំពោះអាហារូបត្ថម្ភ ការទ្រទ្រង់ជីវភាពរស់នៅ និងការលូតលាស់ ដែលជាប្រយោជន៍សម្រាប់ប្រជាជនកម្ពុជាគ្រប់រូប ជាពិសេសអ្នកក្រីក្រនៅតំបន់ជនបទ
- ចាត់វិធានការអនុវត្តចាប់ពីពេលនេះតទៅ ដើម្បីធានាឲ្យបាននូវផលប្រយោជន៍ដ៏ធំធេងរបស់វិស័យជលផល នៅតែមានបន្តសម្រាប់កូនចៅយើងពីជំនាន់មួយទៅជំនាន់មួយតរៀងទៅ។

ជារួមក្របខណ្ឌផែនការយុទ្ធសាស្ត្រនេះ បានបង្កើតជារចនាសម្ព័ន្ធមួយ ដែលអាចជួយឱ្យសម្រេចបាននូវអ្វីដែលបានលើកឡើងដូចខាងលើ។ ក្របខណ្ឌផែនការយុទ្ធសាស្ត្រនេះ អាចជួយឱ្យរាជរដ្ឋាភិបាលសម្រេចបាននូវទស្សនវិស័យរបស់ខ្លួនក្នុងពេលអនាគត ដែលប្រជាជនកម្ពុជាគ្រប់រូបនឹងទទួលផលប្រយោជន៍ពីធនធានជលផលដ៏មានតម្លៃនេះ សម្រាប់ជីវភាពរស់នៅរបស់ខ្លួន។ ខ្ញុំសូមលើកទឹកចិត្តដល់អ្នកពាក់ព័ន្ធនៅក្នុងវិស័យជលផលទាំងអស់ សូមចូលរួមចំណែកបំពេញភារកិច្ចយ៉ាងសកម្ម និងខ្លាំងក្លា ដើម្បីអនុវត្តក្របខណ្ឌផែនការយុទ្ធសាស្ត្រនេះឱ្យបានជោគជ័យ។

រាជធានីភ្នំពេញថ្ងៃទី...២១...ខែ...មីនា...ឆ្នាំ ២០១១

រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ចាន់ សារុន







# មាតិកាអត្ថបទ


បុព្វកថា

១. **សេចក្តីផ្តើម** ..... ១

២. **វិស័យជលផលនៅក្នុងប្រទេសកម្ពុជា** ..... ២

៣. **សក្តានុពល និងបញ្ហាប្រឈមនៃវិស័យជលផលនៅកម្ពុជា** ..... ៤

៣.១ ចំណុចខ្លាំង ចំណុចខ្សោយ កាលានុវត្តភាព និងការគំរាមកំហែង ..... ៤

៣.២ បញ្ហាពីខាងក្រៅ ..... ៥

**៤. អភិក្រមជាយុទ្ធសាស្ត្រ** ..... ៧

៤.១ ទំនាក់ទំនងជាមួយនឹងគោលនយោបាយ និងយុទ្ធសាស្ត្រជាតិ ..... ៧

៤.២ ទស្សនវិស័យ ..... ៨

៤.៣ សសរស្តម្ភនៃការអភិវឌ្ឍ ..... ៩

៤.៤ គោលដៅយុទ្ធសាស្ត្រ ..... ៩

៤.៥ គោលការណ៍ និងតម្លៃ ..... ១១

**៥. ការអនុវត្តយុទ្ធសាស្ត្រ** ..... ១៣

៥.១ បញ្ហារួម ..... ១៣

៥.២ នេសាទទឹកសាប និងសមុទ្រ ..... ១៥

៥.៣ វារីវប្បកម្ម ..... ១៦

៥.៤ ការកែច្នៃ និងពាណិជ្ជកម្ម ..... ១៦

៥.៥ ការធ្វើនិយតកម្ម និងសេវាកម្ម ..... ១៧

៥.៦ ផែនការ និងការចាត់អាទិភាព ..... ១៨

**៦. ធនធាន** ..... ២១

៦.១ សមត្ថភាពមន្ត្រី ..... ២១

៦.២ ថវិកា និងមូលនិធិ ..... ២២

៦.៣ យន្តការផ្តល់មូលនិធិ ..... ២៣

ឧបសម្ព័ន្ធ១ : សូចនាករ និងចំណុចដៅសម្រាប់ឆ្នាំ២០១០-២០១៩ ..... ២៦

ឧបសម្ព័ន្ធ២ : សារតារនៃក្របខណ្ឌផែនការយុទ្ធសាស្ត្រ ..... ៣៧

ឧបសម្ព័ន្ធ៣ : លក្ខខណ្ឌយោងសម្រាប់ការអនុវត្តផែនការខណ្ឌរដ្ឋបាលជលផល និងការសម្របសម្រួល ..... ៣៩

ឧបសម្ព័ន្ធ៤ : ការទំនាក់ទំនងរវាងវិស័យជលផលជាមួយនឹងវិស័យផ្សេងទៀតរបស់រាជរដ្ឋាភិបាល និងសង្គម ..... ៤៤

ឧបសម្ព័ន្ធ៥ : យុទ្ធសាស្ត្របន្ថែមសម្រាប់វិស័យជលផលកម្ពុជាសម្រាប់ឆ្នាំ២០១០ ..... ៤៥

ឧបសម្ព័ន្ធ៦ : ថវិកាប៉ាន់ប្រមាណ ..... ៤៩


















# ១

# សេចក្តីផ្តើម

ក្របខណ្ឌផែនការយុទ្ធសាស្ត្រនេះ ដាក់ចេញនូវទស្សនវិស័យរបស់រាជរដ្ឋាភិបាលចំពោះអនាគតនៃវិស័យជលផលនៅក្នុងប្រទេសកម្ពុជា និងពិពណ៌នាអំពីគោលដៅដែលត្រូវសម្រេចឱ្យបានក្នុងការអនុវត្តនូវផែនការនេះ។ គោលបំណងនៃក្របខណ្ឌផែនការយុទ្ធសាស្ត្រនេះ គឺគាំទ្រដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍសហស្សវត្សរបស់ប្រទេសកម្ពុជា និងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ស្របតាមច្បាប់ស្តីពីជលផលដែលជាប្រយោជន៍សម្រាប់ប្រជាជនកម្ពុជាគ្រប់រូប។

ក្របខណ្ឌផែនការយុទ្ធសាស្ត្រនេះ ពិពណ៌នាអំពីបរិបទជាយុទ្ធសាស្ត្រដ៏ទូលំទូលាយ បញ្ហាប្រឈម និងកាលានុវត្តភាពនៅក្នុងវិស័យជលផល ហើយបានដាក់ចេញនូវអាទិភាពជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលសម្រាប់ការអភិវឌ្ឍវិស័យជលផល ព្រមទាំងបានកំណត់នូវចំណុចដៅនានាប្រកបដោយនិរន្តរភាព។ ក្របខណ្ឌផែនការយុទ្ធសាស្ត្រនេះ មានគោលបំណងផ្តល់ការណែនាំដល់អ្នកពាក់ព័ន្ធទាំងអស់ដែលបំពេញការងារនៅក្នុងវិស័យជលផល និងគាំទ្រដល់ការរៀបចំផែនការអភិវឌ្ឍ ជាពិសេសផែនការសកម្មភាពរបស់រដ្ឋបាលជលផល។

ឯកសារនៅក្នុងផ្នែកទី២ ដែលមានចំណងជើងថា "ឯកសារសាវតារអំពីវិស័យជលផល " គឺបានពិពណ៌នាលម្អិត ព្រមទាំងបានវិភាគ និងពន្យល់បញ្ជាក់អំពីហេតុផលនៃដំណើរការរៀបចំក្របខណ្ឌផែនការយុទ្ធសាស្ត្រនេះ។







# ២

# វិស័យជលផលនៅក្នុងប្រទេសកម្ពុជា

តំបន់ដីសើមលិចទឹកសរុបទាំងតាមរដូវកាល និងជាអចិន្ត្រៃយ៍ គឺគ្របដណ្តប់ប្រមាណជាង ៣០% នៃផ្ទៃប្រទេសកម្ពុជា។ ផ្អែកតាមលក្ខណៈសម្បត្តិនេះ ធ្វើឱ្យកម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានវិសាលភាពជលផលទឹកសាបធំបំផុត និងមានជីវចម្រុះសម្បូរបែបនៅក្នុងពិភពលោក ក្នុងនោះមានតែប្រទេសចិន ឥណ្ឌា និងបង់ក្លាដែសប៉ុណ្ណោះ ដែលមានវិសាលភាពវិស័យជលផលទឹកសាបធំជាងប្រទេសកម្ពុជា។

តាំងពីយូរអង្វែងរៀងមក វិស័យជលផលបានរួមចំណែកយ៉ាងសំខាន់ក្នុងការផ្តល់ការងារ ការបង្កើនជីវភាពរស់នៅរបស់ប្រជាជនក្រីក្រ ផ្តល់នូវសន្តិសុខស្បៀង និងរួមចំណែកដល់កំណើននៃផលិតផលក្នុងស្រុកសរុប ហើយធ្វើឱ្យមានលំនឹងដោយការដោះដូររូបិយប័ណ្ណបរទេស។ វិស័យជលផលផ្តល់នូវការងារដល់ប្រជាជនកម្ពុជាប្រមាណ ៦ លាននាក់ រួមទាំងអ្នកដែលធ្វើនេសាទពេញម៉ោង មិនពេញម៉ោង និងតាមរដូវកាល។ វិស័យជលផលបានរួមចំណែកយ៉ាងសំខាន់ដល់សន្តិសុខស្បៀង ផ្តល់នូវសារជាតិប្រូតេអ៊ីនប្រមាណជាង ៨០% នៃប្រូតេអ៊ីនសាច់នៅក្នុងរបបអាហារដែលបានប៉ាន់ស្មាននូវកម្រិតថ្នាក់ជាតិ ហើយជាប្រភពដ៏សំខាន់នៃជីវជាតិ និងអាហារូបត្ថម្ភចាំបាច់សម្រាប់ទ្រទ្រង់ជីវិត និងសុខភាពរបស់ប្រជាជនកម្ពុជាគ្រប់រូប។

លើសពីនេះទៀត ផលិតផលជលផលត្រូវបានប៉ាន់ស្មានថា មានតម្លៃប្រមាណពី ២០០-៣០០ លានដុល្លារ សហរដ្ឋអាមេរិកក្នុងមួយឆ្នាំៗ ដោយគិតតាមតម្លៃនៅទីកន្លែងផៃឡើងត្រី។ ផ្អែកតាមតួលេខនេះបញ្ជាក់ថា វិស័យជលផលបានរួមចំណែកប្រមាណពី ៨-១២% នៃផលិតផលក្នុងស្រុកសរុប។ ដោយឡែកចំពោះផលិតផលជលផលនាំចេញ ត្រូវបានប៉ាន់ស្មានថា មានតម្លៃលើសពី ១០០ លានដុល្លារ សហរដ្ឋអាមេរិកក្នុងមួយឆ្នាំៗ។

ត្រីក៏ជាផ្នែកមួយនៃមរតកវប្បធម៌របស់ប្រទេសកម្ពុជាផងដែរ។ ទំនាក់ទំនងរវាងវិស័យជលផល និងទិដ្ឋភាពនានានៃប្រវត្តិសាស្ត្រនៅក្នុងតំបន់ដែលបានចារិកទុកដោយបុរាណវិទូខ្មែរនៅលើផ្ទាំងសិលាចារិកនៃប្រាង្គប្រាសាទនានានៅក្នុងប្រទេសកម្ពុជាដែលរៀបរាប់អំពីសកម្មភាពកៃច្នៃ និងការជួញដូរផលនេសាទនៅទូទាំងតំបន់បានបង្ហាញអំពីសារៈសំខាន់របស់វិស័យជលផលនៅក្នុងប្រទេសក៏ដូចជានៅទូទាំងតំបន់អាស៊ីអាគ្នេយ៍ទាំងមូល។ ដូចនេះវិស័យជលផល និងជីវចម្រុះដ៏សម្បូរបែបនៅក្នុងប្រទេសកម្ពុជាគឺជាផ្នែកមួយយ៉ាងសំខាន់បំផុតនៃមរតកធម្មជាតិរបស់ជាតិ និងពិភពលោក។

**ផែនទីប្រព័ន្ធអេកូឡូស៊ីតំបន់ដីសើម និងដែននេសាទ**










ទោះបីជាយ៉ាងដូច្នេះក្ដី វិស័យជលផលបាន និងកំពុងជួបប្រទះនឹងបញ្ហាប្រឈមនានាជាច្រើនដូចជា ការធ្វើនេសាទហួសកម្រិត កត្តាខាងក្នុងវិស័យ និងការជះឥទ្ធិពលមកពីកត្តាខាងក្រៅ រួមមានការគំរាមកំហែងពីថ្នាក់តំបន់ និងសកលលោក។ ការគំរាមកំហែងទាំងនោះមានការប្រែប្រួលប្រព័ន្ធអេកូឡូស៊ី ការសាងសង់ទំនប់វារីអគ្គិសនី និងការប្រែប្រួលអាកាសធាតុ។ តាមការស្រាវជ្រាវបញ្ជាក់ថាកម្រិតនៃទឹកជំនន់គឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងផលនេសាទ នេះមានន័យថាបើកម្រិតទឹកជំនន់កាន់តែធំ នោះផលនេសាទកាន់តែច្រើន ហើយផ្ទុយមកវិញបើកម្រិតទឹកជំនន់តូច កម្រិតផលនេសាទក៏មានចំនួនតិចដែរ។ ក្រៅពីនេះក៏មានកត្តាផ្សេងទៀតដែលមានទំនាក់ទំនងជាមួយនឹងផលនេសាទដូចជាវិសាលភាព និងពេលវេលានៃទឹកជំនន់ដែលមានឥទ្ធិពលដល់លទ្ធភាពនៃប្រព័ន្ធអេកូឡូស៊ីក្នុងការផ្ដល់នូវទីជម្រក និងចំណីអាហារដល់មច្ឆជាតិ។

## ស្ថិតិផលនេសាទ និងព្រៃលិចទឹក

| | ២000 | ២00២ | ២00៤ | ២00៦ | ២00៨ |
|---|---|---|---|---|---|
| **ការនេសាទ** | | | | | |
| - ទឹកសាប (តោន) | ២៤៥.៦00 | ៣៦0.៣00 | ២៥0.000 | ៤២២.000 | ៣៦៥.000 |
| - សមុទ្រ (តោន) | ៣៦.000 | ៤៥.៨៥0 | ៥៥.៨00 | ៦0.៥00 | ៦៦.000 |
| **វារីវប្បកម្ម** | | | | | |
| - ទឹកសាប (តោន) | ១៤.៤១0 | ១៤.៥៤៧ | ១៨.៥៨៥ | ៣៤.១៦0 | ៣៩.0២៥ |
| - សមុទ្រ (តោន) | ២0 | ៥៣ | ៧៥ | ៤0 | ៧៥ |
| **ការនាំចេញ (តោន)** | ៤៣.៦00 | ៥២.៥00 | ៤៥.៨៥0 | ៣0.000 | ២៥.000 |
| **ព្រៃលិចទឹក** | តួលេខផ្លូវការរបស់រដ្ឋបាលជលផលឆ្នាំ ២00៥ សរុបចំនួន ៩៩៩,៩១១ ហ.ត ៖<br>- ព្រៃកោងកាង ៦៧.៧៧0 ហ.ត<br>- ព្រៃលិចទឹកទឹកសាប ៩៣២.១៤១ ហ.ត | | | | |
| **ចំនួនកូនត្រី (ក្បាល)** | ៧.៥0៨.000 | ១៣.៤២0.000 | ១៥.៧៩៣.000 | ២១.៣៣៥.000 | ៣៧.១៩៣.000 |

អនាគតនៃវិស័យជលផលនៅក្នុងប្រទេសកម្ពុជានឹងត្រូវកំណត់ឡើង ដោយផ្អែកលើតម្រូវការដែលកំពុងតែកើនឡើងដោយសារកំណើនរបស់ប្រជាជន។ ប្រជាជនកម្ពុជាគិតត្រឹមឆ្នាំ ២០១០ គឺមានចំនួនប្រមាណ ១៤ លាន នាក់ និងអត្រាកំណើនត្រូវបានគេប៉ាន់ស្មានថាមានប្រមាណ ១,៥៤% ក្នុងមួយឆ្នាំ[១]។ ផ្អែកតាមកំណើននេះ យើងត្រូវគិតគូរដល់ការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភសម្រាប់ប្រជាជនកម្ពុជា ក៏ដូចជាការទ្រទ្រង់ដល់កិច្ចអភិវឌ្ឍសេដ្ឋកិច្ច ពីព្រោះតម្រូវការត្រីនឹងបន្តកើនឡើងជាលំដាប់។ ដូច្នេះ វិស័យជលផលនឹងជួបប្រទះនូវបញ្ហាប្រឈមក្នុងការផ្គត់ផ្គង់ផលនេសាទដើម្បីបំពេញនូវតម្រូវការកើនឡើងនេះ ហើយក៏ត្រូវគិតគូរអំពីនិរន្តរភាពនៃវិស័យជលផលសម្រាប់មនុស្សជំនាន់ក្រោយៗទៀតផង។

*១. លទ្ធផលជំរឿនឆ្នាំ ២០០៨, ចំនួនប្រជាជនមានសរុប ១៣.៣៨៨.៩១០ : វិទ្យាស្ថានស្ថិតិជាតិ ខែសីហា ឆ្នាំ ២០០៨*







# ៣

# សក្តានុពល និងបញ្ហាប្រឈមនៃវិស័យជលផលនៅកម្ពុជា

## ៣.១ *ចំណុចខ្លាំង ចំណុចខ្សោយ កាលានុវត្តភាព និងការគំរាមកំហែង*

### ការវិភាគចំណុចខ្លាំង ចំណុចខ្សោយ កាលានុវត្តភាព និងការគំរាមកំហែង

**ចំណុចខ្លាំង**

- មានបច្ចេកទេស និងបច្ចេកវិទ្យានៃការនេសាទ និង ចំណេះដឹងអំពីបរិស្ថាន
- ការគ្រប់គ្រងធនធានជលផលមានភាពប្រសើរឡើងតាមរយៈ ការធ្វើផែនទីកំណត់ព្រំប្រទល់ និងការអភិរក្សទីជម្រកសំខាន់ៗ
- ការគ្រប់គ្រងធនធានជលផលដោយមានការចូលរួមពីសហគមន៍ទទួលបានជោគជ័យ ប្រជាពលរដ្ឋមានឆន្ទៈក្នុងការការពារ និងអភិរក្សធនធានជលផល
- មានបទពិសោធន៍ចិញ្ចឹមត្រីគ្រប់ទ្រង់ទ្រាយ និងនៅគ្រប់កម្រិត
- មានជំនាញក្នុងការកែច្នៃត្រីជាលក្ខណៈប្រពៃណីយ៉ាងល្អប្រសើរ ដោយត្រូវការថាមពលតិចតួច
- មានប្រវត្តិដ៏យូរអង្វែងក្នុងការធ្វើពាណិជ្ជកម្ម និងមានតម្រូវការខ្ពស់ ទាំងក្នុងស្រុក និងអន្តរជាតិចំពោះផលនេសាទ
- ការយល់ដឹង និងការគាំទ្រពីអ្នកពាក់ព័ន្ធមានការកើនឡើង
- មានការកើនឡើងនូវចំណេះដឹងជាមូលដ្ឋានអំពីប្រភេទ និងទីជម្រកសំខាន់ៗ
- មានច្បាប់ លិខិតបទដ្ឋាន និងរចនាសម្ព័ន្ធគ្រប់គ្រង។

**ចំណុចខ្សោយ**

- ការយល់ដឹងរបស់ប្រជាពលរដ្ឋមួយចំនួនអំពីសារៈសំខាន់នៃវិស័យជលផលនៅមានកម្រិត
- ការផ្គត់ផ្គង់ផលនេសាទមានការប្រែប្រួលតាមរដូវកាល និងតាមឆ្នាំ និងមានការនេសាទហួសកម្រិតលើប្រភេទត្រីមួយចំនួន
- អភិបាលកិច្ច និងការអនុវត្តច្បាប់នៅមានកម្រិត
- ខ្វះជំនាញ ឯកសារណែនាំ និងស្តង់ដារ
- ខ្វះមូលនិធិរួមទាំងការធ្វើវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធ
- ខ្វះធនធាន និងចំណេះដឹងក្នុងការគាំទ្រផ្នែកវារីវប្បកម្ម
- ខ្វះសម្ភារៈត្រួតពិនិត្យគុណភាព និងការគ្រប់គ្រងវិធីបង្កាជំងឺ
- ខ្វះការស្រាវជ្រាវ និងទិន្នន័យប្រកបដោយគុណភាពលើផ្នែកមួយចំនួន

**កាលានុវត្តភាព**

- មានធនធានសម្បូរហូរហៀរ សម្បូរជីវចម្រុះ មានធនធានដែលអាចកកើតឡើងវិញ
- ជាវិស័យមួយដែលជាទីពឹងអាស្រ័យយ៉ាងខ្លាំងចំពោះប្រជាជននៅក្នុងតំបន់ជនបទ
- ការកើនឡើងនៃការនាំចេញ តាមរយៈការលើកកម្ពស់យុទ្ធសាស្ត្រទីផ្សារ គុណភាពផលិតផល និងការបង្កើននូវតម្លៃបន្ថែម
- មានការលើកទឹកចិត្តចំពោះការនាំចេញ តាមរយៈការកាត់បន្ថយថ្លៃដើម និងបន្ថយបន្ទុកពន្ធដារ
- មានការអភិវឌ្ឍការនេសាទសមុទ្រ
- មានការលូតលាស់នៃវារីវប្បកម្ម និងការនេសាទតាមវាលស្រែ
- មានការធ្វើឱ្យប្រសើរឡើងនូវការកែច្នៃត្រីដែលមានតម្លៃ និងជីវជាតិខ្ពស់ដើម្បីបង្កើនសន្តិសុខស្បៀង
- ការគ្រប់គ្រងធនធានជលផល ត្រូវបានធ្វើឱ្យប្រសើរឡើងតាមរយៈការលើកទឹកចិត្តឱ្យមានការចូលរួមធ្វើការសម្រេចចិត្តពីប្រជាជនដែលពឹងផ្អែកលើវិស័យនេះ។

**កត្តាគំរាមកំហែង**

- *បាត់បង់ទីជម្រកកន្លែងពងកូន និងការថយចុះនៃមេពូជធម្មជាតិដោយសារ*
  - ការប្រែប្រួលអាកាសធាតុ នាំឱ្យមានការប្រែប្រួលកម្រិតកម្ពស់ទឹក អត្រាលំហូរ និងកម្រិតទឹកជំនន់
  - ការបំផ្លាញបរិស្ថាន បណ្តាលមកពីការពុល និងការកើនឡើងនៃកំណកកករ ដោយសារការរុករករ៉ែដោយខុសច្បាប់
  - ការសាងសង់ទំនប់ ការរានយកដី និងការកាប់បំផ្លាញព្រៃឈើដោយខុសច្បាប់
  - ការកើនឡើងនូវសម្ពាធទៅលើធនធាន ដោយសារកត្តាសេដ្ឋកិច្ច និងកំណើនប្រជាជន
  - ការកើនឡើងនូវការប្រកួតប្រជែងពាណិជ្ជកម្មអន្តរជាតិ
  - ការត្រួតពិនិត្យនេសាទខុសច្បាប់នៅមានកម្រិត និងការបំផ្លិចបំផ្លាញនៅតែមាន ដែលជាហេតុនាំឱ្យកើតមានទំនាស់
  - កើតមានជំងឺ ជាពិសេសក្នុងផ្នែកវារីវប្បកម្ម
  - បាត់បង់ដែននេសាទ ដោយសារការគ្រប់គ្រងដីធ្លីមានភាពទន់ខ្សោយ។







ចំណុចខ្លាំងរបស់វិស័យជលផល គឺធនធានធម្មជាតិសម្បូរ និងមានប្រវត្តិសាស្ត្រយូរអង្វែង ទោះបីជាការគ្រប់គ្រងវិស័យនេះនៅមានចំណុចខ្វះខាតខ្លះៗក៏ដោយ។ចំណុចខ្សោយដ៏ចម្បងមួយគឺដោយសារលក្ខណៈធម្មជាតិរបស់ធនធានជលផលជាធនធានបើកចំហ ដែលអ្នកក្រីក្រជានិច្ចកាលតែងតែពឹងអាស្រ័យលើ ប៉ុន្តែដោយសារធនធានជលផលមានភាពកំណត់ និងមានការប្រែប្រួល ដូច្នេះការពឹងអាស្រ័យរបស់ប្រជាជនសម្រាប់ជីវភាពរស់នៅរបស់ខ្លួនមកលើធនធានជលផលមិនអាចធានាបានទាំងស្រុងនោះឡើយ។ នៅពេលដែលតម្រូវការកាន់តែកើនឡើង សម្ពាធទៅលើធនធានជលផលក៏កាន់តែកើនឡើងផងដែរ។

ទោះបីជាមានភាពទន់ខ្សោយយ៉ាងនេះក្តី កាលានុវត្តភាពនៅក្នុងវិស័យជលផលមានភាពធំធេង និងច្បាស់លាស់។ យើងអាចសម្រេចបាននូវការលូតលាស់ ដោយគិតទាំងផលិតផល និងការរកប្រាក់ចំណូល។ ទោះបីជាយ៉ាងដូចនេះក្តី ដើម្បីសម្រេចបាននូវការអភិវឌ្ឍធនធានជលផលដ៏សំខាន់នេះ ចាំបាច់ត្រូវតែធានា និងថែរក្សាឱ្យបានគង់វង្ស។

វិស័យជលផលមានសក្តានុពលធំធេងក្នុងការផ្តល់នូវផលប្រយោជន៍សម្រាប់សេដ្ឋកិច្ច និងការចិញ្ចឹមជីវិតរបស់ប្រជាជន ប៉ុន្តែសក្តានុពលនេះគឺស្ថិតនៅក្រោមការគំរាមកំហែងជាបន្តបន្ទាប់ពីបញ្ហាប្រឈមទាំងខាងក្នុង និងខាងក្រៅវិស័យ។ បញ្ហាប្រឈមមួយចំនួនកើតឡើងនៅក្នុងស្រុក និងមួយចំនួនទៀតកើតឡើងនៅក្នុងតំបន់ ឬជាសកល ជាពិសេសការគំរាមកំហែងដល់ធនធានទឹក ធារទឹក បរិមាណទឹកសម្រាប់ការលូតលាស់របស់មច្ឆជាតិ ដោយសារការប្រែប្រួលបរិស្ថាន ការសាងសង់ទំនប់ និងសកម្មភាពនានារបស់មនុស្ស។ ទោះបីជាយ៉ាងដូច្នេះក្តី ទន្ទឹមនឹងបញ្ហាប្រឈមដែលត្រូវគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយនោះ វិស័យជលផលក៏មានកាលានុវត្តភាពក្នុងការថែរក្សា និងពង្រីកការរួមចំណែករបស់ខ្លួនឱ្យបានកាន់តែទូលំទូលាយថែមទៀតផងដែរ។

## ៣.២ បញ្ហាពីខាងក្រៅ

បញ្ហាដែលជាមូលហេតុ ឬមានឥទ្ធិពលមកលើវិស័យជលផលចែកចេញជាពីរប្រភេទរួមមានៈ បញ្ហាដែលកើតមាននៅក្នុងប្រទេសកម្ពុជា និងបញ្ហាដែលកើតមានឡើងក្នុងតំបន់ ឬជាសកល។

***បញ្ហានៅក្នុងប្រទេសកម្ពុជាៈ*** បញ្ហាដែលកើតចេញពីផ្ទៃក្នុងនៃព្រះរាជាណាចក្រកម្ពុជាចាំបាច់ត្រូវៈ

១ ធានានូវសុវត្ថិភាពដែននេសាទសម្រាប់ការការពារ និងការអភិវឌ្ឍវិស័យជលផល។

២ ការពារប្រព័ន្ធអេកូឡូស៊ីតំបន់ដីសើមពីផលប៉ះពាល់នៃការបំផ្លិចបំផ្លាញព្រៃលិចទឹក ការរានដីធ្លី និងការបំពុលបរិស្ថានជលផល។







៣ ធានាថា ផលប៉ះពាល់មកលើវិស័យជលផលដែលបណ្តាលមកពីការសាងសង់ទំនប់វារីអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានកំណត់ច្បាស់លាស់។

៤ ជំរុញការនាំចេញឱ្យមានល្បឿនលូតលាស់កើនឡើង។

៥ កាត់បន្ថយសម្ពាធទៅលើធនធានជលផល តាមរយៈការធ្វើពិពិធកម្មនៃជម្រើសមុខរបរចិញ្ចឹមជីវិត[២]។

ការអនុវត្តនូវក្របខណ្ឌផែនការយុទ្ធសាស្ត្រនេះ នឹងជួយគាំទ្រដល់រដ្ឋបាលជលផលក្នុងការទទួលយកនូវតួនាទីជាច្រើនថែមទៀត ពាក់ព័ន្ធនឹងការរៀបចំ និងការអនុវត្តគោលនយោបាយសម្របសម្រួលជាមួយនឹងក្រសួង នាយកដ្ឋាន ភ្នាក់ងារ និងស្ថាប័ននានាដែលមានសកម្មភាពពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានទឹក។ កិច្ចសម្របសម្រួលនេះ ក៏ទាមទារឱ្យមានការអនុវត្តជាមួយនឹងបណ្តាដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលដែលកំពុងបំពេញការងារពាក់ព័ន្ធនឹងវិស័យជលផល ដើម្បីធានាថា សកម្មភាព និងកិច្ចអន្តរាគមន៍របស់ពួកគេ គឺស្របជាមួយនឹងគោលដៅ និងតម្រូវការរួមនៃការអភិវឌ្ឍ។

***បញ្ហាមកពីខាងក្រៅប្រទេសកម្ពុជា:*** បញ្ហាទាំងនេះ គឺជាបញ្ហាឆ្លងដែន និងបញ្ហានៅក្នុងតំបន់ដែលចាំបាច់ត្រូវ:

១ ចាត់វិធានការដើម្បីកាត់បន្ថយផលប៉ះពាល់ទៅលើវិស័យជលផលដែលបណ្តាលមកពីការសាងសង់ទំនប់វារីអគ្គិសនីនៅទន្លេមេគង្គប៉ែកខាងលើ។

២ ដោះស្រាយបញ្ហាដែលបណ្តាលមកពីបម្រែបម្រួលអាកាសធាតុ។

៣ ធានាឱ្យមានវិធានការកាត់បន្ថយភាពងាយរងគ្រោះដែលបណ្តាលមកពីការគំរាមកំហែងនៃកត្តាខាងក្រៅមកលើវិស័យជលផល និងប្រជាពលរដ្ឋដែលពឹងផ្អែកលើវិស័យនេះ។

បញ្ហាទាំងនេះតម្រូវឱ្យមានសកម្មភាពរួមគ្នាក្នុងក្របខណ្ឌអន្តរជាតិ។ ក្នុងករណីការសាងសង់ទំនប់វារីអគ្គិសនីគឺត្រូវមានការរួមបញ្ចូលទាំងប្រទេសដែលជាសមាជិក និងប្រទេសដែលស្ថិតនៅក្រៅក្របខណ្ឌនៃគណៈកម្មការទន្លេមេគង្គ។ ការអនុវត្តក្របខណ្ឌផែនការយុទ្ធសាស្ត្រនេះ គឺធ្វើឱ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការជាមួយនឹងស្ថាប័នក្នុងតំបន់ដូចជាគណៈកម្មការទន្លេមេគង្គជាដើម ក៏ដូចជាពង្រឹងការយល់ដឹងឱ្យកាន់តែល្អប្រសើរឡើងអំពីទិន្នន័យ និងព័ត៌មានតាមរយៈស្ថាប័នទាំងនេះ។

ចំពោះករណីការប្រែប្រួលអាកាសធាតុ កិច្ចការដែលត្រូវអនុវត្តគឺធ្វើឡើងតាមរយៈស្ថាប័នក្នុងតំបន់ និងអង្គការអន្តរជាតិ និងវេទិកានានា រួមមានអង្គការសហប្រជាជាតិផង។ ទោះបីយ៉ាងដូច្នេះក្តី រាជរដ្ឋាភិបាលចាំបាច់ត្រូវរៀបចំគោលនយោបាយសម្របសម្រួលជាតិដើម្បីដោះស្រាយនូវបញ្ហាទាំងនេះប្រកបដោយប្រសិទ្ធភាព។ ការសិក្សាស្រាវជ្រាវអំពីការប្រែប្រួលអាកាសធាតុត្រូវបានធ្វើឡើង និងគូសបញ្ជាក់នៅក្នុងវិស័យនានាជាហូរហែខ្លះៗមកហើយ ដូច្នេះរដ្ឋបាលជលផលនឹងទទួលខុសត្រូវក្នុងការធានាថា ឥទ្ធិពលមកលើវិស័យជលផលត្រូវបានយកទៅពិចារណាផងដែរ។

២. *រួមបញ្ចូលទាំងកម្មវិធីភូមិមួយផលិតផលជលផលមួយដែលគ្រប់គ្រងដោយគណៈកម្មការជាតិភូមិមួយផលិតផលមួយ*







# ៤

# អភិក្រមជាយុទ្ធសាស្ត្រ

## ៤.១ ទំនាក់ទំនងជាមួយនឹងគោលនយោបាយ និងយុទ្ធសាស្ត្រជាតិ

### គោលដៅអភិវឌ្ឍន៍សហស្សវត្សរបស់កម្ពុជា

**តួនាទីរបស់វិស័យជលផលក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរបស់កម្ពុជា គឺមានសារៈសំខាន់យ៉ាងខ្លាំង។ តួនាទីនេះមានចែងដូចខាងក្រោម:**

១ តួនាទីរបស់វិស័យជលផលក្នុងការផ្គត់ផ្គង់ម្ហូបអាហារ និងផ្តល់នូវការងារគឺ រួមចំណែកសម្រេចឱ្យបាននូវគោលដៅទី១ **គឺការលុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លានធ្ងន់ធ្ងរ**

២ តួនាទីរបស់ស្ត្រីនៅក្នុងវិស័យជលផល គឺរួមចំណែកសម្រេចឱ្យបាននូវគោលដៅទី៣ គឺ**ការលើកតម្កើង**សមធម៌យេនឌ័រនិងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី។

៣ ការធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភនៅក្នុងចំណីអាហារដែលបានពីការប្រើប្រាស់ត្រី និងផលិតផលជលផល គឺរួមចំណែកសម្រេចឱ្យបាននូវគោលដៅទី៤ គឺកាត់បន្ថយមរណភាពរបស់កុមារ និងគោលដៅទី៥ គឺលើកកម្ពស់សុខមាលភាពមាតា។

៤ ចំណុចចុងក្រោយ ការគ្រប់គ្រងដ៏ល្អនៃតំបន់ដីសើម គឺរួមចំណែកសម្រេចឱ្យបាននូវគោលដៅទី៧ គឺធានាចីរភាពបរិស្ថាន ការអនុវត្តន៍កន្លងមកគឺបានបង្ហាញពីវឌ្ឍនភាពបានយ៉ាងល្អប្រសើរធៀបនឹងគោលដៅដែលបានកំណត់ប៉ុន្តែនៅមានគោលដៅជាចំរើនទៀតដែលនឹងត្រូវសម្រេចឱ្យបានក្នុងពេលអនាគតហើយគោលដៅទាំងនេះដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំទ្រង់ទ្រាយនៃក្របខណ្ឌផែនការយុទ្ធសាស្ត្រនេះ។

### ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

សារៈសំខាន់នៃវិស័យជលផល  គឺត្រូវបានទទួលស្គាល់ផងដែរនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដោយបានកត់សំគាល់ថា " ត្រីមានតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់នូវស្បៀងអាហារូបត្ថម្ភ និងប្រាក់ចំណូលដល់ប្រជាជនកម្ពុជារាប់លាននាក់ " ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិសម្រាប់ឆ្នាំ ២០០៩ - ២០១៣ បានកំណត់នូវចំណុចដៅសម្រាប់វិស័យជលផលដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងក្របខណ្ឌផែនការយុទ្ធសាស្ត្រនេះ។







## វិមជ្ឈការ និងវិសហមជ្ឈការ

វិស័យជលផលក៏បានរួមចំណែកយ៉ាងសំខាន់ក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលផងដែរ។ ដំណើរការនៃការផ្ទេរសិទ្ធិទទួលខុសត្រូវក្នុងការគ្រប់គ្រងវិស័យជលផលដល់ថ្នាក់ខេត្ត ឃុំ និងសហគមន៍ ត្រូវបានចាប់ផ្តើមអនុវត្តជាបណ្តើរៗមកហើយ ហេតុនេះការអនុវត្តក្របខណ្ឌផែនការយុទ្ធសាស្ត្រវិស័យជលផល នឹងជួយគាំទ្រដល់រដ្ឋបាលជលផលដើម្បីបន្តដំណើរការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងវិស័យជលផលឱ្យបានកាន់តែលឿនទៅមុខថែមទៀត ក្នុងនោះកិច្ចការសំខាន់ គឺការកសាងសមត្ថភាពមន្ត្រីនៅថ្នាក់ខណ្ឌរដ្ឋបាលជលផល ដើម្បីជំរុញឱ្យមានការទទួលខុសត្រូវនៅថ្នាក់ខណ្ឌរដ្ឋបាលជលផល កើនឡើងជាបន្តបន្ទាប់។

វិស័យជលផលនៅកម្ពុជាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងវិស័យនានាជាច្រើនផ្សេងទៀតរបស់រាជរដ្ឋាភិបាល និងសង្គម ហើយតួនាទីភារកិច្ចរបស់រដ្ឋបាលជលផលក្នុងការសម្របសម្រួលជាមួយនឹងវិស័យទាំងនោះ ចាំបាច់ត្រូវតែពង្រីកឱ្យបានទូលំទូលាយថែមទៀតតាមរយៈការអនុវត្តក្របខណ្ឌផែនការយុទ្ធសាស្ត្រវិស័យជលផលនេះ។ កិច្ចការលម្អិតអំពីទំនាក់ទំនងរបស់វិស័យជលផលជាមួយនឹងវិស័យនានាមានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ៤។

## ៤.២ | ទស្សនវិស័យ

ទស្សនវិស័យរបស់រាជរដ្ឋាភិបាលសម្រាប់អនាគតវិស័យជលផលគឺ:

*គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានជលផលប្រកបដោយនិរន្តរភាព ដើម្បីរួមចំណែកធានាសន្តិសុខស្បៀង លើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន ការរីកចម្រើននៃសេដ្ឋកិច្ចសង្គម និងការអភិវឌ្ឍប្រទេសជាតិ។*

ទស្សនវិស័យនេះ គឺជាមូលដ្ឋានគ្រឹះក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល សំដៅសម្រេចបាននូវចំណុចដៅនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរបស់កម្ពុជា។ ការសម្របសម្រួល ការធ្វើសុខដុមនីយកម្ម និងការគ្រប់គ្រងកិច្ចអភិវឌ្ឍន៍វិស័យជលផលក្នុងការឆ្លើយតបនឹងទស្សនវិស័យនេះ គឺជាតួនាទី និងការទទួលខុសត្រូវដ៏ចម្បងរបស់រដ្ឋបាលជលផល។

ហេតុនេះរដ្ឋបាលជលផល គឺជាភ្នាក់ងារនាំមុខរបស់រាជរដ្ឋាភិបាលក្នុងការទទួលខុសត្រូវលើការគ្រប់គ្រង និងអភិវឌ្ឍវិស័យជលផលនៅកម្ពុជា។ រដ្ឋបាលជលផលទទួលខុសត្រូវក្នុងការធានានូវការបែងចែកផលប្រយោជន៍ដែលបានមកពីវិស័យជលផលប្រកបដោយសមធម៌ និងទទួលខុសត្រូវចំពោះការប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាពសម្រាប់បច្ចុប្បន្ន និងទៅអនាគត។ អាណត្តិរបស់រដ្ឋបាលជលផល គឺការអនុវត្តទស្សនវិស័យនេះ ហើយក្របខណ្ឌផែនការយុទ្ធសាស្ត្រគឺជាជំហានយ៉ាងសំខាន់នៅក្នុងដំណើរការនេះ។








## ៤.៣ សសរស្តម្ភនៃការអភិវឌ្ឍ

យុទ្ធសាស្ត្រអភិវឌ្ឍរបស់រាជរដ្ឋាភិបាលចំពោះវិស័យជលផល គឺផ្អែកលើសសរស្តម្ភ ៣ ដែលជាមូលដ្ឋានសំខាន់ ដូចមានចែងខាងក្រោមៈ

១ ជលផលទឹកសាប និងសមុទ្រ។

២ វារីវប្បកម្មទឹកសាប និងសមុទ្រ។

៣ ការកែច្នៃ និងពាណិជ្ជកម្ម។

ដើម្បីគាំទ្រដល់សសរស្តម្ភទាំងនេះ គឺតម្រូវឱ្យមានគោលការណ៍នៃការធ្វើនិយ័តកម្មដ៏សមស្រប និងអាចអនុវត្តបានដោយរួមទាំងក្របខណ្ឌច្បាប់ និងការផ្តល់នូវសេវាកម្មប្រកបដោយប្រសិទ្ធភាព។

សសរស្តម្ភនៃការអភិវឌ្ឍវិស័យជលផលខាងលើនេះ គឺគាំទ្រដល់ប្រជាជននៅក្នុងវិស័យជលផល ការធានាសន្តិសុខស្បៀងការកាត់បន្ថយភាពក្រីក្រ និងការលូតលាស់នៃសេដ្ឋកិច្ច។ សកម្មភាពដោយផ្ទាល់នឹងត្រូវអនុវត្តផ្អែកលើសសរស្តម្ភទាំង ៣ ខាងលើក្រោមក្របខណ្ឌផែនការយុទ្ធសាស្ត្ររបស់វិស័យជលផល ក៏ដូចជាសកម្មភាពពាក់ព័ន្ធទៅនឹងការរៀបចំក្របខណ្ឌច្បាប់ និងការផ្តល់នូវសេវាកម្មនានា។

ផលនេសាទទឹកសាបមានបរិមាណលើសលប់នៅក្នុងបរិមាណផលនេសាទសរុបបច្ចុប្បន្ន។ ដូចនេះយើងត្រូវថែរក្សា និងធ្វើឱ្យប្រសើរឡើងនូវធនធានជលផលទាំងនេះឱ្យអស់លទ្ធភាព។ ប៉ុន្តែ ដោយសារសមត្ថភាពកកើតឡើងវិញរបស់ធនធានធម្មជាតិមានកម្រិត ជាហេតុធ្វើឱ្យផលនេសាទបានពីធម្មជាតិមិនអាចធានាបាននូវនិរន្តរភាពក្នុងការផ្គត់ផ្គង់តាមតម្រូវការរបស់ប្រជាជនដែលមានចំនួនកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ ឱ្យបានគ្រប់គ្រាន់ឡើយ។ ដូច្នេះការអភិវឌ្ឍវារីវប្បកម្ម គឺជាកិច្ចការយ៉ាងសំខាន់ដែលត្រូវធ្វើឡើង ជាមួយគ្នានេះយើងត្រូវបង្កើននូវគុណភាព និងស្តង់ដាររបស់ផលិតផលជលផលសម្រាប់ការបរិភោគ និងការធ្វើពាណិជ្ជកម្ម សំដៅលើកកម្ពស់ជីវភាពរស់នៅ និងការនាំចេញ។

## ៤.៤ គោលដៅយុទ្ធសាស្ត្រ

ដើម្បីអនុវត្តក្របខណ្ឌផែនការយុទ្ធសាស្ត្រ រដ្ឋបាលជលផលបានកំណត់គោលដៅគន្លឹះចំនួន ៧។ គោលដៅគន្លឹះទាំង៧នេះនឹងរួមចំណែកយ៉ាងសំខាន់ក្នុងការសម្រេចបាននូវទស្សនវិស័យរបស់រាជរដ្ឋាភិបាលសម្រាប់វិស័យជលផលទៅថ្ងៃអនាគត។ គោលដៅគន្លឹះទាំងនេះត្រូវបានកំណត់ឡើង និងរំពឹងថានឹងសម្រេចឱ្យបាននៅឆ្នាំ ២០១៩។ ដើម្បីសម្រេចបាននូវកិច្ចការទាំងនេះ គឺតម្រូវឱ្យមានកិច្ចសហការរវាងរដ្ឋបាលជលផលជាមួយនឹងគ្រប់ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងគ្រប់ដៃគូអភិវឌ្ឍន៍ទាំងអស់។ គោលដៅគន្លឹះទាំងនេះ និងសសរស្តម្ភនៃការអភិវឌ្ឍវិស័យជលផលមានទំនាក់ទំនងជាមួយគ្នាយ៉ាងជិតស្និទ្ធ ដូចមានចែងនៅក្នុងតារាងខាងក្រោម៖







| គោលដៅ / សសរស្តម្ភ | ទិដ្ឋភាពរួម | ការនេសាទ | វារីវប្បកម្ម | ការកែច្នៃ និងពាណិជ្ជកម្ម | និយតកម្ម និងសេវាកម្ម |
|---|---|---|---|---|---|
| ១. ការរួមចំណែករបស់វិស័យជលផលដល់ការរីកចម្រើនជាតិមានកម្រិតខ្ពស់ និងមានចីរភាព | | √ | √ | √ | |
| ២. ជីវភាពរស់នៅរបស់ប្រជាជនក្នុងវិស័យនេះ កំពុងត្រូវបានធ្វើឱ្យប្រសើរឡើង និងមានកម្រិតខ្ពស់ជាងកម្រិតមធ្យមដែលបានកំណត់នៅថ្នាក់ជាតិ[៣] | √ | √ | | √ | |
| ៣. ដែននេសាទ និងប្រភពធនធានជលផលផ្សេងទៀតមានលក្ខខណ្ឌល្អ និងមានភាពសមស្រប ហើយត្រូវបានគ្រប់គ្រងប្រកបដោយចីរភាព[៤] | | √ | | | √ |
| ៤. ត្រី គឺជាប្រភពនៃចំណីអាហារដ៏សម្បូរបែប មានសុខភាព និងថ្លៃថ្នូរ | √ | √ | √ | √ | |
| ៥. មុខជំនួញក្នុងរបរនេសាទ គឺមានភាពចំណេញ ស្ថេរភាព និងមានភាពទទួលខុសត្រូវ | √ | √ | | √ | |
| ៦. ដែននេសាទត្រូវបានគ្រប់គ្រង អភិវឌ្ឍ និងអភិរក្ស ដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយប្រទេសជិតខាង | | | | | √ |
| ៧. បរិយាកាសគោលនយោបាយ ច្បាប់ និងការជួយគាំទ្រចំពោះវិស័យ គឺមានភាពគ្រប់គ្រាន់សមស្រប និងមានសមត្ថភាពអាចអនុវត្តបាន | √ | | | √ | √ |

ដើម្បីចង្អុលបង្ហាញអំពីសមិទ្ធផលដែលត្រូវសម្រេចឱ្យបាន និងដើម្បីត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្ត សូចនាករ និងចំណុចដៅនានាត្រូវបានរៀបចំឡើង។ ចំណុចដៅទាំងនេះត្រូវបានរៀបចំឡើងសម្រាប់រយៈពេល ៣ ឆ្នាំ ៦ ឆ្នាំ និង១០ ឆ្នាំ ហើយសូចនាករទាំងនេះត្រូវបានកំណត់ឡើងសម្រាប់ជាខ្នាតវាស់វែង និងសម្រាប់ផ្ទៀងផ្ទាត់ ជាមួយគោលដៅដែលបានកំណត់។ ប៉ុន្តែគួរទទួលស្គាល់ថា សូចនាករទាំងនេះ គឺគ្រាន់តែជាមធ្យោបាយសម្រាប់ចង្អុលបង្ហាញប៉ុណ្ណោះ នៅក្នុងកាលៈទេសៈខ្លះ ហេតុការណ៍ដែលនឹងកើតឡើង គឺលើសពីសិទ្ធិអំណាចរបស់រដ្ឋបាលជលផល ដូចនេះវាអាចជះឥទ្ធិពលដល់លទ្ធផលដែលត្រូវសម្រេចបាន។

ចំណុចដៅសំខាន់ៗជាច្រើនទៀតនឹងមានបង្ហាញជូនក្នុងផ្នែកបន្ទាប់នៃឯកសារនេះ (យុទ្ធសាស្ត្រសម្រាប់អនុវត្ត)។ សូចនាករ និងគោលដៅទាំងអស់សម្រាប់ឆ្នាំ ២០១០-២០១៩ មានចែងនៅក្នុងឧបសម្ព័ន្ធ ១។

គោលដៅ សូចនាករ និងចំណុចដៅទាំងអស់ដែលបានរៀបចំឡើង គឺជាមូលដ្ឋានគ្រឹះសម្រាប់ការរៀបចំផែនការអភិវឌ្ឍរយៈពេល ៣ ឆ្នាំ និងផែនការសកម្មភាពប្រចាំឆ្នាំរបស់វិស័យជលផល។ ប្រព័ន្ធកសាងផែនការនេះ គឺជាស្នូលក្នុងការសម្រេចបាននូវគោលដៅនានា ហើយនាំមកនូវលទ្ធផលជាក់ស្តែង និងការធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាជនប្រកបដោយនិរន្តរភាព។ ប្រព័ន្ធកសាងផែនការនេះ នឹងត្រូវអនុវត្តសម្រាប់រាល់ការផ្តួចផ្តើម និងសកម្មភាពនានាដែលរាជរដ្ឋាភិបាលនឹងទទួលរ៉ាប់រងក្នុងការអភិវឌ្ឍ និងគ្រប់គ្រងវិស័យជលផលប្រកបដោយនិរន្តរភាព។

៣. គិតទាំងអ្នកដែលមានមុខរបរដោយផ្ទាល់ ឬប្រយោល ទាំងអ្នកធ្វើនេសាទសុទ្ធ និងអ្នកធ្វើនេសាទតាមរដូវ
៤. ការចូលរួមពេលលេញពីប្រជាពលរដ្ឋមូលដ្ឋាន តាមរយៈដំណើរការសហគ្រប់គ្រងគឺជា មូលដ្ឋានគ្រឹះសម្រាប់គោលដៅនេះ







## ៤.៥ | គោលការណ៍ និងតម្លៃ

### គោលការណ៍

គោលការណ៍ជាមូលដ្ឋាន ដែលមានចែងនៅក្នុងទស្សនវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់វិស័យជលផល អាចយកមកប្រើប្រាស់ដើម្បីជាមគ្គុទ្ទេសក៍ក្នុងការរៀបចំការងារអភិវឌ្ឍវិស័យជលផល។ គោលការណ៍ទាំងនេះរួមមានដូចខាងក្រោមៈ

១ ធានាសន្តិសុខស្បៀងប្រកបដោយគុណភាព និងសុវត្ថិភាពល្អសម្រាប់ប្រជាជន។

២ លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន។

៣ លើកកម្ពស់ការអភិវឌ្ឍជាតិ។

៤ ធានានូវនិរន្តរភាព។

**ដើម្បីអនុវត្តគោលការណ៍ទាំងនេះក្នុងការដោះស្រាយនូវបញ្ហាដែលកំពុងជួបប្រទះនៅក្នុងវិស័យជលផលឱ្យបានសមស្រប យុទ្ធសាស្ត្រជាគន្លឹះមួយចំនួនដែលត្រូវគិតគូរ រួមមានដូចខាងក្រោមៈ**

១ ការពារ និងថែរក្សានូវប្រព័ន្ធអេកូឡូស៊ី ដើម្បីធ្វើឱ្យផលនេសាទធម្មជាតិ ស្ថិតក្នុងកម្រិតមួយដែលអាចធានាបាននូវបរិមាណគ្រប់គ្រាន់សម្រាប់បំពេញនូវតម្រូវការផង និងធានាបាននូវនិរន្តរភាពផង។

២ បង្កើនផលនេសាទនៅតាមវាលស្រែ។

៣ គាំទ្រដល់ការលូតលាស់ផ្នែកវារីវប្បកម្មទឹកសាបជាលក្ខណៈគ្រួសារ លក្ខណៈសិប្បកម្ម និងទ្រង់ទ្រាយធំ

៤ អភិវឌ្ឍការនេសាទសមុទ្រ និងវារីវប្បកម្មសមុទ្រ។

៥ ធ្វើឱ្យប្រសើរឡើងនូវបច្ចេកវិទ្យាកែច្នៃ។

៦ ជំរុញផល ផលិតផលជលផលនៅក្នុងទីផ្សារជាតិ និងអន្តរជាតិ។

៧ គាំទ្រពិពិធកម្មមុខរបរចិញ្ចឹមជីវិតក្រៅពីការធ្វើនេសាទដល់ប្រជានេសាទ ជាពិសេសអ្នកក្រីក្រ អ្នកបាត់បង់សមត្ថភាព និងជនងាយរងគ្រោះ ដើម្បីជួយឱ្យពួកគេចាកចេញផុតពីភាពក្រីក្រ។

៨ ធានាថាលិខិតបទដ្ឋានច្បាប់សម្រាប់វិស័យជលផលគឺមានការគាំទ្រ និងប្រកបដោយប្រសិទ្ធភាព។

៩ ធានាថា លទ្ធផលនៃការសិក្សាស្រាវជ្រាវ ត្រូវបានយកមកប្រើប្រាស់ និងគាំទ្រដល់ការអភិវឌ្ឍវិស័យជលផលប្រកបដោយសមធម៌។

### តម្លៃ

ការអភិវឌ្ឍវិស័យជលផល គឺត្រូវផ្អែកលើតម្លៃ ៤ យ៉ាង ដែលជាមគ្គុទេសក៍សម្រាប់សកម្មភាពរបស់យើងក្នុងនោះរួមមានៈ ការយល់ដឹង ការការពារ ការលូតលាស់ និងការគាំទ្រ។







១ **ការយល់ដឹង** យើងត្រូវយល់ដឹងអំពីវិស័យជលផល និងប្រជាជនដែលពឹងផ្អែកលើវិស័យនេះ ប្រសិនបើយើងចង់ឱ្យការរួមចំណែករបស់វិស័យជលផលដល់ការអភិវឌ្ឍជាតិមានកម្រិតអតិបរមា។ យើងមានជំនឿយ៉ាងមុតមាំថា គ្រប់អ្នកពាក់ព័ន្ធទាំងអស់នៅក្នុងវិស័យជលផលគួររៀនសូត្រពីគ្នាទៅវិញទៅមក។ នេះមានន័យថា យើងចង់បានការស្រាវជ្រាវដែលធ្វើឡើងចំគោលដៅ និងមានប្រសិទ្ធភាព ដើម្បីជាប្រយោជន៍ក្នុងការគាំទ្រ និងការលើកកម្ពស់សេចក្ដីសម្រេចចិត្តឱ្យបានស្របតាមស្ថានភាពជាក់ស្ដែង និងគាំទ្រដល់ការរៀបចំក្របខណ្ឌច្បាប់ និងគោលនយោបាយឱ្យបានសមស្រប។

២ **ការការពារ** យើងត្រូវការពារនូវប្រភេទវារីជាត ទីជម្រក និងប្រព័ន្ធអេកូឡូស៊ីទាំងទឹកសាប និងសមុទ្រ ប្រសិនបើយើងមានបំណងចង់ថែរក្សានូវផលប្រយោជន៍របស់វិស័យចំពោះជាតិ។ ជាពិសេស យើងត្រូវរួមសហការជាមួយប្រទេសជិតខាង និងដៃគូរបស់យើងដើម្បីប្រឆាំងនឹងការគំរាមកំហែងក្នុងការបំផ្លិចបំផ្លាញទីជម្រកទាំងនេះ។

៣ **ការលូតលាស់** យើងត្រូវធានាការលូតលាស់នៃផលិតភាពរបស់វិស័យជលផល ប្រសិនបើយើងចង់ឱ្យវិស័យនេះបន្តការផ្គត់ផ្គង់ម្ហូបអាហារដល់ប្រជាជនកម្ពុជាដែលកំពុងតែមានចំនួនកើនឡើង និងទទួលបាននូវផលប្រយោជន៍ពីការកើនឡើងនៃតម្រូវការទីផ្សារអន្តរជាតិចំពោះផលិតផលត្រី។ កិច្ចការនេះ គឺត្រូវធ្វើឡើងតាមរយៈការពង្រីកសកម្មភាពវារីវប្បកម្មជាលក្ខណៈគ្រួសារ និងទ្រង់ទ្រាយធំ និងនេសាទតាមវាលស្រែ ក៏ដូចជាតាមរយៈការពង្រីកការកែច្នៃ និងការនាំចេញ។

៤ **ការគាំទ្រ** យើងត្រូវគាំទ្រដំណើរការទាំងនេះតាមរយៈការផ្ដល់នូវសេវាកម្មប្រកបដោយប្រសិទ្ធភាព និងភាពស័ក្ដិសិទ្ធិ ដោយបង្កើតនូវបរិយាកាសងាយស្រួលដល់វិស័យឯកជនក្នុងការពង្រីកនូវការរួមចំណែករបស់ខ្លួនដល់ការអភិវឌ្ឍ ព្រមទាំងមានការបើកចំហ និងធ្វើឱ្យមានតម្លាភាពនូវគ្រប់សកម្មភាពទាំងអស់ការរៀបចំលិខិតបទដ្ឋានច្បាប់ដ៏មានប្រសិទ្ធភាព ការកសាងនូវទំនាក់ទំនងល្អជាមួយប្រទេសជិតខាង និងការសម្រេចចិត្តដោយមានភស្តុតាងជាមូលដ្ឋាន។ កិច្ចការនេះក៏តម្រូវឱ្យធ្វើឡើងស្របទៅតាមបទដ្ឋានអន្តរជាតិ ដូចជាកតិកាសញ្ញាអង្គការសហប្រជាជាតិជាដើម។ កតិកាសញ្ញាអង្គការសហប្រជាជាតិគឺជាគំនិតផ្ដួចផ្ដើមនៃយុទ្ធសាស្ត្រ និងគោលនយោបាយសកលសម្រាប់ការធ្វើពាណិជ្ជកម្មដោយផ្អែកលើគោលការណ៍ជាសកល ១០យ៉ាងពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ពលកម្ម បរិស្ថាន និងការប្រឆាំងអំពើពុករលួយ។

ជាក់ស្ដែងគោលការណ៍ទី៥ នៃកតិកាសញ្ញាអង្គការសហប្រជាជាតិលើកឡើងអំពីការកេងប្រវ័ញ្ចលើពលកម្មកុមារ (ដែលត្រូវបានកំណត់សម្រាប់កុមារអាយុក្រោម ១៤ ឆ្នាំ លើកលែងតែករណីពិសេសដែលកំណត់អាយុដល់ ១៨ ឆ្នាំ) និងសកម្មភាពជាបន្ទាន់ ដើម្បីកាត់បន្ថយ ឬ លុបបំបាត់ការកេងប្រវ័ញ្ចទាំងនេះ។ នៅកម្ពុជា មានកុមារជាច្រើនដែលបានចូលរួមនៅក្នុងសកម្មភាពនេសាទដែលសកម្មភាពខ្លះអាចប្រឈមនឹងគ្រោះថ្នាក់ ឬ ការរារាំងដល់កុមារមិនបានចូលរៀនសូត្រឱ្យបានត្រឹមត្រូវ។

ការទទួលខុសត្រូវក្នុងការសម្រេចបាននូវទស្សនវិស័យរបស់វិស័យជលផល គឺផ្អែកលើដំណើរការនៃកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល វិស័យឯកជន សហគមន៍មូលដ្ឋាន ក្រុមប្រឹក្សាឃុំ ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល។ ដៃគូនីមួយៗ ត្រូវមានការឯកភាពគ្នាតាមរយៈដំណើរការចរចារួមគ្នា ដោយគិតគូរអំពីលក្ខខណ្ឌ ដែលជាតម្រូវការរបស់ក្រសួង នាយកដ្ឋាន និងភ្នាក់ងាររបស់រដ្ឋាភិបាលនីមួយៗ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។







៥

# ការអនុវត្តយុទ្ធសាស្ត្រ

## ៥.១ | *បញ្ហារួម*

### ស្បៀងអាហារ ជីវភាពរស់នៅ និងការអភិវឌ្ឍ

សូចនាករសម្រាប់វាស់វែងការលូតលាស់ និងនិរន្តរភាពនៃវិស័យជលផល គឺជាសូចនាករយ៉ាងសំខាន់បំផុត ពីព្រោះការលូតលាស់ និងនិរន្តរភាព គឺជាថាមពលយ៉ាងសំខាន់ក្នុងការធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅ និងការលូតលាស់សេដ្ឋកិច្ច ក៏ដូចជាការធានាបាននូវសុវត្ថិភាពស្បៀង និងអាហារូបត្ថម្ភ។ ចំណុចដៅជាគន្លឹះសម្រាប់ការអភិវឌ្ឍវិស័យជលផលរួមមានដូចខាងក្រោម:

១ ផលនេសាទចាប់ពីធម្មជាតិ[៥] គឺមានកម្រិតថេរ និងមាននិរន្តរភាពក្នុងកម្រិតមិនលើសពី ៥០០.០០០ តោន/ឆ្នាំ។

២ ផលនេសាទតាមវាលស្រែ[៦] ប្រចាំឆ្នាំនឹងមានការកើនឡើង ១៥% ដើម្បីធ្វើឱ្យផលនេសាទសរុបទទួលបានចំនួន ៥០០.០០០ តោន/ឆ្នាំ នៅដំណាច់ឆ្នាំ ២០១៩។

៣ ផលិតផលវារីវប្បកម្មប្រចាំឆ្នាំ នឹងមានការកើនឡើង ១៥% ដើម្បីឈានទៅដល់ ១៨៥.០០០ តោន/ឆ្នាំ នៅដំណាច់ឆ្នាំ ២០១៩។



ការកំណត់នូវចំណុចដៅទាំងនេះហាក់ដូចជាមានមហិច្ឆតាធំធេងពេក ប៉ុន្តែយើងអាចធ្វើបាន។ កិច្ចអន្តរាគមន៍សំខាន់ដើម្បីសម្រេចបានតាមគោលដៅទាំងនេះ គឺភាពស្មោះត្រង់ និងការយល់ច្បាស់លាស់ (សូចនាករ និងចំណុចដៅនានាត្រូវបានរៀបចំឡើង)។ ចំណុចដៅសម្រាប់ផលិតផលជលផល ធៀបនឹងបរិមាណផលនេសាទសរុបបច្ចុប្បន្ន មានបង្ហាញជូននៅលើក្រាហ្វិកដូចខាងក្រោម:

---

*៥. គិតរួមទាំងផលចាប់តាមទន្លេ ស្ទឹង បឹង និងសមុទ្រ ប៉ុន្តែមិនគិតផលចាប់តាមវាលស្រែឡើយ*

*៦. រួមបញ្ចូលតំបន់ទំនាបលិចទឹកផ្សេងទៀត ប៉ុន្តែមិនគិតបញ្ចូលផលិតផលវារីវប្បកម្មឡើយ*







## ផលិតផលគោលដៅឆ្នាំ២០១០-២០១៩[៧]




មានបរិមាណផលនេសាទលើសពីតម្រូវការប្រើប្រាស់។ ដូច្នេះ យើងមានលទ្ធភាពអាចធ្វើឱ្យល្អប្រសើរឡើងនូវអាហារូបត្ថម្ភតាមស្តង់ដារហើយអាចជំរុញការអភិវឌ្ឍសេដ្ឋកិច្ចតាមរយៈការនាំចេញទៀតផង។ ដូច្នេះ ជីវភាពរស់នៅរបស់ប្រជាជនយើងកាន់តែមានភាពប្រសើរឡើង។

### មនុស្ស

ការលូតលាស់នៃផលនេសាទមិនអាចធានាបាននូវការអភិវឌ្ឍប្រកបដោយសមធម៌នោះទេ។ ហេតុនេះ ចំណុចដៅនានាពាក់ព័ន្ធនឹងការយកចិត្តទុកដាក់ដល់ជនក្រីក្រ និងជនងាយរងគ្រោះ ត្រូវបានរៀបចំឡើង។ ចំណុចដៅទាំងនេះរួមមានដូចខាងក្រោម:

១ ចំនួនអ្នកនេសាទ និងអ្នកកែច្នៃផលនេសាទទ្រង់ទ្រាយតូចដែលកំពុងរស់នៅក្រោមបន្ទាត់ភាពក្រីក្រដែលត្រូវបានកំណត់ដោយថ្នាក់ជាតិ នឹងត្រូវកាត់បន្ថយប្រមាណ ៤០% នៅចុងឆ្នាំ ២០១៩ ប្រៀបធៀបនឹងទិន្នន័យឆ្នាំគោល។

២ ជីវភាពរស់នៅរបស់ស្ត្រី និងបុរសមានកម្រិតស្មើគ្នានៅគ្រប់អនុវិស័យជលផល[៨] នៅចុងឆ្នាំ ២០១៩។

៣ កិច្ចអន្តរាគមន៍ក្នុងការផ្តល់នូវឱកាសការងារនៅថ្នាក់សហគមន៍[៩] នឹងត្រូវអនុវត្តទូទាំងប្រទេស នៅចុងឆ្នាំ ២០១៩។

៤ កម្រិតបរិមាណត្រីបរិភោគជាមធ្យមសម្រាប់មនុស្សម្នាក់ក្នុង១ឆ្នាំ គិតទូទាំងប្រទេស យ៉ាងហោចណាស់អាចរក្សាបាននូវកម្រិតដូចបរិមាណត្រីបរិភោគនៅក្នុងឆ្នាំ ២០០៧[១០] ហើយយ៉ាងហោចណាស់ ៧០% នៃអ្នកក្រីក្រនឹងទទួលបាននូវបរិមាណត្រីបរិភោគគិតជាមធ្យមនៅចុងឆ្នាំ ២០១៩ មានកម្រិតប្រហាក់ប្រហែលនឹងឆ្នាំ ២០០៧។

---

*៧. ប្រភព: ទិន្នន័យរបស់រដ្ឋបាលជលផល*

*៨. រួមទាំងលទ្ធភាពរបស់ស្ត្រីក្នុងការចូលរួមនៅក្នុងសកម្មភាពសហគមន៍នេសាទ វារីវប្បកម្ម និងការកែច្នៃជលផលនៃភូមិមួយផលិតផលជលផលមួយ*

*៩. ការធ្វើសុខដុមនីយកម្មនៃកម្មវិធីជាតិភូមិមួយផលិតផលមួយ ជាមួយកម្មវិធីថ្នាក់តំបន់ភូមិមួយផលិតផលជលផលមួយ គឺជាផ្នែកមួយនៃវិស័យជលផល*









៥ បរិមាណត្រី និងវារីសត្វដែលមានកម្រិតជីវជាតិខ្ពស់[១១] ដែលមនុស្សម្នាក់បរិភោគគិតជាមធ្យមក្នុង ១ ឆ្នាំ យ៉ាងហោចណាស់កើនឡើងចំនួន ៥០% ចាប់ពីឆ្នាំ ២០១១ ដល់ចុងឆ្នាំ ២០១៩។

សកម្មភាពដែលត្រូវអនុវត្តដើម្បីសម្រេចបាននូវចំណុចដៅខាងលើនឹងមានការត្រួតពិនិត្យជាទៀងទាត់ ជាពិសេសចំណុចដៅពាក់ព័ន្ធនឹងកិច្ចអន្តរាគមន៍នឹងត្រូវដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពអភិវឌ្ឍន៍វិស័យជលផល។

## ៥.២ នេសាទទឹកសាប និងសមុទ្រ

ដើម្បីសម្រេចបាននូវការលូតលាស់នៃផលិតផលជលផល ដែលជាតម្រូវការសម្រាប់ជំរុញការអភិវឌ្ឍ ចំណុចដៅជាក់លាក់មួយចំនួនត្រូវបានរៀបចំឡើង។ ចំពោះនេសាទទឹកសាប គោលបំណងសំខាន់គឺការគាំទ្រ និងការបង្កើននូវសមត្ថភាពទ្រទ្រង់នៃប្រព័ន្ធតំបន់ដីសើម (ជាពិសេសតំបន់វាលស្រែ)។ ចំពោះដែននេសាទតាមទន្លេ និងបឹង ចំណុចដៅដែលត្រូវកំណត់គឺពាក់ព័ន្ធនឹងការការពារប្រព័ន្ធអេកូឡូស៊ី ដែលជាកិច្ចការចាំបាច់ក្នុងការធានាបាននូវនិរន្តរភាពប្រភេទ និងបរិមាណត្រីចម្រុះ។ ដោយឡែក ចំពោះនេសាទសមុទ្របច្ចុប្បន្ននេះ គឺការយល់ដឹងពុំទាន់បានទូលំទូលាយ ដូច្នេះចំណុចដៅជាដំបូង គឺការរៀបចំផែនការ ដើម្បីធានាការលូតលាស់ធនធានជលផលប្រកបដោយនិរន្តរភាព។ ខាងក្រោមនេះ គឺជាចំណុចដៅដែលបានកំណត់ឡើងសម្រាប់ទាំងនេសាទទឹកសាប និងនេសាទសមុទ្រ៖

១ យ៉ាងហោចណាស់ឃុំចំនួន ១.២០០ (៧៥%នៃចំនួនឃុំសរុប) បានរៀបចំស្រះជម្រកត្រីសហគមន៍ ប្រកបដោយនិរន្តរភាព និងប្រសិទ្ធភាព នៅត្រឹមដំណាច់ឆ្នាំ ២០១៩[១២]។

២ សហគមន៍នេសាទចំនួន ៤៧០ បានចុះបញ្ជីជាផ្លូវការ និងមានដំណើរការប្រកបដោយប្រសិទ្ធភាព នៅត្រឹមដំណាច់ឆ្នាំ ២០១៩។

៣ ផលនេសាទចាប់បាននៅតាមឡូត៍នេសាទរក្សាបាននូវនិរន្តរភាពជារៀងដរាប។

៤ ផែនការដោយផ្អែកលើមូលដ្ឋានវិទ្យាសាស្ត្រ សម្រាប់ការធ្វើអាជីវកម្មនេសាទសមុទ្រប្រកបដោយនិរន្តរភាពនឹងត្រូវបានរៀបចំរួចរាល់ ហើយអនុវត្តនៅត្រឹមដំណាច់ឆ្នាំ ២០១៤។

៥ យ៉ាងហោចណាស់ផ្ទៃដីព្រៃលិចទឹកនៅតំបន់ទឹកសាបចំនួន ៣៥% និងផ្ទៃដីព្រៃលិចទឹកនៅតំបន់ឆ្នេរសមុទ្រចំនួន ៧៥% ត្រូវបានការពារយ៉ាងល្អ តាមរយៈការកំណត់ និងបោះបង្គោលព្រំប្រទល់នៅត្រឹមដំណាច់ឆ្នាំ ២០១៩។

---

១០. ៥២,៤ គ.ក/១នាក់/ឆ្នាំ

១១. ប្រភេទវារីសត្វមួយចំនួនត្រូវបានរកឃើញថាមានសារជាតិវីតាមីនចាំបាច់ និងសារជាតិចិញ្ចឹមខ្ពស់ប្រៀបធៀបនឹងប្រភពប្រូតេអ៊ីនត្រី ឬសត្វផ្សេងទៀត

១២. នេះគឺជាសកម្មភាពអន្តរាគមន៍យ៉ាងសំខាន់ដើម្បីបង្កើនផលនេសាទតាមវាលស្រែ។ ស្រះជម្រកត្រីសហគមន៍ដែលបានរៀបចំកន្លងមកបានបង្កើននូវផលិតភាពត្រីនៅតាមវាលស្រែយ៉ាងខ្ពស់ រហូតដល់ទៅ ៦ ដង។ រដ្ឋបាលជលផលកំពុងជំរុញ និងគាំទ្រដល់សហគមន៍មូលដ្ឋានក្នុងការរៀបចំ ថែរក្សា និងការពារ ស្រះជម្រកត្រីតាមវាលស្រែផ្អែកតាមគោលការណ៍ស្ម័គ្រចិត្ត និងម្ចាស់ការ







៦ យ៉ាងហោចណាស់អន្លង់ជ្រៅៗចំនួន ៤០ ក្នុងចំណោមអន្លង់ទាំង ៩៧ ត្រូវបានការពារ និងអភិរក្ស ប្រកបដោយប្រសិទ្ធភាព ហើយយ៉ាងហោចណាស់ក៏មានកន្លែងអភិរក្សចំនួន ៨០% នៃបឹងទន្លេសាប ត្រូវបានកែលំអតាមរយៈការកំណត់ព្រំប្រទល់ ការការពារ និងការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ នៅត្រឹមដំណាច់ឆ្នាំ ២០១៩។

ក្រោយឆ្នាំ ២០១៩ នឹងមានកិច្ចការជាច្រើនទៀតដែលត្រូវបំពេញឱ្យបានចប់សព្វគ្រប់ ពាក់ព័ន្ធនឹងការថែរក្សាព្រៃលិចទឹក អន្លង់ជ្រៅៗ តំបន់អភិរក្ស និងទីជម្រកសំខាន់ៗទាំងអស់ ប៉ុន្តែចំណុចដៅខាងលើមិនបានលើកឡើងនូវតម្រូវការទាំងនេះឡើយ។

## ៥.៣ វារីវប្បកម្ម

វារីវប្បកម្មនៅកម្ពុជាមានសក្តានុពលយ៉ាងធំធេងសម្រាប់រយៈពេលយូរអង្វែង។ ទោះជាយ៉ាងនេះក្តី បរិមាណផលិតផលវារីវប្បកម្ម នៅក្នុងតំណាក់កាលចាប់ផ្តើម គឺមានកម្រិតទាបនៅឡើយ (ក្នុងឆ្នាំ ២០០៩ ផលិតផលវារីវប្បកម្មអនុវត្តបានត្រឹមតែ ៥០.០០០ តោន ប៉ុណ្ណោះ ដែលភាគច្រើនគឺបានមកពីការចិញ្ចឹមជាទ្រង់ទ្រាយតូច)។ ស្ថិតនៅក្នុងសភាពការណ៍ដែលជាតម្រូវការចាំបាច់ចំពោះមុខកិច្ច អន្តរាគមន៍ជាចម្បងគឺត្រូវគាំទ្រដល់ការអភិវឌ្ឍដែលមានលក្ខណៈគ្រួសារជាមុនសិន ដោយត្រូវផ្តល់នូវការបណ្តុះបណ្តាល ការផ្តល់នូវ កូនត្រីពូជ និងរៀបចំប្រព័ន្ធគ្រប់គ្រងហានិភ័យ។ ចំណុចដៅនានាពាក់ព័ន្ធនឹងផ្នែកនេះរួមមានដូចខាងក្រោមៈ

១ យ៉ាងហោចណាស់កសិករចំនួន ៨៥.០០០ នាក់ ដែលបានបណ្តុះបណ្តាលបានចូលរួមយ៉ាងសកម្មនៅក្នុងការងារវារីវប្បកម្ម នៅដំណាច់ឆ្នាំ ២០១៩។

២ ការផលិតកូនត្រីពូជត្រូវបានបង្កើនឡើងដល់ ២៥០.០០០.០០០ កូន ក្នុងមួយឆ្នាំ នៅត្រឹមដំណាច់ឆ្នាំ ២០១៩។

៣ ប្រព័ន្ធតាមដាន និងត្រួតពិនិត្យជំងឺត្រីនឹងត្រូវបានរៀបចំឡើង ហើយអនុវត្តនៅត្រឹមដំណាច់ឆ្នាំ ២០១៤។

៤ ការស្រាវជ្រាវ និងការអភិវឌ្ឍដើម្បីកំណត់នូវប្រភេទត្រីក្នុងស្រុក ដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់ ដោយ រួមសហការជាមួយនឹង កិច្ចអន្តរាគមន៍ថ្នាក់តំបន់ ដូចជាគណៈកម្មការទន្លេមេគង្គនឹងត្រូវធ្វើឡើង។

ដើម្បីសម្របសម្រួលការអភិវឌ្ឍវារីវប្បកម្ម រដ្ឋបាលជលផលត្រូវរៀបចំគោលការណ៍ណែនាំបច្ចេកទេស និងលិខិតបទដ្ឋានតាម ស្តង់ដារ ស្របតាមច្បាប់ស្តីពីជលផល ដើម្បីគាំទ្រផ្នែកវារីវប្បកម្មក្នុងការសម្រេចបាននូវចំណុចដៅដែលបានកំណត់។

## ៥.៤ ការកែច្នៃ និងពាណិជ្ជកម្ម

ការគិតគូរអំពីគុណភាពនៃការកែច្នៃ កម្រិតស្តង់ដារ ដំណើរការ និងនីតិវិធីសមស្រប គឺជាស្នូលក្នុងការលើកកម្ពស់នូវអាហារូបត្ថម្ភ ជីវភាពរស់នៅ និងការធ្វើជំនួញ (ទាំងជាតិ និងអន្តរជាតិ)។ កិច្ចអន្តរាគមន៍សំខាន់គឺផ្តោតទៅលើការកែលំអគុណភាព និងលើកកម្ពស់ លទ្ធភាពទីផ្សារ។ ចំណុចដៅជាគន្លឹះ រួមមានដូចខាងក្រោមៈ







១ យ៉ាងហោចណាស់ ៨០% នៃអ្នកកែច្នៃ និង ៨០% នៃផលិតផលត្រី នឹងត្រូវបានអនុវត្តស្របតាមបទបញ្ញត្តិនៃការធានារ៉ាប់រងគុណភាព សុវត្ថិភាព និងស្តង់ដារ[13] នៅត្រឹមដំណាច់ចុងឆ្នាំ ២០១៩។

២ សមាគមកសិករ[14] នឹងត្រូវបង្កើតឡើង ហើយមានលទ្ធភាពអាចទទួលបាននូវហិរញ្ញវត្ថុ និងមានទីផ្សារ នៅត្រឹមដំណាច់ឆ្នាំ ២០១៩។

៣ កិច្ចអន្តរាគមន៍នៅថ្នាក់សហគមន៍ដែលធ្វើឱ្យប្រសើរឡើងនូវគុណភាព និងការចូលទៅកាន់ទីផ្សារ[15] នឹងត្រូវអនុវត្តទូទាំងប្រទេសនៅត្រឹមដំណាច់ឆ្នាំ ២០១៩។

រដ្ឋបាលជលផលនឹងរៀបចំស្តង់ដារពេញលេញមួយ និងគោលការណ៍ណែនាំ ដើម្បីលើកកម្ពស់គុណភាពកែច្នៃ ការវេចខ្ចប់ និងសុវត្ថិភាព ហើយនឹងត្រូវអនុវត្តការចុះបញ្ជីជាផ្លូវការ និងដំណើរការត្រួតពិនិត្យឱ្យបានល្អប្រសើរ។ ការងារទាំងនេះ នឹងត្រូវបានរៀបចំដើម្បីសម្របសម្រួលដល់ការធ្វើពាណិជ្ជកម្មដោយផ្តល់នូវការធានារ៉ាប់រងអំពីគុណភាព ហើយយកចិត្តទុកដាក់ជាចំបង គឺធានាថា ទាំងអ្នកមានមុខរបរខ្នាតធំ និងខ្នាតតូចមិនចាំបាច់ចំណាយបន្ថែមទៅលើបន្ទុកការងាររដ្ឋបាលឡើយ។ រដ្ឋបាលជលផលនឹងសហការជាមួយក្រសួងពាណិជ្ជកម្ម ដើម្បីរិះរកមធ្យោបាយក្នុងការកាត់បន្ថយរបាំងពាណិជ្ជកម្មដែលប៉ះពាល់ដល់វិស័យជលផល ហើយនឹងតម្រឹមជាមួយនឹងយុទ្ធសាស្ត្រពាណិជ្ជកម្មបើកទូលាយរបស់រាជរដ្ឋាភិបាល។

## ៥.៥ ការធ្វើនិយ័តកម្ម និងសេវាកម្ម

កិច្ចអន្តរាគមន៍នានាដែលជាតម្រូវការចាំបាច់សម្រាប់ការអភិវឌ្ឍ គឺត្រូវស្ថាបនាឡើងដោយផ្អែកលើមូលដ្ឋាន នៃការទទួលស្គាល់ដោយច្បាប់ និងបទប្បញ្ញត្តិនានា។ កិច្ចការនេះ គឺគ្របដណ្តប់ទាំងតម្រូវការនៃការទទួលស្គាល់ និងការដោះស្រាយនូវបញ្ហាគំរាមកំហែង ហើយត្រូវកសាងឡើងផ្អែកលើភាពខ្លាំងដែលកំពុងកើតមានបច្ចុប្បន្ន។ ការប្រើប្រាស់លទ្ធផលនៃការសិក្សាស្រាវជ្រាវប្រកបដោយប្រសិទ្ធភាព គឺតម្រូវឱ្យមានព័ត៌មានគ្រប់គ្រាន់សម្រាប់ផ្តល់នូវភស្តុតាងជាមូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេចចិត្ត នៅក្នុងដំណើរការរៀបចំផែនការ និងការធ្វើនិយ័តកម្ម។ ប៉ុន្តែគ្រប់ ការធ្វើនិយ័តកម្ម និងការផ្តល់សេវាកម្មទាំងអស់ ត្រូវតែឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជន។ ចំណុចដៅដែលបានកំណត់នៅក្នុងផ្នែកនេះរួមមានដូចខាងក្រោម៖

១ ការផ្ទេរសិទ្ធិអំណាចទទួលខុសត្រូវពេញលេញទៅឱ្យភ្នាក់ងារនៅថ្នាក់ក្រោមជាតិ ស្របតាមកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកម្មវិធីជាតិកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនឹងត្រូវធ្វើឡើងនៅត្រឹមដំណាច់ឆ្នាំ ២០១៩។

២ ការផ្តល់លទ្ធភាពក្នុងការធ្វើនិយ័តកម្មសម្រាប់អនុវិស័យជលផលទាំងអស់ ក្នុងការគាំទ្រអភិបាលកិច្ចល្អ ការអភិវឌ្ឍអនុវិស័យ និងការអនុវត្តច្បាប់ជាតិ (រាប់បញ្ចូលទាំងការប្រឆាំងនឹងអំពើពុករលួយ[16]) នឹងត្រូវរៀបចំឱ្យបាននៅត្រឹមដំណាច់ឆ្នាំ២០១៩។

---

*១៣. ស្តង់ដារថ្នាក់ជាតិនឹងត្រូវរៀបចំឡើងសម្រាប់ការជួញដូរ និងប្រើប្រាស់ផ្ទៃក្នុង។ ទន្ទឹមនេះ ស្តង់ដារកម្រិតអន្តរជាតិនឹងត្រូវអនុវត្តផងដែរ។ កិច្ចការនេះនឹងត្រូវរួមបញ្ចូលទាំងការកសាងសមត្ថភាពមន្ត្រីរបស់រដ្ឋបាលជលផល។*

*១៤. រួមទាំងសកម្មភាពកែច្នៃ ពាណិជ្ជកម្ម និងទីផ្សារផលនេសាទនៃកម្មវិធីភូមិមួយផលិតផលជលផលមួយ និងសហគមន៍កសិករចិញ្ចឹម និងភ្ញាស់ត្រី*

*១៥. ការធ្វើសុខដុមនីយកម្មនៃកម្មវិធីជាតិភូមិមួយផលិតផលមួយ ជាមួយកម្មវិធីថ្នាក់តំបន់ភូមិមួយផលិតផលជលផលមួយ គឺជាផ្នែកមួយនៃវិស័យជលផល*

*១៦. ការគាំទ្រច្បាប់ប្រឆាំងនឹងអំពើពុករលួយគឺជាសកម្មភាពអាទិភាព*







៣ ផែនការដ៏ទូលំទូលាយដើម្បីដោះស្រាយបញ្ហាជាអន្តរជាតិ ដែលវិស័យជលផលនៅកម្ពុជាជួបប្រទះ រួមមានការប្រែប្រួលអាកាសធាតុ ការសាងសង់ទំនប់ ការខូចខាតបរិស្ថាន នឹងត្រូវរៀបចំឡើងឱ្យបាននៅត្រឹមដំណាច់ឆ្នាំ ២០១១។

៤ ការវាយតម្លៃដោយមានការចូលរួម នឹងត្រូវប្រើប្រាស់ជាផ្លូវការក្នុងការគាំទ្រដល់ដំណើរការរៀបចំលិខិតបទដ្ឋានគតិយុត្តិនានា និងការកសាងផែនការ ហើយយ៉ាងហោចណាស់ ៧០% នៃប្រជាជននៅក្នុងសហគមន៍នេសាទ និងសាធារណជនទូទៅ នឹងឆ្លើយតបជាវិជ្ជមានចំពោះគោលនយោបាយអភិវឌ្ឍន៍វិស័យជលផល ហើយការអនុវត្តនឹងត្រូវធ្វើឡើងនៅត្រឹមដំណាច់ឆ្នាំ ២០១៩។

នៅទីកន្លែងដែលមានបញ្ហាឆ្លងដែន រដ្ឋបាលជលផលធានាឱ្យមានការចូលរួមពេញលេញនៅក្នុងក្របខណ្ឌការងាររបស់គណៈកម្មការទន្លេមេគង្គ តាមរយៈសមាជិកភាពនៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា។ រដ្ឋបាលជលផលនឹងនាំយកបញ្ហាដែលជះឥទ្ធិពលទៅលើវិស័យជលផលដោយផ្ទាល់ ដើម្បីទាញការយកចិត្តទុកដាក់ពីគណៈកម្មការទន្លេមេគង្គ ហើយសហការស្វែងរកនូវដំណោះស្រាយរួមគ្នាដោយរួមទាំងកិច្ចព្រមព្រៀងអន្តរជាតិ តាមការចាំបាច់ និងសមស្រប។

## ៥.៦ ផែនការ និងការចាត់អាទិភាព

### ផែនការ

ក្របខណ្ឌផែនការយុទ្ធសាស្ត្រនេះ គឺបង្ហាញនូវចំណុចចាប់ផ្តើមសម្រាប់គ្រប់ផែនការសកម្មភាព និងផែនការអភិវឌ្ឍរបស់រដ្ឋបាលជលផល។ ទោះបីជាយ៉ាងដូចនេះក្តី ផែនការរយៈពេលវែង គឺត្រូវការកែសម្រួល ដើម្បីឆ្លុះបញ្ចាំងអំពីនយោបាយ សង្គម សេដ្ឋកិច្ច និងការប្រែប្រួលបរិស្ថាន ដែលមានឥទ្ធិពលមកលើវិស័យជលផលនៅក្នុងឆ្នាំខាងមុខ។ ដូច្នេះក្របខណ្ឌផែនការយុទ្ធសាស្ត្រនេះមានគោលបំណងកំណត់នូវបំណងប្រាថ្នា និងទិសដៅដ៏ទូលំទូលាយសម្រាប់អនាគត ដែលជាមូលដ្ឋានបង្អែកយ៉ាងសំខាន់សម្រាប់ផែនការរយៈពេលខ្លី។ ដំណើរការរៀបចំផែនការនេះមានជំហាន និងមានផ្នែកជាច្រើនរួមបញ្ចូលគ្នា។

១ **ផែនការសកម្មភាពអភិវឌ្ឍន៍វិស័យជលផលៈ** ផែនការនេះមានវិសាលភាពគ្របដណ្តប់រយៈពេល៣ឆ្នាំដែលបានមកពីកម្មវិធី និងការធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ ដើម្បីគ្របដណ្តប់រយៈពេល ៣ ឆ្នាំ ខាងមុខ។ ដូច្នេះផែនការនេះ គឺជាផែនការរំកិល។ វាបានផ្តល់ឱ្យនូវទិសដៅលម្អិត និងបង្កើតជាឧបករណ៍សំខាន់ សម្រាប់ជាទម្រង់របស់សកម្មភាពលម្អិតរបស់រដ្ឋបាលជលផល និងបង្ហាញដល់ដៃគូអភិវឌ្ឍន៍ទាំងអស់ អំពីកម្មវត្ថុរបស់រាជរដ្ឋាភិបាលចំពោះវិស័យជលផលនៅរយៈពេលទៅខាងមុខ។ នេះគឺជាផែនការដែលនឹងត្រូវប្រើប្រាស់ដើម្បីធានាថា ការអនុវត្តគឺស្របតាមចំណុចដៅ ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រ ហើយស្ថិតនៅលើផ្លូវដ៏ត្រឹមត្រូវមួយ ដើម្បីសម្រេចបាននូវទស្សនវិស័យរបស់រាជរដ្ឋាភិបាល ចំពោះវិស័យជលផល។

២ **ផែនការប្រចាំឆ្នាំរបស់វិស័យជលផលៈ** នេះគឺជាផែនការលម្អិតដែលបង្ហាញនូវលទ្ធផលរំពឹងទុកដែលនឹងត្រូវសម្រេចឱ្យបាន និងសកម្មភាពដែលត្រូវអនុវត្តនៅក្នុងឆ្នាំនីមួយៗ សំដៅសម្រេចឱ្យបាននូវគោលបំណងរួម។ ផែនការនេះរួមមាន ផែនការសកម្មភាពតាមផ្នែកនីមួយៗរបស់វិស័យជលផល ដូចជា ផ្នែកវារីវប្បកម្ម សហគមន៍នេសាទ កិច្ចការនេសាទ គុណភាព និងកែច្នៃ អភិរក្ស និងគ្រប់គ្រងធនធានជលផល លើសពីនេះនៅមានផែនការលម្អិតទៅតាមសកម្មភាពជាក់លាក់នីមួយៗថែមទៀត។







៣ **ផែនការសកម្មភាពប្រចាំឆ្នាំរបស់ខណ្ឌរដ្ឋបាលជលផលៈ** ការគ្រប់គ្រងវិស័យជលផលនៅតាមបណ្ដា ខេត្តនីមួយៗ គឺត្រូវបានគាំទ្រដោយខណ្ឌរដ្ឋបាលជលផល។ ខណ្ឌរដ្ឋបាលជលផលបានធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គការក្នុងស្រុក និងប្រជាពលរដ្ឋ ហើយនេះគឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការផ្ដល់នូវសេវាកម្មជូនដល់អ្នកពាក់ព័ន្ធទាំងនោះ។ រដ្ឋបាលជលផលកំពុងធ្វើការងារតាមរយៈខណ្ឌរដ្ឋបាលជលផល ដើម្បីបង្កិតផែនការសកម្មភាពទៅជិតប្រជាជនដែលជាក្រុមអ្នកទទួលផលតាមគោលដៅកំណត់ ហើយកិច្ចការនេះត្រូវបានធ្វើឡើងស្របជាមួយនឹងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល។

## ការចាត់អាទិភាព

រាជរដ្ឋាភិបាលបានទទួលស្គាល់ថា ក្របខណ្ឌផែនការយុទ្ធសាស្ត្រនេះ គឺមានភាពធំធេង ប៉ុន្តែសកម្មភាពទាំងនេះ គឺជាការចាំបាច់ក្នុងការសម្រេចឱ្យបាននូវគោលដៅនានាដែលបានកំណត់ ហើយការអនុវត្តគឺតម្រូវឱ្យមានធនធានគ្រប់គ្រាន់នៅគ្រប់ដំណាក់កាលទាំងមូល។ ជាក់ស្ដែង រាជរដ្ឋាភិបាលទទួលស្គាល់ផងដែរថា ផលលំបាកនឹងអាចកើតមាននៅរាល់ពេលវេលា ជាពិសេសពាក់ព័ន្ធនឹងលក្ខខណ្ឌសេដ្ឋកិច្ចពិភពលោក។ ហេតុនេះ ការរៀបចំគោលការណ៍សម្រាប់កំណត់សកម្មភាពជាអាទិភាពដែលអាចអនុវត្តបានក្នុងកម្រិតមួយ នៅទីកន្លែង និងពេលវេលាជាក់លាក់គឺជាការចាំបាច់។ ផ្អែកតាមគោលដៅអភិវឌ្ឍន៍សហស្សវត្ស និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ សកម្មភាពអាទិភាពសំខាន់ៗរួមមានដូចខាងក្រោមៈ

១ សកម្មភាពទាំងឡាយដែលមានភាពចាំបាច់ និងបន្ទាន់ក្នុងការបំពេញនូវតម្រូវការនៃម្ហូបអាហារ និងសុវត្ថិភាពស្បៀងរួមទាំងសកម្មភាពកាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាជនដែលពឹងផ្អែកលើធនធានជលផល ដែលបណ្ដាលមកពីការគំរាមកំហែងពីកត្តាខាងក្រៅទៅលើប្រព័ន្ធជីវចម្រុះនៅក្នុងតំបន់ដីសើម។

២ សកម្មភាពទាំងឡាយដែលមានសារៈសំខាន់ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាជនក្រីក្រ។

៣ សកម្មភាពទាំងឡាយដែលមានសារៈសំខាន់ដើម្បីគាំទ្រដល់ការលូតលាស់សេដ្ឋកិច្ចរយៈពេលវែង។

ជារួម រដ្ឋបាលជលផល នឹងអនុវត្តទៅតាមវដ្តនៃផែនការដែលបានបញ្ជាក់ខាងលើ និងយុទ្ធសាស្ត្រ ឬគោលនយោបាយទាំងឡាយ ប៉ុន្តែដើម្បីចាប់ផ្ដើមអនុវត្តក្របខណ្ឌផែនការយុទ្ធសាស្ត្រនេះ ផ្នែកមួយចំនួនដូចខាងក្រោម នឹងត្រូវបានចាត់ជាអាទិភាពៈ

១ ការស្រាវជ្រាវ និងការអភិវឌ្ឍ។

២ ការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលជលផលថ្នាក់កណ្ដាល ក៏ដូចជាការអភិឌ្ឍធនធានមនុស្សនៅថ្នាក់ខណ្ឌរដ្ឋបាលជលផល។

៣ ការអភិវឌ្ឍវារីវប្បកម្មគ្រប់ប្រភេទ ទាំងទឹកសាប និងសមុទ្រ។









៤ សហគមន៍នេសាទ និងការនេសាទក្នុងវាលស្រែ។

៥ ការកាត់បន្ថយកំហាតបង់នៅក្នុងសកម្មភាពកែច្នៃជលផល និងការខ្វះខ្នាយចំពោះអ្នកកែច្នៃខ្នាតតូច។

៦ ការរៀបចំ និងការអនុវត្តផែនការខណ្ឌរដ្ឋបាលជលផល។

៧ ការអភិរក្ស និងការការពារតាមរយៈសកម្មភាពសំខាន់ដូចខាងក្រោមៈ

- ការធ្វើផែនទីការកំណត់ព្រំប្រទល់ និងការការពារព្រៃលិចទឹក
- ការការពារ និងការអភិរក្សអន្លង់ជ្រៅៗនៅតំបន់មេគង្គលើ
- ការគ្រប់គ្រងប្រកបដោយនិរន្តរភាពនូវទីជម្រកជលផលសំខាន់ៗ
- ផែនការដ៏ទូលំទូលាយសម្រាប់កិច្ចសហប្រតិបត្តិការថ្នាក់តំបន់ ដើម្បីដោះស្រាយនូវបញ្ហាដែលកើតមានជាអន្តរជាតិចំពោះវិស័យជលផលនៅក្នុងប្រទេសកម្ពុជា រួមមានការប្រែប្រួលអាកាសធាតុ ការសាងសង់ទំនប់ និងការខូចខាតបរិស្ថាន នឹងត្រូវរៀបចំឱ្យបាននៅត្រឹមដំណាច់ឆ្នាំ ២០១១។







# ៦

# ធនធាន

## ៦.១ សមត្ថភាពមន្ត្រី

ភាពជោគជ័យនៃការធ្វើផែនការនានារបស់រដ្ឋបាលជលផល គឺពឹងអាស្រ័យទៅលើសមត្ថភាពក្នុងការផ្តល់នូវសេវាកម្មដែលជាតម្រូវការសម្រាប់វិស័យជលផល។ កិច្ចការនេះគឺទាមទារឱ្យមានការបង្កើននូវសមត្ថភាពជំនាញរបស់មន្ត្រីរដ្ឋបាលជលផលជាពិសេសនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក។ រដ្ឋបាលជលផលក៏ទទួលស្គាល់ផងដែរថា ការអភិវឌ្ឍជំនាញផ្ទាល់ខ្លួន គឺជាការចាំបាច់ចំពោះការផ្តល់អាទិភាពចំពោះធនធានមនុស្ស ហើយក៏ទទួលស្គាល់ផងដែរថា នៅក្នុងរយៈពេលខ្លី រដ្ឋបាលជលផលមិនអាចផ្តល់នូវគ្រប់សេវាកម្មតាមតម្រូវការបានឡើយ។ ហេតុនេះ រដ្ឋបាលជលផលនឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួង នាយកដ្ឋាន និងភ្នាក់ងារផ្សេងៗ ដើម្បីធានាឱ្យមានការសម្របសម្រួល និងសហប្រតិបត្តិការអន្តរវិស័យ។ ក្រុមការងារបច្ចេកទេសចម្រុះស្តីពីកំណែទម្រង់នេសាទ នឹងបំពេញតួនាទីយ៉ាងសំខាន់ក្នុងការងារនេះ។

រដ្ឋបាលជលផលនឹងធ្វើការងារជាដៃគូជាមួយនឹងអង្គការនានា និងវិស័យឯកជនទៅតាមសមត្ថភាព និងលទ្ធភាពដែលអាចធ្វើបាន។ ដូច្នេះ តួនាទីរបស់ក្រុមការងារបច្ចេកទេសចម្រុះស្តីពីកំណែទម្រង់នេសាទ គឺជាចំណុចគន្លឹះក្នុងការរៀបចំ និងសម្របសម្រួលភាពជាដៃគូឱ្យមានដំណើរការល្អ។

ទោះបីជាយ៉ាងដូច្នេះក្តី ការអភិវឌ្ឍសមត្ថភាព និងជំនាញរបស់មន្ត្រីរដ្ឋបាលជលផល គឺជាកត្តាយ៉ាងសំខាន់ក្នុងការអនុវត្តឱ្យបានជោគជ័យ ស្របទៅតាមក្របខណ្ឌនៃផែនការយុទ្ធសាស្ត្រនេះ។ ហេតុដូច្នេះរដ្ឋបាលជលផលនឹងរៀបចំ និងអនុវត្តកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្សឱ្យបានទូលំទូលាយដល់មន្ត្រីគ្រប់កម្រិតថ្នាក់ទាំងអស់។ ការងារនេះ គឺតម្រូវឱ្យមានការវិភាគអំពីតម្រូវការជំនាញ ការកំណត់នូវដំណោះស្រាយសម្រាប់ទទួលបាននូវជំនាញទាំងនេះ។ គោលបំណងជារួម គឺការព្យាយាមដើម្បីស្វែងរកវិធីសាស្ត្រ ក្នុងការកាត់បន្ថយការពឹងផ្អែកទៅលើតែជំនួយបច្ចេកទេសពីខាងក្រៅ និងអន្តរជាតិ ចាប់ពីទសវត្សន៍ទី ២ នៃសតវត្សន៍ទី ២១ នេះ។ ជាពិសេស នៅក្នុងពេលចាប់ផ្តើមនៃការអនុវត្តក្របខណ្ឌផែនការយុទ្ធសាស្ត្ររបស់វិស័យជលផលនេះ គឺតម្រូវឱ្យមានទីប្រឹក្សាបច្ចេកទេសថ្នាក់ជាតិ និងអន្តរជាតិ ដើម្បីជួយដល់រដ្ឋបាលជលផលក្នុងការអនុវត្តសកម្មភាពជាអាទិភាពឱ្យបានទូលំទូលាយទៅតាមលទ្ធភាពដែលអាចធ្វើបាន។ នៅថ្នាក់មូលដ្ឋាន ជំនួយការសម្រាប់ខណ្ឌរដ្ឋបាលជលផល គឺជាការចាំបាច់ ដើម្បីធានាការអនុវត្តផែនការសកម្មភាពនានាឱ្យបានជោគជ័យ។

ទីប្រឹក្សាបច្ចេកទេសពីខាងក្រៅ នឹងត្រូវជ្រើសរើស នៅពេលដែលមន្ត្រីថ្នាក់ជាតិត្រូវការជំនួយ ដូច្នេះការសិក្សា វាយតម្លៃអំពីតម្រូវការគឺជាលទ្ធផលនៃផែនការអភិវឌ្ឍធនធានមនុស្សរបស់រដ្ឋបាលជលផល។ តាមការប៉ាន់ស្មាន ទីប្រឹក្សាអន្តរជាតិយ៉ាងច្រើនចំនួន ៤ រូប និងទីប្រឹក្សាជាតិចំនួនពី ២០ ទៅ ២៤ រូប នឹងត្រូវជ្រើសរើសក្នុងមួយឆ្នាំៗ។ ចំណែកនៅថ្នាក់ខណ្ឌរដ្ឋបាលជលផល តាមការប៉ាន់ស្មានគិតជាមធ្យម ចំពោះខណ្ឌរដ្ឋបាលជលផលចំនួន ១២ នៅក្នុងតំណាក់កាលដំបូង (ប៉ុន្តែនៅពេលខាងមុខអាចមានគ្រប់ខណ្ឌ) នឹងទទួលបានការគាំទ្រដល់មន្ត្រីមូលដ្ឋានចំនួន ៥ ទៅ ៧ រូប។ សេចក្តីលម្អិតមានចែងនៅក្នុងឧបសម្ព័ន្ធ ៥ ។







## ៦.២ ថវិកា និងមូលនិធិ

រាជរដ្ឋាភិបាលនឹងបន្តផ្តល់ថវិកាដោយផ្ទាល់ដល់កម្មវិធីជលផលនៅដំណាក់កាលដំបូងចំនួន ១,២៥ លាន ដុល្លារសហរដ្ឋអាមេរិក សម្រាប់ឆ្នាំ ២០១០។ រាជរដ្ឋាភិបាលមានបំណងនឹងបង្កើនកម្រិតថវិកាបន្ថែមរហូតដល់ ១៥% ក្នុងមួយឆ្នាំៗ ប៉ុន្តែ ដោយសារសម្ពាធនៃព្រឹត្តិការណ៍សេដ្ឋកិច្ចដែលកើតមាននៅចំពេលនៃការរៀបចំក្របខណ្ឌផែនការយុទ្ធសាស្ត្រនេះ ដូច្នេះបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលមិនអាចធានាបាននូវការផ្តល់ថវិកានេះឡើយ។ ហេតុនេះ តាមការព្យាករណ៍នៅក្នុងរយៈពេល ៥ ឆ្នាំ ដំបូង (២០១០-២០១៥) សន្មតថា រាជរដ្ឋាភិបាលពុំមានលទ្ធភាពក្នុងការបង្កើននូវថវិកានេះបានឡើយ។ប៉ុន្តែបន្ទាប់ពីឆ្នាំ២០១៥ទៅថវិកាជាតិនឹងអាចបង្កើនបានចំនួន១៥% ក្នុងមួយឆ្នាំៗ។ តារាងខាងក្រោមនេះគឺសង្ខេបអំពីថវិកាប៉ាន់ស្មានសម្រាប់រយៈពេល ១០ ឆ្នាំ តាមគោលដៅ និងផ្នែកសំខាន់ៗនីមួយៗ។

### តារាងសង្ខេបស្តីពីថវិកាប៉ាន់ស្មានសម្រាប់រយៈពេល ១០ ឆ្នាំ (២០១០-២០១៩)

| | គណនា ២០១០-២០១២ | ប៉ាន់ប្រមាណ ២០១៣-២០១៥ | ប៉ាន់ប្រមាណ ២០១៦-២០១៩ | សរុបរួម |
|---|---|---|---|---|
| **សរុបរួមគិតជាលានដុល្លារសហរដ្ឋអាមេរិក** | ២៥.១៩ | ២៣.១៨ | ៣០.១៨ | ៧៨.៥៥ |
| **គោលដៅគិតជាភាគរយ** | | | | |
| **គោលដៅទី១** : ការរួមចំណែករបស់វិស័យជលផលដល់ការរីកចម្រើនជាតិមានកម្រិតខ្ពស់ និងមានចីរភាព | | | | ២៦% |
| **គោលដៅទី២** : ជីវភាពរស់នៅរបស់ប្រជាជនក្នុងវិស័យនេះកំពុងត្រូវបានធ្វើឱ្យប្រសើរឡើង និងមានកម្រិតខ្ពស់ជាងកម្រិតមធ្យម ដែលបានកំណត់នៅថ្នាក់ជាតិ | | | | ១៤% |
| **គោលដៅទី៣** : ដែននេសាទ និងប្រភពធនធានជលផលផ្សេងទៀតមានលក្ខខណ្ឌល្អ និងមានភាពសមស្រប ហើយអាចត្រូវបានគ្រប់គ្រងប្រកបដោយចីរភាព | | | | ១៨% |
| **គោលដៅទី៤** : ត្រី គឺជាប្រភពនៃចំណីអាហារដ៏សម្បូរបែបមានសុខភាព និងថ្លៃថ្នូរ | | | | ១៨% |
| **គោលដៅទី៥** : មុខជំនួញក្នុងវិស័យនេសាទ គឺមានភាពចំណេញស្ថិរភាព និងមានភាពទទួលខុសត្រូវ | | | | ៦% |
| **គោលដៅទី៦** : ដែននេសាទត្រូវបានគ្រប់គ្រង អភិវឌ្ឍ និងអភិរក្សដោយមានកិច្ចសហប្រតិបត្តិការ យ៉ាងជិតស្និទ្ធជាមួយប្រទេសជិតខាង | | | | ៦% |
| **គោលដៅទី ៧** : បរិយាកាសគោលនយោបាយច្បាប់ និងការជួយគាំទ្រចំពោះវិស័យ គឺមានភាពគ្រប់គ្រាន់សមស្រប និងមានសមត្ថភាពអាចអនុវត្តបាន។ | | | | ១១% |
| **សសរស្តម្ភគិតជាភាគរយ** | | | | |
| **សសរស្តម្ភទី ១** : ជលផលទឹកសាប និងសមុទ្រ | | | | ៤៩% |
| **សសរស្តម្ភទី ២** : វារីវប្បកម្ម | | | | ២១% |
| **សសរស្តម្ភទី ៣** : ការកែច្នៃ និងពាណិជ្ជកម្ម | | | | ៣០% |









រាជរដ្ឋាភិបាលនឹងបន្តស្វែងរកប្រភពថវិកាដើម្បីធានាថា កម្មវិធីនេះនឹងទទួលបានមូលនិធិគ្រប់គ្រាន់។ រាជរដ្ឋាភិបាលទទួលស្គាល់ថា ដៃគូអភិវឌ្ឍន៍ប្រឈមនឹងវិបត្តិសេដ្ឋកិច្ចពិភពលោកដូចគ្នា។ ចំពោះប្រទេសជាតិដែលមានការអភិវឌ្ឍតិចតួច និងមានធនធានបម្រុងតិចតួចសម្រាប់ពឹងអាស្រ័យដូចជាប្រទេសកម្ពុជាគឺទំនងជាទទួលផលប៉ះពាល់យ៉ាងខ្លាំង។

នៅក្នុងរយៈពេលខ្លី និងមធ្យម កម្ពុជានឹងពឹងទៅលើថវិកាដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍នានា។ ទោះបីជាយ៉ាងនេះក្តី នៅពេលដែលផលិតផលជលផលមានការកើនឡើង គួរអនុញ្ញាតឱ្យបង្កើនថ្លៃឈ្នួលអាជីវកម្មដែលបានមកពីវិស័យនេះ។ ការកើនឡើងនៃប្រាក់ចំណូល និងការលូតលាស់ជាទូទៅនៃវិស័យជលផលអាចជួយទ្រទ្រង់ដល់ លទ្ធភាពសេដ្ឋកិច្ចជាទូទៅរបស់រាជរដ្ឋាភិបាលក្នុងការផ្តល់នូវថវិកាសម្រាប់វិស័យជលផល[១៧]។ ទោះបីជាយ៉ាងនេះក្តី ចំណុចជាមូលដ្ឋានសម្រាប់កំណត់នូវកម្រិតប្រាក់ចំណូលពីវិស័យទៅថ្ងៃអនាគត គឺត្រូវធានាថា វាពុំមែនជាបន្ទុកដែលត្រូវដាក់ទៅលើប្រជាពលរដ្ឋនៅក្នុងវិស័យជលផលនោះឡើយ ធ្វើដូច្នេះទើបស្បៀងអាហារ និងសុវត្ថិភាពអាហារូបត្ថម្ភរបស់ប្រជាជនត្រូវបានធានា ភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅក្នុងវិស័យត្រូវបានកាត់បន្ថយ ហើយវិស័យជលផលរួមចំណែកដល់ការលូតលាស់នៃសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព។

## ៦.៣ យន្តការផ្តល់មូលនិធិ

មានការទទួលស្គាល់ថា សេវាកម្មដែលរដ្ឋបាលជលផលថ្នាក់កណ្តាលផ្តល់ទៅឱ្យសហគមន៍មូលដ្ឋានមិនបានគ្រប់គ្រាន់ឡើយ។ ដូច្នេះ ការពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលថ្នាក់ក្រោមជាតិ គឺមានសារៈសំខាន់ចាំបាច់បំផុតពីព្រោះថា មន្ត្រីទាំងនោះមានភារកិច្ចជាអ្នកអនុវត្តដោយផ្ទាល់នៅមូលដ្ឋាន។ ដូច្នេះតួនាទីរបស់រដ្ឋបាលជលផលថ្នាក់កណ្តាល គួរតែផ្តោតការយកចិត្តទុកដាក់ទៅលើការពង្រឹងសមត្ថភាពរបស់មន្ត្រីថ្នាក់ក្រោមជាតិ ហើយតួនាទីនេះ ត្រូវចាត់ទុកដូចជាម៉ាស៊ីន ដើម្បីបើកផ្លូវឆ្ពោះទៅមុខ។ ដើម្បីសម្រេចនូវគោលបំណងនេះ រដ្ឋបាលជលផលចាំបាច់ត្រូវធ្វើប្រតិភូកម្មអំណាច ការទទួលខុសត្រូវ និងតួនាទីនៅក្នុងកម្រិតមួយទៅឱ្យថ្នាក់ក្រោមជាតិ ស្របតាមសមត្ថភាពបច្ចុប្បន្នរបស់មន្ត្រី និងកម្មវិធីកសាងសមត្ថភាពនៅក្នុងវិស័យជលផលរបស់រដ្ឋបាលជលផលទាំងមូល។

ជារួម ការគ្រប់គ្រងថវិកា និងការត្រួតពិនិត្យនឹងត្រូវអនុវត្តដោយរដ្ឋបាលជលផលថ្នាក់កណ្តាល តាមរយៈ នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងសហប្រតិបត្តិការអន្តរជាតិ ដូចបានណែនាំនៅក្នុងនីតិវិធី និងប្រព័ន្ធថវិកា និងផែនការរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

មានលំហូរមូលនិធិពីរយ៉ាងដែលរំពឹងថា នឹងកើតមាននៅក្នុងអំឡុងពេលនៃការអនុវត្តក្របខណ្ឌផែនការយុទ្ធសាស្ត្ររបស់វិស័យជលផលក្នុងរយៈពេល ១០ ឆ្នាំ ខាងមុខនេះ។ ទី១ គឺមូលនិធិផ្តល់ផ្ទាល់ទៅនាយកដ្ឋានពាក់ព័ន្ធនៅរដ្ឋបាលជលផលថ្នាក់កណ្តាល ដើម្បីគាំទ្រដល់ការរៀបចំគោលនយោបាយការណែនាំបច្ចេកទេស និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ ដែលជាមធ្យោបាយនាំផ្លូវដ៏សំខាន់

១៧. ចំណូលពីវិស័យជលផលនឹងត្រូវប្រើប្រាស់ស្របតាមនីតិវិធីនិងបទប្បញ្ញត្តិរបស់រាជរដ្ឋាភិបាល







សម្រាប់ការអភិវឌ្ឍវិស័យជលផល។ ដោយសារសមត្ថភាពជំនាញរបស់មន្ត្រីនៅថ្នាក់ក្រោមជាតិក្នុងការអនុវត្តសកម្មភាពនានាមានកម្រិត នាយកដ្ឋានជំនាញនីមួយៗនៅថ្នាក់កណ្តាលតម្រូវឱ្យជួយដល់ខណ្ឌរដ្ឋបាលជលផលតាមការចាំបាច់។ ដូច្នេះ មូលនិធិមួយចំនួនអាចត្រូវប្រើប្រាស់សម្រាប់កិច្ចការនេះ។ លំហូរមូលនិធិមួយទៀតនឹងត្រូវផ្តល់ផ្ទាល់ទៅថ្នាក់ក្រោមជាតិសម្រាប់ការផ្តល់នូវសេវាកម្មដែលត្រូវផ្សារភ្ជាប់ជាមួយនឹងតម្រូវការឃុំ ស្រុក និងខេត្ត។ ចំនួនទឹកប្រាក់ដែលទំលាក់តាមលំហូរទី ២ សម្រាប់ជលផលថ្នាក់ក្រោមជាតិនឹងត្រូវបង្កើនបន្តិចម្តងៗ ទៅតាមដំណាក់កាលនៅពេលដែលសមត្ថភាពរបស់មន្ត្រីថ្នាក់ក្រោមជាតិមានការកើនឡើង ហើយអាចបង្ហាញឱ្យឃើញពីសមត្ថភាពក្នុងការសម្រេចបាននូវការងារតាមគោលដៅដែលបានឯកភាព។ ដើម្បីសម្រេចបាននូវការងារនេះ រដ្ឋបាលជលផលថ្នាក់កណ្តាលត្រូវអនុវត្តផែនការអភិវឌ្ឍធនធានមនុស្សឱ្យបានសកម្មដល់មន្ត្រីថ្នាក់ក្រោមជាតិទាំងអស់។







# ឧបសម្ព័ន្ធ








២៦ **ឧបសម្ព័ន្ធ១:** សូចនាករ និងចំណុចដៅសម្រាប់ឆ្នាំ ២០១០-២០១៩

៣៧ **ឧបសម្ព័ន្ធ២:** សាវតារនៃក្របខណ្ឌផែនការយុទ្ធសាស្ត្រ

៣៩ **ឧបសម្ព័ន្ធ៣:** លក្ខខណ្ឌយោងសម្រាប់ការអនុវត្តន៍ផែនការខណ្ឌរដ្ឋបាលជលផល និងការសម្របសម្រួល









៤៤ **ឧបសម្ព័ន្ធ៤:** ទំនាក់ទំនងរវាងវិស័យជលផលជាមួយនឹងវិស័យផ្សេងទៀតរបស់រាជរដ្ឋាភិបាល និងសង្គម

៤៥ **ឧបសម្ព័ន្ធ៥:** យុទ្ធសាស្ត្របន្ថែមសម្រាប់វិស័យជលផលកម្ពុជាសម្រាប់ឆ្នាំ ២០១០

៤៩ **ឧបសម្ព័ន្ធ៣:** ថវិកាប៉ាន់ប្រមាណ សេចក្តីសង្ខេបអំពីកញ្ចប់ថវិកាតាមគោលដៅ

# ឧបសម្ព័ន្ធ១: សូចនាករ និងចំណុចដៅសម្រាប់ឆ្នាំ ២០១០-២០១៩

## គោលដៅទី១ : ការរួមចំណែករបស់វិស័យជលផលដល់ការរីកចម្រើនជាតិមានកម្រិតខ្ពស់ និងមានចីរភាព

| សូចនាករ | ឆ្នាំគោល | គិតត្រឹមដំណាច់ឆ្នាំ ២០១២ (៣ឆ្នាំ) | គិតត្រឹមដំណាច់ឆ្នាំ ២០១៥ (៦ឆ្នាំ) | គិតត្រឹមដំណាច់ឆ្នាំ ២០១៩ (១០ឆ្នាំ) |
|---|---|---|---|---|
| ១.១ កម្រិតផលនេសាទ ចាប់បានពីធម្មជាតិ[១៨] | **២០០៨** : មើលលេខយោង[១៩] | ផលនេសាទចាប់បានពីក្នុងធម្មជាតិមានកម្រិតថេរ និងមាននិរន្តរភាពក្នុងកម្រិតមិនលើសពី ៥០០.០០០ តោនក្នុង១ឆ្នាំ | ផលនេសាទចាប់បានពីក្នុងធម្មជាតិមានកម្រិតថេរ និងមាននិរន្តរភាពក្នុងកម្រិតមិនលើសពី ៥០០.០០០ តោនក្នុង១ឆ្នាំ | ផលនេសាទចាប់បានពីក្នុងធម្មជាតិមានកម្រិតថេរ និងមាននិរន្តរភាព ក្នុងកម្រិតមិនលើសពី ៥០០.០០០ តោនក្នុង១ឆ្នាំ |
| ១.២ ផលនេសាទចាប់បានពីវាលស្រែ | ២០០៨ : ១១០.០០០ តោន | ផលនេសាទចាប់បានពីវាលស្រែកើនឡើង ១៥% ក្នុង ១ ឆ្នាំ ស្មើនឹង ១៦៨.០០០តោន | ផលនេសាទចាប់បានពីវាលស្រែកើនឡើង ១៥% ក្នុង១ឆ្នាំ ស្មើនឹង ២៥៥.០០០ តោន | ផលនេសាទចាប់បានពីវាលស្រែកើនឡើង ១៥% ក្នុង១ឆ្នាំ ស្មើនឹង ៥០០.០០០ តោន |
| ១.៣ ចំនួនសហគមន៍ស្រះជម្រកត្រី | ២០០៩ : ២៣៥ | យ៉ាងហោចឃុំចំនួន ៤០០ (២៥% នៃ ចំនួនសរុប) មានស្រះជម្រកត្រីប្រកបដោយនិរន្តរភាព និងប្រសិទ្ធភាព | យ៉ាងហោចឃុំចំនួន ៨០០ (៥០% នៃ ចំនួនសរុប) មានស្រះជម្រកត្រីប្រកបដោយនិរន្តរភាព និងប្រសិទ្ធភាព | យ៉ាងហោចឃុំចំនួន១.២០០ (៧៥% នៃចំនួនសរុប) មានស្រះជម្រកត្រីប្រកបដោយនិរន្តរភាព និងប្រសិទ្ធភាព |
| ១.៤ ការកើនឡើងផលិតផលវារីវប្បកម្មស្របតាមតម្រូវការសន្តិសុខស្បៀង និងការនាំចេញ [២០] | ២០០៨ : ៤០.០០០តោន | ផលិតផលវារីវប្បកម្មកើនឡើង១៥% ក្នុងមួយឆ្នាំៗ ស្មើនឹង ៦៧.០០០ តោន | ផលិតផលវារីវប្បកម្មកើនឡើង១៥% ក្នុងមួយឆ្នាំៗ ស្មើនឹង ១០២.០០០ តោន | ផលិតផលវារីវប្បកម្មកើនឡើង១៥% ក្នុងមួយឆ្នាំៗ ស្មើនឹង ១៨៥.០០០ តោន |
| ១.៥ ចំនួនកសិករដែលបានបណ្តុះបណ្តាល បានចូលរួមយ៉ាងសកម្ម នៅក្នុងសកម្មភាពវារីវប្បកម្ម | ៤៤.០០០ កសិករ | ៥៥.០០០ នាក់ | ៦៥.០០០ នាក់ | ៨៥.០០០ នាក់ |
| ១.៦ កម្រិតនៃផលិតកម្មកូនត្រីពូជសម្រាប់វារីវប្បកម្ម | ២០០៨ : ៣៧.០០០.០០០ក្បាល | ផលិតកម្មកូនត្រីពូជកើនឡើងដល់ ១០០.០០០.០០០ក្បាល ក្នុង១ឆ្នាំៗ | ផលិតកម្មកូនត្រីពូជកើនឡើងដល់ ១៥០.០០០.០០០ ក្បាល ក្នុង១ឆ្នាំៗ | ផលិតកម្មកូនត្រីពូជកើនឡើងដល់ ២៥០.០០០.០០០ ក្បាល ក្នុង១ឆ្នាំៗ |

*១៨. គិតរួមទាំងប្រភេទវារីសត្វផ្សេងទៀត ដូចជាកំពិស ក្តាម ខ្យង កង្កែប ជាដើម ។ល។ ប៉ុន្តែ មិនបានគិតបញ្ចូលផលនេសាទចាប់ពីវាលស្រែឡើយ។*

*១៩. ផ្អែកតាមរបាយការណ៍ផលចាប់ ឡូត៍នេសាទ នេសាទសិប្បកម្ម នេសាទគ្រួសារ និងសមុទ្រ មានចំនួនសរុប ៣២១.០០០ តោន, បើគណនាតាមការប្រើប្រាស់ផលនេសាទ សរុបមានចំនួនប្រមាណ ៦០០.០០០ តោន*

*២០. កម្រិតផលិតផលវារីវប្បកម្មដែលបានមកពីទ្រង់ទ្រាយតូចគឺមានចំនួនមិនតិចជាង ២៥ % ឡើយ*

| គោលដៅទី១ : ការរួមចំណែករបស់វិស័យជលផលដល់ការរីកចម្រើនជាតិមានកម្រិតខ្ពស់ និងមានចីរភាព | | | | |
|---|---|---|---|---|
| **សូចនាករ** | **ឆ្នាំគោល** | **គិតត្រឹមដំណាច់ឆ្នាំ ២០១២ (៣ឆ្នាំ)** | **គិតត្រឹមដំណាច់ឆ្នាំ ២០១៥ (៦ឆ្នាំ)** | **គិតត្រឹមដំណាច់ឆ្នាំ ២០១៩ (១០ឆ្នាំ)** |
| ១.៧ កម្រិតនៃផលិតកម្មចំណីក្នុងស្រុកសម្រាប់វារីវប្បកម្ម | ពុំមានតួលេខ | ការសិក្សាប្រមូលទិន្នន័យឆ្នាំគោលអំពីការប្រើប្រាស់ចំណីសម្រាប់វារីវប្បកម្ម ត្រូវបានធ្វើឡើង ហើយផែនការកាត់បន្ថយការពឹងផ្អែកលើម្សៅត្រី ដោយគ្រោងប្រើប្រាស់ប្រភេទចំណីផ្សំពីប្រូតេអ៊ីនរុក្ខជាតិដែលបានផលិតវិញ | ការប្រើប្រាស់គ្រឿងផ្សំពីបន្លែក្នុងស្រុក នឹងកើនឡើងដល់ ២០% ប្រៀបធៀបនឹងទិន្នន័យឆ្នាំគោល | ការប្រើប្រាស់គ្រឿងផ្សំពីបន្លែក្នុងស្រុកនឹងកើនឡើងដល់ ៦០% ប្រៀបធៀបនឹងទិន្នន័យឆ្នាំគោល |
| ១.៨ ចំនួនសាលារៀនដែលបានចូលរួមយ៉ាងសកម្មក្នុងសកម្មភាពវារីវប្បកម្ម | ២០០៨ : ២៩ | យ៉ាងហោចមានសាលារៀនចំនួន ៦០ មានសកម្មភាពចិញ្ចឹមត្រី ហើយបានបង្រៀនសិស្សានុសិស្សអំពីវារីវប្បកម្ម | យ៉ាងហោចមានសាលារៀនចំនួន ៩០ មានសកម្មភាពចិញ្ចឹមត្រី ហើយបានបង្រៀនសិស្សា នុសិស្សអំពីវារីវប្បកម្ម | យ៉ាងហោចមានសាលារៀនចំនួន ១៤០ មានសកម្មភាពចិញ្ចឹមត្រី ហើយបានបង្រៀនសិស្សានុសិស្ស អំពីវារីវប្បកម្ម |
| ១.៩ កម្រិតផលនេសាទសមុទ្រ | ២០០៨ : ៦៦.០០០តោន | ការប្រមូលទិន្នន័យឆ្នាំគោលអំពីនេសាទសមុទ្រត្រូវបានអនុម័ត និងអនុវត្ត | ផែនការផ្អែកលើមូលដ្ឋានវិទ្យាសាស្ត្រសម្រាប់ធ្វើឱ្យមាននិរន្តរភាពនៃការធ្វើអាជីវកម្មនេសាទ និងការអភិវឌ្ឍវារីវប្បកម្មសមុទ្រត្រូវបានអនុវត្ត | អាជីវកម្មនេសាទសមុទ្រគឺស្ថិតក្នុងកម្រិតថេរ និងមាននិរន្តរភាព ហើយវារីវប្បកម្មសមុទ្រស្ថិតក្នុងភាពរីកលូតលាស់ជាទូទៅ |
| ១.១០ កំណើននៃការនាំចេញផលនេសាទ [២១] | ពុំមានតួលេខ[២២] | សក្តានុពលសម្រាប់ពង្រីកការនាំចេញផលនេសាទធម្មជាតិ និងការចិញ្ចឹម ក៏ដូចជាផលិតផលជលផលផ្សេងទៀតនឹងត្រូវបានធ្វើការវាយតម្លៃពេញលេញ | ផែនការដ៏ទូលំទូលាយសម្រាប់ជំរុញការនាំចេញផលិតផលជលផលនឹងត្រូវបានអនុវត្តពេញលេញ | យ៉ាងហោច ៥០% នៃគោលដៅនៃការនាំចេញនឹងត្រូវសម្រេចបាន |
| ១.១១ កម្រិតនៃផលិតកម្ម និងការនាំចេញស្បែកក្រពើស្របតាមតម្រូវការទីផ្សារ និងក្របខណ្ឌពាណិជ្ជកម្ម | ២០០៩ : ២៦៦ កសិដ្ឋានកំពុងដំណើរការ | ទិន្នន័យឆ្នាំគោលនៃផលិតកម្មក្រពើនិងប្រព័ន្ធផលិតកម្មត្រូវបានប្រមូលចប់សព្វគ្រប់ ហើយផែនការសម្រាប់ផលិតកម្មក្រពើប្រកបដោយនិរន្តរភាពត្រូវបានរៀបចំ | ៧០% នៃកសិដ្ឋានចិញ្ចឹមក្រពើត្រូវបានចុះបញ្ជីថ្នាក់ជាតិ[២៣] និងមានដំណើរការស្របតាមគោលការណ៍និរន្តរភាព[២៤] ហើយការនាំចេញក្រពើរស់ត្រូវបានកាត់បន្ថយចំនួន ៥០% នៃកម្រិតឆ្នាំ២០១២ | ៧០% នៃកសិករចិញ្ចឹមក្រពើអាចនាំចេញស្បែកក្រពើទៅក្នុងទីផ្សារអន្តរជាតិហើយការនាំចេញក្រពើរស់ត្រូវបានបញ្ឈប់ |
| ១.១២ តម្លៃត្រីខាតបង់ដោយសារការថែរក្សា និងការកែច្នៃមិនមានលក្ខណៈសមស្រប | ពុំមានទិន្នន័យ | ទិន្នន័យឆ្នាំគោលអំពីការបាត់បង់តម្លៃ និងគុណភាពត្រីនៅកម្រិតថ្នាក់ជាតិត្រូវបានប្រមូលចប់សព្វគ្រប់ ហើយកម្មវិធីកាត់បន្ថយការបាត់បង់តម្លៃ និងគុណភាពត្រីនឹងត្រូវរៀបចំឡើង | ការខាតបង់តម្លៃ និងគុណភាពត្រីនឹងត្រូវបានកាត់បន្ថយ ២០% ប្រៀបធៀបនឹងកម្រិតឆ្នាំ ២០១១ | ការខាតបង់តម្លៃ និងគុណភាពត្រីនឹងត្រូវបានកាត់បន្ថយ ៥០% ប្រៀបធៀបនឹងកម្រិតឆ្នាំ ២០១១ |
| ១.១៣ កម្រិតចំណូលពីវិស័យជលផលសម្រាប់រាជរដ្ឋាភិបាលប្រើប្រាស់ធ្វើការវិនិយោគការអភិវឌ្ឍជាតិ | ២០០៩ : ១,៧៦ លានដុល្លារ | កម្រិតចំណូលពីវិស័យជលផលបង់ចូលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងកើនឡើង ១៥% ធៀបនឹងទិន្នន័យឆ្នាំគោល | កម្រិតចំណូលពីវិស័យជលផលបង់ចូលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងកើនឡើង ២៥% ធៀបនឹងទិន្នន័យឆ្នាំគោល | កម្រិតចំណូលពីវិស័យជលផលបង់ចូលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងកើនឡើង ៤០% ធៀបនឹងទិន្នន័យឆ្នាំគោល |

២១. រួមទាំងការធ្វើសុខដុមនីយកម្មការនាំចេញ ជាមួយនឹងយុទ្ធសាស្ត្រពាណិជ្ជកម្មបើកទូលាយ
២២. ពុំមានទិន្នន័យជាផ្លូវការ ដូចនេះគឺត្រូវកំណត់នូវវិធីសាស្ត្រដើម្បីប៉ាន់ស្មាន
២.៣ ផ្អែកតាមស្តង់ដារ និងគោលការរបស់អង្គការ សាយតេស
២.៤ ដោយគិតគូដល់និរន្តភាពនៃផលិតកម្មចំណី និងប្រភពសម្រាប់ផលិតចំណី

| គោលដៅទី២ : ជីវភាពរស់នៅរបស់ប្រជាជនក្នុងវិស័យនេះ កំពុងត្រូវបានធ្វើឱ្យប្រសើរឡើង និងមានកម្រិតខ្ពស់ជាងកម្រិតមធ្យមដែលបានកំណត់នៅថ្នាក់ជាតិ | | | | |
|---|---|---|---|---|
| **សូចនាករ** | **ឆ្នាំគោល** | **គិតត្រឹមដំណាច់ឆ្នាំ ២០១២ (៣ឆ្នាំ)** | **គិតត្រឹមដំណាច់ឆ្នាំ ២០១៥ (៦ឆ្នាំ)** | **គិតត្រឹមដំណាច់ឆ្នាំ ២០១៩(១០ឆ្នាំ)** |
| ២.១កម្រិតនៃភាពក្រីក្រក្នុងវិស័យជលផល | ពុំមានទិន្នន័យ | ការធ្វើអង្កេតដើម្បីប្រមូលទិន្នន័យឆ្នាំគោលអំពីភាពក្រីក្រត្រូវបានរៀបចំ អនុម័ត និងអនុវត្ត | គោលដៅនៃកម្មវិធីកាត់បន្ថយភាពក្រីក្រត្រូវបានរៀបចំ និងអនុវត្តយ៉ាងពេញលេញ ហើយចំនួនអ្នកនេសាទ និងអ្នកកែច្នៃត្រីខ្នាតតូចដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ ត្រូវបានកាត់បន្ថយប្រៀបធៀបនឹងទិន្នន័យឆ្នាំគោល[២៥] | ចំនួនអ្នកនេសាទ និងអ្នកកែច្នៃត្រីខ្នាតតូចដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រថ្នាក់ជាតិត្រូវបានកាត់បន្ថយថែមទៀតប្រៀបធៀបនឹងទិន្នន័យឆ្នាំ ២០១៥ |
| ២.២ ការពង្រីកនូវកាលានុវត្តភាពនៃមុខរបរចិញ្ចឹមជីវិតសម្រាប់បង្កើននូវប្រាក់ចំណូលសម្រាប់អ្នកក្រីក្រ និងការលុបបំបាត់នូវភាពងាយរងគ្រោះ ចំពោះកុមារដែលធ្វើការនៅក្នុងវិស័យជលផល | ពុំមានទិន្នន័យ | កាលានុវត្តភាពឧបសគ្គនៃសកម្មភាពរកប្រាក់ចំណូលត្រូវបានកំណត់ហើយកិច្ចអន្តរាគមន៍[២៦] ដើម្បីលុបបំបាត់ភាពរងគ្រោះចំពោះកុមារ និងការធ្វើឱ្យល្អប្រសើរឡើងនូវកាលានុវត្តភាពការងារត្រូវបានអនុវត្តសាកល្បងយ៉ាងហោចណាស់នៅក្នុងសហគមន៍ចំនួន២០[២៧] | កិច្ចអន្តរាគមន៍ដើម្បីធ្វើឱ្យល្អប្រសើរឡើងនូវកាលានុវត្តភាព និងការលុបបំបាត់នូវភាពងាយរងគ្រោះចំពោះកុមារត្រូវបានអនុវត្តសាកល្បង យ៉ាងហោចណាស់នៅក្នុងសហគមន៍ចំនួន៦០ នៅក្នុងខេត្តចំនួន ១៨ | កិច្ចអន្តរាគមន៍ដើម្បីធ្វើឱ្យល្អប្រសើរឡើងនូវកាលានុវត្តភាព និងការលុបបំបាត់ភាពរងគ្រោះចំពោះកុមារត្រូវបានអនុវត្តសាកល្បងយ៉ាងហោចណាស់នៅក្នុងសហគមន៍ចំនួន ១៥០ នៅទូទាំងប្រទេស |
| ២.៣ ចំនួនសហគមន៍នេសាទចុះបញ្ជី និងមានដំណើរការ ប្រកបដោយប្រសិទ្ធភាព[២៨] | ២០០៨ : សហគមន៍នេសាទ ចំនួន ៤៦៨ ត្រូវបានបង្កើតឡើង និងសហគមន៍នេសាទចំនួន ១៧៣ ត្រូវបានចុះបញ្ជី | សហគមន៍នេសាទចំនួន ៣០០ ត្រូវបានចុះបញ្ជីជាផ្លូវការ និងមានដំណើរការប្រកបដោយប្រសិទ្ធភាព | សហគមន៍នេសាទចំនួន ៣៧០ ត្រូវ បានចុះបញ្ជីជាផ្លូវការ និងមានដំណើរការប្រកបដោយប្រសិទ្ធភាព | សហគមន៍នេសាទចំនួន ៤៧០ ត្រូវបានចុះបញ្ជីជាផ្លូវការ និងមានដំណើរការប្រកបដោយប្រសិទ្ធភាព |
| ២.៤ លទ្ធភាពរបស់ស្ត្រីក្នុងការចូលរួមនៅក្នុងសកម្មភាពវិស័យជលផល[២៩] ប្រកបដោយប្រសិទ្ធភាព និងសមធម៌ | ២០០៨ : គោលនយោបាយនិងយុទ្ធសាស្ត្រនៃការ បញ្ជ្រាបយែនឌ័រក្នុងវិស័យជលផលត្រូវបានអនុម័ត | ការចូលរួមដោយស្ត្រីនៅក្នុងសកម្មភាពជលផលនឹងមានការកើនឡើងនៅគ្រប់ផ្នែក | ស្ត្រីអាចប្រើប្រាស់ធនធានជលផលទាំងអស់ និងសេវាកម្ម ហើយអាចចូលរួមក្នុងសកម្មភាពជលផលប្រកបដោយសមធម៌ជាមួយនឹងបុរស | ជីវភាពរស់នៅរបស់ស្ត្រីមានកម្រិតស្មើគ្នាជាមួយនឹងបុរស នៅគ្រប់ផ្នែកនៃវិស័យជលផល |
| ២.៥ កម្រិតនៃទំនាស់នៅក្នុងជលផល | ពុំមានទិន្នន័យ | ប្រភពនៃទំនាស់ត្រូវបានកំណត់ពីលក្ខណៈវិសាលភាព និងបរិមាណ (ដើម្បីផ្តល់ជាទិន្នន័យគោល) ហើយអន្តរាគមន៍កាត់បន្ថយទំនាស់ត្រូវបានរៀបចំឡើង | ចំនួនករណីទំនាស់ធំៗនៅក្នុងវិស័យជលផលតាមរបាយការណ៍ត្រូវបានកាត់បន្ថយនៅត្រឹម ៦០% ប្រៀបធៀបទិន្នន័យឆ្នាំគោល | ចំនួនករណីទំនាស់ធំៗនៅក្នុងវិស័យជលផលតាមរបាយការណ៍ត្រូវបានកាត់បន្ថយនៅត្រឹម ៣០% ប្រៀបធៀបទិន្នន័យឆ្នាំគោល |

២៥. ពុំមានតួលេខជាក់លាក់ដែលអាចកំណត់នូវចំណុចគោលឡើយ ពីព្រោះកម្រិតនៃភាពក្រីក្រគឺពឹងផ្អែកយ៉ាងខ្លាំងទៅលើលក្ខខណ្ឌសេដ្ឋកិច្ចទូទៅ

២៦. កិច្ចអន្តរាគមន៍ទៅលើកម្មវិធីភូមិមួយផលិតផលជលផលមួយ

២៧. សហគមន៍មានន័យថាប្រជាពលរដ្ឋក្នុងភូមិមួយចំនួនរួមគ្នា ឬសមាគម ឬបណ្តាញ

២៨. ការផ្តល់ឱកាសសហគមន៍ក្នុងការពង្រីកមុខរបរចិញ្ចឹមជីវិត រួមទាំងកម្មវិធីភូមិមួយផលិតផលជលផលមួយ

២៩. រួមទាំងការចូលរួមរបស់ស្ត្រីនៅក្នុងគណៈកម្មការសហគមន៍នេសាទ សកម្មភាពវារីវប្បកម្ម កែច្នៃ ភូមិមួយផលិតផលជលផលមួយ

| គោលដៅទី២ : ជីវភាពរស់នៅរបស់ប្រជាជនក្នុងវិស័យនេះ កំពុងត្រូវបានធ្វើឱ្យប្រសើរឡើង និងមានកម្រិតខ្ពស់ជាងកម្រិតមធ្យមដែលបានកំណត់នៅថ្នាក់ជាតិ | | | | |
|---|---|---|---|---|
| សូចនាករ | ឆ្នាំគោល | គិតត្រឹមដំណាច់ឆ្នាំ ២០១២ (៣ឆ្នាំ) | គិតត្រឹមដំណាច់ឆ្នាំ ២០១៥ (៦ឆ្នាំ) | គិតត្រឹមដំណាច់ឆ្នាំ ២០១៩(១០ឆ្នាំ) |
| ២.៦. កម្រិតនៃការនេសាទខុសច្បាប់ | ២០០៨ :<br>១.៩៤៨ ករណី នេសាទខុសច្បាប់ត្រូវបានរាយការណ៍ | កម្មវិធីអប់រំសម្រាប់មន្ត្រី និងប្រជាជននៅមូលដ្ឋានអំពីច្បាប់ ស្តីពីជលផល និងផលប៉ះពាល់នៃការនេសាទបំផ្លិចបំផ្លាញត្រូវបានអនុវត្តនៅទូទាំងប្រទេស | កម្រិតនៃការនេសាទខុសច្បាប់ត្រូវបានកាត់បន្ថយ ២០% ប្រៀបធៀបនឹងទិន្នន័យឆ្នាំគោល | កម្រិតនៃការនេសាទខុសច្បាប់ត្រូវបានកាត់បន្ថយត្រឹម ៤០% ប្រៀបធៀបនឹងទិន្នន័យឆ្នាំគោល |
| ២.៧ ចំនួនប្រពលរដ្ឋ (រួមទាំង ស្ត្រី និងកុមារ) រងការឈឺចាប់ដោយសារការរងរបួស ជំងឺ និងស្លាប់ ដោយធ្វើកិច្ចការនានានៅក្នុងវិស័យជលផល | ពុំមានទិន្នន័យ | ទិន្នន័យឆ្នាំគោលត្រូវបានប្រមូលចប់សព្វគ្រប់ | កម្រិតនៃការរងរបួស ជំងឺ និងការ ស្លាប់ត្រូវបានកាត់បន្ថយ ២០% ប្រៀបធៀបនឹងទិន្នន័យឆ្នាំគោល | កម្រិតនៃការរងរបួស ជំងឺ និងការស្លាប់ត្រូវកាត់បន្ថយត្រឹម ៤០% ប្រៀបធៀបនឹងទិន្នន័យឆ្នាំគោល |

| គោលដៅទី៣ : ដែននេសាទ និងប្រភពធនធានជលផលផ្សេងទៀតមានលក្ខខណ្ឌល្អ និងមានភាពសមស្រប ហើយត្រូវបានគ្រប់គ្រងប្រកបដោយចីរភាព | | | | |
|---|---|---|---|---|
| សូចនាករ | ឆ្នាំគោល | គិតត្រឹមដំណាច់ឆ្នាំ ២០១២ (៣ឆ្នាំ) | គិតត្រឹមដំណាច់ឆ្នាំ ២០១៥ (៦ឆ្នាំ) | គិតត្រឹមដំណាច់ឆ្នាំ ២០១៩(១០ឆ្នាំ) |
| ៣.១ ចំនួនប្រភេទវារិជាត ដែលរងគ្រោះនៅក្នុងប្រទេសកម្ពុជា | ២០០៩ :<br>វារិជាត ៥៨ ប្រភេទ ត្រូវបានចុះក្នុងបញ្ជីជាប្រភេទកំពុងរងគ្រោះនៅក្នុងអនុក្រឹត្យ [៣០] | ចំនួនប្រភេទនៃវារិជាតដែលរងគ្រោះត្រូវបានកាត់បន្ថយត្រឹម ៥៣ ប្រភេទ | ចំនួនប្រភេទនៃវារិជាតដែលកំពុងរងគ្រោះត្រូវបានកាត់បន្ថយត្រឹម ៤៩ ប្រភេទ | ចំនួនប្រភេទនៃវារិជាតដែលរងគ្រោះត្រូវបានកាត់បន្ថយត្រឹម ៤៣ ប្រភេទ |
| ៣.២ ការការពារ និងការគ្រប់គ្រងជម្រកជលផលសំខាន់ៗ [៣១] | ពុំមានទិន្នន័យ | កម្មវិធីធ្វើផែនទីអំពីទីជម្រក កន្លែងពងកូន និងរបាយនៃប្រភេទវារីសត្វពេញមួយឆ្នាំត្រូវបានរៀបចំឡើង និងអនុម័តព្រមទាំងអនុវត្តសាកល្បង | កម្មវិធីធ្វើផែនទីយ៉ាងហោចណាស់សម្រេចបាន៨០% ហើយកិច្ចអន្តរាគមន៍ការពារត្រូវបានអនុវត្តសាកល្បងយ៉ាងហោចណាស់៥០% នៃតំបន់សំខាន់ៗ | កម្មវិធីធ្វើផែនទីត្រូវបានបញ្ចប់ ហើយយ៉ាងហោចណាស់ ៨០% នៃជម្រកសំខាន់ៗ ត្រូវបានការពារ |

៣០. *វិធានការស្តារឡើងវិញត្រូវបានកំណត់នៅក្នុងប្រកាស*
៣១. *រួមមានស្ទឹង បឹង វាលទំនាបលិចទឹក ព្រៃលិចទឹក វាលល្បាប់ និងតំបន់ឆ្នេរ*

| គោលដៅទី៣ : ដែននេសាទ និងប្រភពធនធានជលផលផ្សេងទៀតមានលក្ខខណ្ឌល្អ និងមានភាពសមស្រប ហើយត្រូវបានគ្រប់គ្រងប្រកបដោយចីរភាព | | | | |
|---|---|---|---|---|
| សូចនាករ | ឆ្នាំគោល | គិតត្រឹមដំណាច់ឆ្នាំ ២០១២ (៣ឆ្នាំ) | គិតត្រឹមដំណាច់ឆ្នាំ ២០១៥ (៦ឆ្នាំ) | គិតត្រឹមដំណាច់ឆ្នាំ ២០១៩(១០ឆ្នាំ) |
| ៣.៣ ការធ្វើផែនទីកំណត់ព្រំប្រទល់ និងការការពារ[៣២]ព្រៃលិចទឹក | ២០០៩ : ២.១៥៧ ហិកតា តំបន់ទឹកសាប និង ៣០៧ ហិកតា តំបន់ឆ្នេរត្រូវបានកំណត់ព្រំប្រទល់ | យ៉ាងហោច ២,៥%នៃតំបន់ព្រៃលិចទឹកទឹកសាប និង ៥% នៃតំបន់ព្រៃលិចទឹកតំបន់ឆ្នេរ [៣៣] ត្រូវបានការពារតាមព្រំប្រទល់ដែលបានកំណត់ | យ៉ាងហោច ១០% នៃតំបន់ព្រៃលិចទឹកទឹកសាប និង ២៥% នៃតំបន់ព្រៃលិចទឹកតំបន់ឆ្នេរ ត្រូវបានការពារតាមព្រំប្រទល់ដែលបានកំណត់ | យ៉ាងហោច ៣៥% នៃតំបន់ព្រៃលិចទឹកទឹកសាប និង ៧៥% នៃតំបន់ព្រៃលិចទឹកតំបន់ឆ្នេរ ត្រូវបានការពារតាមព្រំប្រទល់ដែលបានកំណត់ |
| ៣.៤ ការការពារ និងអភិរក្សអន្លង់ជ្រៅៗ នៅតំបន់ទន្លេមេគង្គលើ | ២០០៩ : មានអន្លង់ចំនួន ៥ ក្នុងចំណោមអន្លង់ ៥៧ ត្រូវបានការពារ | អន្លង់ជ្រៅៗចំនួន ១៦ ត្រូវបានការពារ និងអភិរក្សប្រកបដោយប្រសិទ្ធភាព | អន្លង់ជ្រៅៗចំនួន ៣០ ត្រូវបានការពារ និងអភិរក្សប្រកបដោយប្រសិទ្ធភាព | អន្លង់ជ្រៅៗចំនួន ៤០ ត្រូវបានការពារ និងអភិរក្សប្រកបដោយប្រសិទ្ធភាព |
| ៣.៥ ការធ្វើឱ្យប្រសើរឡើងនូវការអភិរក្សជលផលតំបន់បឹងទន្លេសាបតាមរយៈការកំណត់ព្រំប្រទល់ការការពារ និងការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ | ២០០៩ : ២៣.៥៤៤ ហិកតា ត្រូវបានការពារដោយអនុក្រឹត្យ។ បច្ចុប្បន្ន នេះ ៣០% ត្រូវបានការពារ | ៤០% | ៦០% | ៨០% |
| ៣.៦ តំបន់ទីជម្រកជលផលសំខាន់ៗស្ថិតក្រោមការគ្រប់គ្រងប្រកបដោយនិរន្តរភាព | ២០០៩ : ស្មៅសមុទ្រ: ២.៥០០ ហិកតា ផ្កាថ្ម: (គ្មានតួលេខ) ព្រៃកោងកាង: ២០០ ហិកតា | យ៉ាងហោចណាស់ស្មៅសមុទ្រចំនួន ៣.០០០ ហិកតា និងផ្កាថ្មចំនួន ៣០០ ហិកតា ស្ថិតក្រោមក្របខណ្ឌសមស្របនៃការគ្រប់គ្រងប្រកបដោយនិរន្តរភាព និងព្រៃលិចទឹក និងព្រៃកោងកាងចំនួន ៣០០ ហិកតា ត្រូវបានដាំឡើងវិញ | យ៉ាងហោចណាស់ស្មៅសមុទ្រចំនួន៥.០០០ ហិកតា និងផ្កាថ្មចំនួន ៥០០ ហិកតាស្ថិតក្រោមក្របខណ្ឌសមស្របនៃការគ្រប់គ្រងប្រកបដោយនិរន្តរភាព និងព្រៃលិចទឹក និងព្រៃកោងកាងចំនួន ៧០០ ហិកតា ត្រូវបានដាំឡើងវិញ | យ៉ាងហោចណាស់ស្មៅសមុទ្រចំនួន ៧.០០០ ហិកតា និងផ្កាថ្មចំនួន ៨៤០ ហិកតា ស្ថិតក្រោមក្របខណ្ឌសមស្របនៃការគ្រប់គ្រងប្រកបដោយនិរន្តរភាព និងព្រៃលិចទឹក និងព្រៃកោងកាងចំនួន ១.០០០ ហិកតា ត្រូវបានដាំឡើងវិញ |
| ៣.៧ ការកាត់បន្ថយឡូត៍នេសាទសម្រាប់ឱ្យសហគមន៍ប្រើប្រាស់ និងអភិរក្ស | ២០០៩ : ផ្ទៃឡូត៍នេសាទចំនួន ៥៦,៤៦% ត្រូវបានកាត់បន្ថយ | ៥៦.៧៤% នៃផ្ទៃឡូត៍នេសាទត្រូវបានកាត់ចេញ ហើយទុកឱ្យសហគមន៍ប្រើប្រាស់ [៣៤] | ៥៦.៧៤% នៃផ្ទៃឡូត៍នេសាទត្រូវបានកាត់ចេញ ហើយទុកឱ្យសហគមន៍ប្រើប្រាស់ | ៥៦.៧៤% នៃផ្ទៃឡូត៍នេសាទត្រូវបានកាត់ចេញ ហើយទុកឱ្យសហគមន៍ប្រើប្រាស់ |

៣២. នេះគឺជាដំណើរការអនុវត្តសាកល្បង ការរៀបចំផែនទី ការធ្វើនិយ័តកម្ម និងកំណត់ព្រំប្រទល់ដោយមានបោះបង្គោលស៊ីម៉ង់ និងដាក់ស្លាកសញ្ញា

៣៣. ផ្អែកតាមទិន្នន័យឆ្នាំ ២០០៥ ផ្ទៃព្រៃលិចទឹកតំបន់ទឹកសាបចំនួន ៩៣៦.៥៥៤ ហត. និង ព្រៃលិចទឹកតំបន់ឆ្នេរសមុទ្រចំនួន ៦៨.៣៥៧ ហត.

៣៤. ផ្អែកតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរបស់កម្ពុជា និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ

| គោលដៅទី៣ : ដែននេសាទ និងប្រភពធនធានជលផលផ្សេងទៀតមានលក្ខខណ្ឌល្អ និងមានភាពសមស្រប ហើយត្រូវបានគ្រប់គ្រងប្រកបដោយចីរភាព | | | | |
|---|---|---|---|---|
| **សូចនាករ** | **ឆ្នាំគោល** | **គិតត្រឹមដំណាច់ឆ្នាំ ២០១២ (៣ឆ្នាំ)** | **គិតត្រឹមដំណាច់ឆ្នាំ ២០១៥ (៦ឆ្នាំ)** | **គិតត្រឹមដំណាច់ឆ្នាំ ២០១៩(១០ឆ្នាំ)** |
| ៣.៨ ការពង្រឹងសហគមន៍នេសាទ ដើម្បីការគ្រប់គ្រងធនធានធម្មជាតិឱ្យមានប្រសិទ្ធភាព [៣៩] | ២២១ សហគមន៍ ដែលបានចុះបញ្ជីត្រូវបានពង្រឹង | យ៉ាងហោចណាស់ ៧៥% នៃចំនួនសហគមន៍នេសាទដែលបានចុះបញ្ជី ត្រូវបានពង្រឹងពេញលេញ | យ៉ាងហោចណាស់ ៨០% នៃចំនួន សហគមន៍នេសាទដែលបានចុះបញ្ជីត្រូវបានពង្រឹងពេញលេញ | យ៉ាងហោចណាស់ ៩០% នៃចំនួន សហគមន៍នេសាទដែលបានចុះបញ្ជីត្រូវបានពង្រឹងពេញលេញ |
| ៣.៩ ឥទ្ធិពលនៃការធ្វើនិយ័តកម្មនៃកន្លែងការពារជលផលទឹកសាប | ពុំមានទិន្នន័យ | ការអង្កេតដើម្បីប្រមូលទិន្នន័យឆ្នាំគោលអំពីឥទ្ធិពលនៃកន្លែងការពារជលផលទឹកសាបត្រូវបានបញ្ចប់ | ការត្រួតពិនិត្យឥទ្ធិពលនៃលិខិតបទដ្ឋានច្បាប់នៃកន្លែងការពារជលផលទឹកសាបត្រូវបានកែលំអ អនុម័ត និងអនុវត្ត | យ៉ាងហោច ៥០% នៃកន្លែងការពារជលផលទឹកសាបត្រូវបានធ្វើនិយ័តកម្មយ៉ាងសមស្រប និងស្ថិតនៅក្រោមការគ្រប់គ្រងយ៉ាងពេញលេញដោយលិខិតបទដ្ឋានច្បាប់។ |
| ៣.១០ ការអនុវត្តនូវប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃទៅលើអេកូឡូស៊ី ជីវសាស្ត្រដើម្បី ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងធនធានធម្មជាតិ | ២០០៩ :<br>អ្នកនេសាទចំនួន ២០០០នាក់ ត្រូវបាន បណ្តុះបណ្តាលនៅទិសឰសាន នៃប្រទេសកម្ពុជា | យ៉ាងហោចណាស់អ្នកនេសាទចំនួន ១០០០ នាក់ ដែលមានចំណេះដឹង និងមានជំនាញ និងមន្ត្រីរដ្ឋបាលជលផលចំនួន ១២០ នាក់ ត្រូវបានបណ្តុះបណ្តាលអំពីវិធីសាស្ត្រត្រួតពិនិត្យជីវសាស្ត្រអេកូឡូស៊ីរបស់ត្រី | ការត្រួតពិនិត្យជីវសាស្ត្រអេកូឡូស៊ីជលផល និងការវាយតម្លៃប្រព័ន្ធព័ត៌មានត្រូវបានរៀបចំ និងអនុវត្ត | យ៉ាងហោច ៨០% នៃការត្រួតពិនិត្យជីវសាស្ត្រអេកូឡូស៊ីជលផល និងព័ត៌មានវាយតម្លៃ និងទិន្នន័យ ត្រូវបានបញ្ច្រាបយ៉ាងរហ័សទៅដល់អ្នកពាក់ព័ន្ធទាំងអស់ |
| ៣.១១ ទិន្នន័យអំពីឥទ្ធិពលនៃការសាងសង់ទំនប់វារីអគ្គិសនីនៅតំបន់ទន្លេមេគង្គទៅលើវិស័យជលផល | ពុំមានទិន្នន័យ | យ៉ាងហោចណាស់ទិន្នន័យអំពីផលប៉ះពាល់នៃគម្រោងសាងសង់វារីអគ្គិសនីនៅតាមដងទន្លេមេគង្គចំនួន២ដែលបានស្នើឡើង គឺអាចរកបាន | យ៉ាងហោចណាស់ទិន្នន័យអំពីផលប៉ះពាល់នៃគម្រោងសាងសង់វារីអគ្គិសនីនៅតាមដងទន្លេមេគង្គចំនួន ៥ ដែលបានស្នើឡើង គឺអាចរកបាន | យ៉ាងហោចណាស់ទិន្នន័យអំពីផលប៉ះពាល់នៃគម្រោងសាងសង់វារីអគ្គិសនីនៅដងទន្លេមេគង្គចំនួន៩ ដែលបានស្នើឡើងគឺអាចរកបាន |

| គោលដៅទី៤ : ត្រីគឺជាប្រភពនៃចំណីអាហារដ៏សម្បូរបែប មានសុខភាព និងថ្លៃថ្នូរ | | | | |
|---|---|---|---|---|
| **សូចនាករ** | **ឆ្នាំគោល** | **គិតត្រឹមដំណាច់ឆ្នាំ ២០១២ (៣ឆ្នាំ)** | **គិតត្រឹមដំណាច់ឆ្នាំ ២០១៥ (៦ឆ្នាំ)** | **គិតត្រឹមដំណាច់ឆ្នាំ ២០១៩(១០ឆ្នាំ)** |
| ៤.១ បរិមាណត្រីដែលមានសម្រាប់បរិភោគនៅទូទាំងប្រទេស | ២០០៧ :<br>៥២,៤ គក្រ/នាក់/ឆ្នាំ | បរិមាណត្រីដែលប្រជាជនបរិភោគគិតជាមធ្យមក្នុងម្នាក់ក្នុង១ ឆ្នាំនៅថ្នាក់ជាតិយ៉ាងហោចណាស់អាចរក្សាបាននៅត្រឹមកម្រិតឆ្នាំ ២០០៧ | បរិមាណត្រីដែលប្រជាជនបរិភោគគិតជាមធ្យមក្នុងម្នាក់ក្នុង ១ ឆ្នាំ នៅថ្នាក់ជាតិយ៉ាងហោចណាស់អាចរក្សាបាននៅត្រឹមកម្រិតឆ្នាំ ២០០៧ | បរិមាណត្រីដែលប្រជាជនបរិភោគគិតជាមធ្យមក្នុងម្នាក់ក្នុង១ ឆ្នាំនៅថ្នាក់ជាតិយ៉ាងហោចណាស់អាច រក្សាបាននៅត្រឹមកម្រិតឆ្នាំ ២០០៧ |
| ៤.២ ការរួមចំណែកនៃត្រីក្នុងសន្តិសុខអាហារូបត្ថម្ភជាតិ និងសុខភាព | ២០០៩ : ទិន្នន័យអំពីអាហារ រូបត្ថម្ភអាចរៀបចំបាន | ការអង្កេតដើម្បីប្រមូលទិន្នន័យឆ្នាំគោលត្រូវបានរៀបចំចងក្រងឡើងដើម្បីផ្តល់នូវព័ត៌មានអំពីការកែច្នៃ និងការប្រើប្រាស់ត្រី និងធនធានវារីសត្វផ្សេងទៀតសម្រាប់ប្រជាជនគ្រប់រូប ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រថ្នាក់ជាតិស្តីពីការធ្វើឱ្យល្អប្រសើរឡើងនូវអាហារូបត្ថម្ភសម្រាប់មនុស្ស | គោលដៅជាក់លាក់ត្រូវបានកំណត់ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រថ្នាក់ជាតិ | គោលដៅជាក់លាក់ត្រូវបានកំណត់ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រ ថ្នាក់ជាតិ |

៣៩. *ការពង្រឹងសហគមន៍នេសាទរួមមានការកំណត់ព្រំប្រទល់សហគមន៍នេសាទ ការបង្កើតតំបន់អភិរក្ស ការយាមល្បាត និងការកសាងបណ្តាញ។*

| គោលដៅទី៤ : ត្រីគឺជាប្រភពនៃចំណីអាហារដ៏សម្បូរបែប មានសុខភាព និងថ្លៃថ្នូរ | | | | |
|---|---|---|---|---|
| **សូចនាករ** | **ឆ្នាំគោល** | **គិតត្រឹមដំណាច់ឆ្នាំ ២០១២ (៣ឆ្នាំ)** | **គិតត្រឹមដំណាច់ឆ្នាំ ២០១៥ (៦ឆ្នាំ)** | **គិតត្រឹមដំណាច់ឆ្នាំ ២០១៩(១០ឆ្នាំ)** |
| ៤.៣ តម្លៃបន្ថែមទៅលើផលិតផលក្នុងស្រុកតាមរយៈការធ្វើឱ្យប្រសើរឡើងនូវការកែច្នៃ និងគុណភាព ការវេចខ្ចប់ និងការធានាបាននូវសុវត្ថិភាព | ពុំមានទិន្នន័យ | កិច្ចអន្តរាគមន៍ [៣៦] ដែលអាចធ្វើឱ្យប្រសើរឡើងនូវការកែច្នៃ និងគុណភាព ការវេចខ្ចប់ និងការធានាសុវត្ថិភាពត្រូវបានអនុវត្តសាកល្បងយ៉ាងហោចណាស់នៅក្នុងសហគមន៍ចំនួន ២០ [៣៧] | កិច្ចអន្តរាគមន៍ដែលអាចធ្វើឱ្យប្រសើរឡើងនូវការកែច្នៃ និងគុណភាព ការវេចខ្ចប់ និងការធានាសុវត្ថិភាព ត្រូវបានអនុវត្តសាកល្បងយ៉ាងហោចណាស់នៅក្នុងសហគមន៍ចំនួន ៦០ នៅក្នុងខេត្តចំនួន ១៨ | កិច្ចអន្តរាគមន៍ដែលអាចធ្វើឱ្យប្រសើរឡើងនូវការកែច្នៃ និងគុណភាព ការវេចខ្ចប់ និងការធានាសុវត្ថិភាព ត្រូវបានអនុវត្តសាកល្បងយ៉ាងហោចណាស់នៅក្នុងសហគមន៍ចំនួន ១៥០ នៅទូទាំងប្រទេស |
| ៤.៤ ស្តង់ដារកែច្នៃត្រី និងការថែរក្សាដែលធានាបាននូវគុណភាពសុវត្ថិភាព និងការប្រើប្រាស់ជាតិគីមី | ២០០៩ :<br>ទិន្នន័យបច្ចេកទេស ត្រូវបានប្រមូល និងការបណ្តុះបណ្តាល ត្រូវបានធ្វើឡើង | • ស្តង់ដារថ្នាក់ជាតិសម្រាប់ការកែច្នៃត្រីត្រូវបានបោះពុម្ព<br>• កម្មវិធីផ្ទេរចំណេះដឹងសម្រាប់អ្នកកែច្នៃត្រីត្រូវបានរៀបចំ<br>• ៣០% នៃអ្នកកែច្នៃត្រីជាទ្រង់ទ្រាយធំ និងមធ្យម មានសមត្ថភាពផលិតតាមស្តង់ដារ និងមានអនាម័យ | • ៥០% នៃអ្នកកែច្នៃត្រីទាំងអស់បានអនុវត្តតាមវិធានការត្រួតពិនិត្យគុណភាព និងសុវត្ថិភាព<br>• ៥០% នៃផលិតផលត្រីដែលត្រូវបានផលិត គឺស្របទៅតាមស្តង់ដារគុណភាព និងសុវត្ថិភាព | • ៨០% នៃអ្នកកែច្នៃត្រីទាំងអស់បានអនុវត្តតាមវិធានការត្រួតពិនិត្យគុណភាព និងសុវត្ថិភាព<br>• ៨០% នៃផលិតផលត្រីដែលត្រូវបានផលិត គឺស្របទៅតាមបទដ្ឋាន ស្តង់ដារ គុណភាព និងសុវត្ថិភាព |
| ៤.៥ ប្រសិទ្ធភាពនៃការត្រួតពិនិត្យគុណភាពត្រីកែច្នៃស្របតាមស្តង់ដារអន្តរជាតិ | ពុំមានទិន្នន័យ | ២០% នៃសិប្បកម្មមានសម្ភារៈកែច្នៃ ត្រូវបានចុះបញ្ជីផ្លូវការ និងត្រួតពិនិត្យ ដោយផ្អែកទៅលើ:<br>• សមត្ថភាពធនធានមនុស្ស<br>• ការរៀបចំក្របខណ្ឌច្បាប់<br>• ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ | ៥០% នៃសិប្បកម្មមានសម្ភារៈកែច្នៃ ត្រូវបានចុះបញ្ជីផ្លូវការ និងធ្វើការត្រួតពិនិត្យ | ៨០% នៃសិប្បកម្មមានសម្ភារៈកែច្នៃ ត្រូវបានចុះបញ្ជីផ្លូវការ និងធ្វើការត្រួតពិនិត្យ |
| ៤.៦ ការផ្សព្វផ្សាយ និងការបញ្ជូនព័ត៌មាន និងបច្ចេកវិទ្យាកែច្នៃជលផលទៅដល់អ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់ | ពុំមានទិន្នន័យ | ទិន្នន័យអំពី:<br>• ការធានារ៉ាប់រងគុណភាព<br>• ស្តង់ដារសុវត្ថិភាព<br>• ទីផ្សារ<br>• បច្ចេកវិទ្យាកែច្នៃជលផល និងប្រធានបទពាក់ព័ន្ធផ្សេងទៀត ត្រូវបានបង្កើតឡើង ហើយអាចប្រើប្រាស់បាន | ការអនុវត្តសាកល្បងអំពីការផ្ទេរបច្ចេកវិទ្យា ការលើកកម្ពស់ប្រសិទ្ធភាពបច្ចេកទេសកែច្នៃ ត្រូវបានធ្វើឡើង | ប្រព័ន្ធព័ត៌មានអំពីការកែច្នៃ និងការគាំទ្របច្ចេកវិទ្យា ត្រូវបានរៀបចំឡើងពេញលេញសម្រាប់អ្នកពាក់ព័ន្ធទាំងអស់ |
| ៤.៧ សមត្ថភាពរបស់រដ្ឋបាលជលផល និងកសិករចិញ្ចឹមត្រីក្នុងការគ្រប់គ្រងសុខភាព និងជំងឺត្រី | ពុំមានទិន្នន័យ | យ៉ាងហោចណាស់កសិករចិញ្ចឹមត្រីចំនួន ១៥០០នាក់ និងមន្ត្រីរដ្ឋបាលជលផលចំនួន ៤៥ នាក់ បានទទួលវគ្គបណ្តុះបណ្តាលអំពីសុខភាព និងជំងឺត្រី។ | ប្រព័ន្ធតាមដាន និងត្រួតពិនិត្យអំពីជំងឺត្រីត្រូវបានរៀបចំ និងអនុវត្ត | ប្រព័ន្ធទិន្នន័យអំពីជំងឺត្រីថ្នាក់ជាតិ ត្រូវបានរៀបចំ និងចែករំលែក |

៣៦. *កិច្ចអន្តរាគមន៍ទៅលើកម្មវិធីភូមិមួយផលិតផលជលផលមួយ*

៣៧. *សហគមន៍រួមមានប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិមួយ ឬច្រើន ឬសមាគម ឬបណ្តាញ*

| គោលដៅទី៥ : មុខជំនួញក្នុងរបរនេសាទ គឺមានភាពចំណេញ ស្ថេរភាព និងមានភាពទទួលខុសត្រូវ | | | | |
|---|---|---|---|---|
| **សូចនាករ** | **ឆ្នាំគោល** | **គិតត្រឹមដំណាច់ឆ្នាំ ២០១២ (៣ឆ្នាំ)** | **គិតត្រឹមដំណាច់ឆ្នាំ ២០១៥ (៦ឆ្នាំ)** | **គិតត្រឹមដំណាច់ឆ្នាំ ២០១៩(១០ឆ្នាំ)** |
| ៥.១ កម្រិតផលនេសាទចាប់បានពីឡូត៍នេសាទ | ២០០៨ : ១១៥.០០០តោន | ទិន្នន័យឆ្នាំគោលអំពីឧបករណ៍នេសាទស្របច្បាប់ និងការអនុវត្ត ត្រូវបានរៀបចំចប់សព្វគ្រប់ ហើយផែនការស្ដីពីនិរន្តរភាព និងការទទួលខុសត្រូវធ្វើអាជីវកម្មឡូត៍នេសាទត្រូវបានរៀបចំឡើង | ផលនេសាទចាប់បានពីឡូត៍នេសាទត្រូវបានរក្សាក្នុងកម្រិតមួយដែលធានានូវនិរន្តរភាពហើយប្រព័ន្ធតាមដានត្រូវបានបង្កើតឡើង | ផលនេសាទចាប់ពីឡូត៍នេសាទត្រូវបានរក្សាក្នុងកម្រិតមួយដែលធានានូវនិរន្តរភាពហើយកម្មវិធីលើកកម្ពស់គុណភាពត្រូវបានបង្កើតឡើង |
| ៥.២ ច្បាប់ និងការប្រើប្រាស់ឧបករណ៍នេសាទ និងវិធីសាស្ត្រធានានិរន្តរភាព និងការទទួលខុសត្រូវលើការប្រើប្រាស់ធនធាន | ពុំមានទិន្នន័យ | ការធ្វើអង្កេតដើម្បីប្រមូលទិន្នន័យឆ្នាំគោលអំពីប្រសិទ្ធភាព ភាពស័ក្តសិទ្ធិ និងឥទ្ធិពលនៃឧបករណ៍នេសាទត្រូវបានធ្វើឡើង | ប្រកាសស្ដីពីឧបករណ៍នេសាទត្រូវបានរៀប ចំឡើង អនុម័ត និងអនុវត្ត | យ៉ាងហោចណាស់ ៣០% នៃសកម្មភាពនេសាទទឹកសាបត្រូវបានអនុវត្តពេញពេញតាមច្បាប់ |
| ៥.៣ ការបង្កើតនិងរៀបចំសមាជិកនៃសហគមន៍កសិករក្នុងវិស័យ [៣៨] | ២០០៩ : សហគមន៍កសិករចំនួន៤ នៅក្នុង ៣ខេត្ត ត្រូវបានបង្កើតឡើង | សហគមន៍អ្នកកែច្នៃត្រីត្រូវបានបង្កើតឡើងនៅក្នុងខេត្តគោលដៅចំនួន៩ | សហគមន៍អ្នកកែច្នៃត្រីត្រូវបានបង្កើតឡើងនៅគ្រប់ខេត្ត ហើយផែនការ ត្រូវបានរៀបចំឡើងដើម្បីរៀបចំសមាគមដទៃទៀត | សហគមន៍កសិករត្រូវបានបង្កើតឡើងហើយអាចទទួលបាននូវប្រាក់កម្ចី និងមានទីផ្សារ |
| ៥.៤ ការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងរវាងទីផ្សារ និង ផលិតផល និងសេវាកម្មនៅថ្នាក់សហគមន៍ [៣៩] | ពុំមានទិន្នន័យ | ការវិភាគតម្លៃសង្វាក់ផលិតកម្មយ៉ាងហោចណាស់ត្រូវបានធ្វើឡើងចំពោះផលិតផល ចំនួន ៥ មុខ [៤០] | ផលិតផលចំនួន ១០ មុខ និងសេវាកម្ម ស្របតាមតម្រូវការទីផ្សារក្នុងស្រុកត្រូវបានផលិតឡើង និងនាំយកទៅកាន់ទីផ្សារ | ផលិតផលចំនួន ១០ មុខ និងសេវាកម្មស្របតាមតម្រូវការទីផ្សារក្នុងស្រុកត្រូវបានផលិតឡើង និង នាំយកទៅកាន់ទីផ្សារ |

៣៨. សមាគមកែច្នៃ ចិញ្ចឹមលក់ សមាគមអ្នកទីផ្សារ សមាគមអ្នកនេសាទ សមាគមភ្ញាស់កូនត្រី (រួមបញ្ចូលទាំងសមាគមភូមិមួយផលិតផលជលផលមួយ)

៣៩. សហគមន៍រួមមានប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិមួយ ឬច្រើន ឬសមាគម ឬបណ្ដាញ

៤០. ផលិតផលរបស់ភូមិមួយផលិតផលជលផលមួយ

## គោលដៅទី៦ ៖ ដែនទេសាទត្រូវបានគ្រប់គ្រង អភិវឌ្ឍ និងអភិរក្សដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយប្រទេសជិតខាង

| សូចនាករ | ឆ្នាំគោល | គិតត្រឹមដំណាច់ឆ្នាំ ២០១២ (៣ឆ្នាំ) | គិតត្រឹមដំណាច់ឆ្នាំ ២០១៥ (៦ឆ្នាំ) | គិតត្រឹមដំណាច់ឆ្នាំ ២០១៩ (១០ឆ្នាំ) |
|---|---|---|---|---|
| ៦.១ ប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការក្នុងតំបន់ ដើម្បីដោះស្រាយបញ្ហាអន្តរជាតិទាក់ទងនឹងជលផល | ពុំមានទិន្នន័យ | ផែនការសម្រាប់កិច្ចសហប្រតិបត្តិការក្នុងតំបន់ ដើម្បីដោះស្រាយនូវបញ្ហាអន្តរជាតិដែលវិស័យជលផលជួបប្រទះនៅក្នុងប្រទេសកម្ពុជា រួមមាន បញ្ហាការប្រែប្រួលអាកាសធាតុ ការធ្វើទំនប់ ការរិចរិលនៃបរិស្ថានត្រូវបានរៀបចំឡើង | យ៉ាងហោចណាស់ចំណុចគោលសំខាន់ៗចំនួន ២០% នៅក្នុងផែនការសម្រាប់កិច្ចសហប្រតិបត្តិក្នុងតំបន់ត្រូវបានរៀបចំឡើងចប់សព្វគ្រប់ | យ៉ាងហោចណាស់ចំណុចដៅសំខាន់ៗចំនួន ៥០% នៅក្នុងផែនការសម្រាប់កិច្ចសហប្រតិបត្តិក្នុងតំបន់ត្រូវបានរៀបចំឡើងចប់សព្វគ្រប់ |
| ៦.២ ការបង្កើត និងដំណើរការប្រព័ន្ធគ្រប់គ្រងឆ្លងព្រំដែនសម្រាប់ផលស្តុកត្រី និងជម្រកសំខាន់ៗ | ពុំមានទិន្នន័យ | ទិន្នន័យឆ្នាំគោលអំពីការគ្រប់គ្រងធនធានជលផលឆ្លងដែនត្រូវបានអនុវត្ត ហើយផែនការសម្រាប់ការបន្សាំទៅនឹងថ្នាក់តំបន់ត្រូវបានអនុវត្ត។ | យ៉ាងហោចណាស់ចំណុចដៅសំខាន់ៗ ប្រមាណ ២០% ត្រូវបានបំពេញ | យ៉ាងហោចណាស់ចំណុចគោលសំខាន់ៗប្រមាណ ៥០% ត្រូវបានបំពេញ |

## គោលដៅទី៧ ៖ បរិយាកាសគោលនយោបាយ ច្បាប់ និងការជួយគាំទ្រចំពោះវិស័យ គឺមានភាពគ្រប់គ្រាន់ សមស្រប និងមានសមត្ថភាពអាចអនុវត្តបាន

| សូចនាករ | ឆ្នាំគោល | គិតត្រឹមដំណាច់ឆ្នាំ ២០១២ (៣ឆ្នាំ) | គិតត្រឹមដំណាច់ឆ្នាំ ២០១៥ (៦ឆ្នាំ) | គិតត្រឹមដំណាច់ឆ្នាំ ២០១៩ (១០ឆ្នាំ) |
|---|---|---|---|---|
| ៧.១ ការធ្វើសុខដុមនីយកម្ម នៃគោលដៅគោលនយោបាយ និងផែនការរបស់វិស័យជលផលជាមួយនឹងវិស័យផ្សេងទៀតរបស់រាជរដ្ឋាភិបាលដែលប្រើប្រាស់ធនធានទឹក | ពុំមានទិន្នន័យ | កម្មវិធីធ្វើសុខដុមនីយកម្មអន្តរវិស័យរួមមានការដាក់បញ្ចូលបញ្ហាវិស័យជលផលនៅក្នុងផែនការការបន្សាំទៅនឹងបម្រែបម្រួលអាកាសធាតុត្រូវបានរៀបចំឡើង | ដំណើរការធ្វើសុខដុមនីយកម្មនៃគោលដៅគោលនយោបាយ និងផែនការអន្តរវិស័យរវាងស្ថាប័នរបស់រាជរដ្ឋាភិបាលនានាត្រូវបានរៀបចំ និងអនុវត្ត | យ៉ាងហោចណាស់សូចនាករសម្រាប់កម្មវិធីសុខដុមនីយកម្មប្រមាណ ៥០% ត្រូវបានសម្រេច |
| ៧.២ កម្រិតនៃការអនុវត្តកាំកូដ ដោយដៃគូអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា | ២០០៩ ៖ សេចក្តីព្រាងចុងក្រោយនៃកាំកូដត្រូវបានរៀបចំរួច | គោលការណ៍ណែនាំបច្ចេកទេសលើការអនុវត្តកាំកូដ ត្រូវបានរៀបចំ | ការវាយតម្លៃអំពីការប្រើប្រាស់សាកល្បងកាំកូដ ត្រូវបានអនុវត្តតាមរយៈក្រុមការងារបច្ចេកទេសចម្រុះស្តីពីកំណែទម្រង់នេសាទ ហើយកាំកូដត្រូវបានកែសម្រួលឡើងវិញ | ការវាយតម្លៃអំពីការប្រើប្រាស់ពេញលេញនូវកាំកូដត្រូវបានអនុវត្តតាមរយៈក្រុមការងារបច្ចេកទេសចម្រុះស្តីពីកំណែទម្រង់នេសាទ |
| ៧.៣ កម្រិតនៃការសម្រេចបានផ្អែកតាមសូចនាករតាមដានរួម | ២០០៩ ៖ ៨០% | យ៉ាងហោចណាស់ ៨០% នៃសូចនាករតាមដានរួមប្រចាំឆ្នាំត្រូវសម្រេចបានតាមគោលដៅកំណត់ | យ៉ាងហោចណាស់ ៨០% នៃសូចនាករតាមដានរួមប្រចាំឆ្នាំ ត្រូវសម្រេចបានតាមគោលដៅកំណត់ | យ៉ាងហោចណាស់ ៨០% នៃសូចនាករតាមដានរួមប្រចាំឆ្នាំ ត្រូវសម្រេចបានតាមគោលដៅកំណត់ |

| គោលដៅទី៧ : បរិយាកាសគោលនយោបាយ ច្បាប់ និងការជួយគាំទ្រចំពោះវិស័យ គឺមានភាពគ្រប់គ្រាន់ សមស្រប និងមានសមត្ថភាពអាចអនុវត្តបាន | | | | |
|---|---|---|---|---|
| សូចនាករ | ឆ្នាំគោល | គិតត្រឹមដំណាច់ឆ្នាំ ២០១២ (៣ឆ្នាំ) | គិតត្រឹមដំណាច់ឆ្នាំ ២០១៥ (៦ឆ្នាំ) | គិតត្រឹមដំណាច់ឆ្នាំ ២០១៩(១០ឆ្នាំ) |
| ៧.៤ ការប្រគល់អំណាច និងការទទួលខុសត្រូវស្របនឹងផែនការវិមជ្ឈការ និងវិសហមជ្ឈការថ្នាក់ជាតិ [៤១] | ពុំមានទិន្នន័យ | នីតិវិធីប្រតិបត្តិនៃដំណើរការ និងប្រព័ន្ធគ្រប់គ្រងសម្រាប់ស្ថាប័នថ្នាក់ក្រោមជាតិត្រូវបានរៀបចំឡើង | យ៉ាងហោចណាស់ ៦០% នៃមន្ត្រីនៅថ្នាក់ក្រោមជាតិត្រូវបានទទួលការបណ្តុះបណ្តាលពេញលេញ ហើយយ៉ាងហោចណាស់ ៣០% នៃស្ថាប័នថ្នាក់ក្រោមជាតិសង្ឃឹមថានឹងមានការទទួលខុសត្រូវ | ការទទួលខុសត្រូវពេញលេញ និងសិទ្ធិអំណាចត្រូវបានផ្ទេរទៅស្ថាប័នថ្នាក់ក្រោមជាតិទាំងអស់ |
| ៧.៥ ការរៀបចំ និងអនុវត្តផែនការខណ្ឌរដ្ឋបាលជលផលឆ្លើយតបទៅនឹងផែនការឃុំ សង្កាត់ និងស្របជាមួយនឹងគោលនយោបាយវិស័យជលផល | ២០០៩ : ដំណើរការផែនការ ខណ្ឌត្រូវបានអនុវត្តសាកល្បង | ដំណើរការធ្វើផែនការខណ្ឌរដ្ឋបាលជលផលត្រូវបានអនុវត្តពេញលេញ យ៉ាងហោចណាស់នៅក្នុងខេត្ត ចំនួន ៩ | យ៉ាងហោចណាស់ ៥០% នៃផែនការខណ្ឌរដ្ឋបាលជលផល គឺមានភាពស៊ីសង្វាក់ជាមួយនឹងគោលនយោបាយរបស់វិស័យជលផល និងផែនការអភិវឌ្ឍឃុំ សង្កាត់ ព្រមទាំងផែនការថ្នាក់ក្រោមជាតិផ្សេងទៀត | ផែនការខណ្ឌរដ្ឋបាលជលផលទាំងអស់ គឺមានភាពស៊ីសង្វាក់ជាមួយ នឹងគោលនយោបាយរបស់វិស័យជលផល និងផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់ ព្រមទាំងផែនការថ្នាក់ក្រោមជាតិផ្សេងទៀត |
| ៧.៦ ការប្រើប្រាស់វិធីសាស្ត្រនៃការចូលរួមដែលជាផ្នែកមួយនៃដំណើរការសមាហរណកម្មគោលនយោបាយ ការធ្វើផែនការ និងការពិនិត្យមើលឡើងវិញ | ២០០៩ : ដំណើរការវាយតម្លៃអំពីផលប៉ះពាល់នៃគោលនយោបាយដោយមានការចូលរួមត្រូវបានអនុវត្ត និង ប្រើប្រាស់ជាប្រចាំ | ការវាយតម្លៃអំពីផលប៉ះពាល់នៃគោលនយោបាយដោយមានការចូលរួមត្រូវបានធ្វើឡើងប្រចាំឆ្នាំ ហើយលទ្ធផលនៃការវាយតម្លៃនេះត្រូវបានបញ្ចូលជាផ្លូវការទៅក្នុងដំណើរការរៀបចំផែនការវិស័យជលផល | ការវាយតម្លៃអំពីផលប៉ះពាល់នៃគោលនយោបាយយ៉ាងហោចណាស់ចំនួនមួយត្រូវបានធ្វើឡើងប្រចាំឆ្នាំ ហើយលទ្ធផលនៃការវាយតម្លៃត្រូវបានបញ្ចូលនៅក្នុងការរៀបចំគោលនយោបាយ និងដំណើរការរៀបចំផែនការ | ការវាយតម្លៃដោយមានការចូលរួមត្រូវបានប្រើប្រាស់ជាផ្លូវការក្នុងការគាំទ្រដល់គ្រប់ដំណើរការអនុវត្តច្បាប់ការធ្វើនិយ័តកម្មការរៀបចំផែនការសម្រាប់វិស័យជលផល គិតត្រឹមដំណាច់ឆ្នាំ ២០១៩ |
| ៧.៧ កម្រិតនៃការយល់ឃើញជាវិជ្ជមានរបស់សហគមន៍នេសាទ និងប្រជាជនទូទៅពាក់ព័ន្ធនឹងប្រសិទ្ធភាព នៃគោលនយោបាយជលផលផែនការ និងការផ្តល់សេវាកម្ម | ពុំមានទិន្នន័យ | យ៉ាងហោចណាស់ ៤០% នៃប្រជាជននៅក្នុងសហគមន៍នេសាទ និងប្រជាជនទូទៅមានការឆ្លើយតបជាវិជ្ជមានទៅនឹងគោលនយោបាយអភិវឌ្ឍវិស័យជលផល | យ៉ាងហោចណាស់ ៦០% នៃប្រជាជននៅក្នុងសហគមន៍នេសាទ និងប្រជាជនទូទៅមានការឆ្លើយតបជាវិជ្ជមានទៅនឹងគោលនយោបាយអភិវឌ្ឍវិស័យជលផល | យ៉ាងហោចណាស់ ៧០% នៃប្រជាជននៅក្នុងសហគមន៍នេសាទ និងប្រជាជនទូទៅមានការឆ្លើយតបជាវិជ្ជមានទៅនឹងគោលនយោបាយអភិវឌ្ឍវិស័យជលផល |
| ៧.៨ ការអនុវត្តក្របខណ្ឌនៃលិខិតបទដ្ឋានច្បាប់ក្នុងការគាំទ្រអភិបាលកិច្ចល្អ និងការរៀបចំអនុវិស័យ [៤២] | ពុំមានទិន្នន័យ | លិខិតបទដ្ឋានច្បាប់សម្រាប់ឧបករណ៍នេសាទ និងវារីវប្បកម្មត្រូវបានរៀបចំឡើង និងអនុវត្តហើយបទដ្ឋានច្បាប់សម្រាប់ការវាស់វែង[៤៣] ត្រូវបានព្រាងឡើង | បទដ្ឋានច្បាប់សម្រាប់ការវាស់វែងត្រូវបានអនុវត្ត និងយ៉ាងហោចណាស់ ៦០% ឬគ្រប់បទដ្ឋានច្បាប់ដែលចាំបាច់ត្រូវបានព្រាងឡើង | បទដ្ឋានច្បាប់សម្រាប់គ្រប់អនុវិស័យនៃវិស័យជលផលត្រូវបានរៀបចំឡើង និងអនុវត្ត |

៤១. *គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ*

៤២. *មានច្រើនអនុវិស័យរួមមាន: ការនេសាទ វារីវប្បកម្ម ប្រព័ន្ធអេកូឡូស៊ី ការអភិរក្ស និងការគ្រប់គ្រងជលស្តុក ការកែច្នៃ ការដឹកជញ្ជូន និងនាំចេញ ។ ក្រៅពីនេះនៅមានការគាំទ្រដល់ការអនុវត្តច្បាប់ដូចជាច្បាប់ប្រឆាំងនឹងអំពើពុករលួយ។*

៤៣. *វិធានការការពារអនាម័យ*

## គោលដៅទី៧ : បរិយាកាសគោលនយោបាយ ច្បាប់ និងការជួយគាំទ្រចំពោះវិស័យ គឺមានភាពគ្រប់គ្រាន់ សមស្រប និងមានសមត្ថភាពអាចអនុវត្តបាន

| សូចនាករ | ឆ្នាំគោល | គិតត្រឹមដំណាច់ឆ្នាំ ២០១២ (៣ឆ្នាំ) | គិតត្រឹមដំណាច់ឆ្នាំ ២០១៥ (៦ឆ្នាំ) | គិតត្រឹមដំណាច់ឆ្នាំ ២០១៩(១០ឆ្នាំ) |
|---|---|---|---|---|
| ៧.៩ ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ | ពុំមានទិន្នន័យ | កម្មវិធីជំរុញការអនុវត្តច្បាប់ត្រូវបានរៀបចំ និងចាប់ផ្តើមអនុវត្ត | សមត្ថភាព និងប្រសិទ្ធភាពនៃការអនុវត្តច្បាប់នៅគ្រប់កម្រិតថ្នាក់នៃរដ្ឋបាលជលផល ត្រូវបានកែលំអរយ៉ាងហោចណាស់ ៤០% នៃកម្រិត ឆ្នាំ ២០០៧ | សមត្ថភាព និងប្រសិទ្ធភាពនៃការអនុវត្តច្បាប់នៅគ្រប់កម្រិតថ្នាក់នៃរដ្ឋបាលជលផល ត្រូវបានកែលម្អយ៉ាងហោចណាស់ ៨០% នៃកម្រិតឆ្នាំ ២០០៧ |
| ៧.១០ កម្រិតនៃហេដ្ឋារចនាសម្ព័ន្ធដែលមានសម្រាប់គាំទ្រដល់ការអភិវឌ្ឍវិស័យជលផល | ពុំមានទិន្នន័យ | ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តជាមូលដ្ឋានលិខិតបទដ្ឋានច្បាប់ ព័ត៌មាន និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន គឺមានគ្រប់គ្រាន់សម្រាប់គាំទ្រដល់ដំណើរការសម្រេចឱ្យបាននូវចំណុចដៅដែលបានកំណត់នៅឆ្នាំ ២០១២ | ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តជាមូលដ្ឋាន លិខិតបទដ្ឋានច្បាប់ ព័ត៌មាន និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនគឺមានគ្រប់គ្រាន់សម្រាប់គាំទ្រដល់ដំណើរការសម្រេចឱ្យបាននូវចំណុចដៅដែលបានកំណត់នៅឆ្នាំ ២០១៥ | ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តជាមូលដ្ឋានលិខិតបទដ្ឋានច្បាប់ ព័ត៌មាន និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន គឺមានគ្រប់គ្រាន់សម្រាប់គាំទ្រដល់ដំណើរការសម្រេចឱ្យបាននូវចំណុចដៅដែលបានកំណត់នៅ ឆ្នាំ២០១៩ |
| ៧.១១ ការធ្វើសុខដុមនីយកម្មរវាងផែនការវិស័យជលផលជាមួយនឹងភូមិមួយផលិតផលមួយថ្នាក់ជាតិ និងកម្មវិធីភូមិមួយផលិតផលផលផលមួយថ្នាក់តំបន់ | ២០០៩ : គោលនយោបាយ និងផែនការដំបូងត្រូវបានរៀបចំព្រាងឡើង | គោលនយោបាយ និងផែនការសម្រាប់បញ្ជ្រាបនិងធ្វើសុខដុមនីយកម្មផលផលជាមួយនឹងភូមិមួយផលិតផលផលផលមួយថ្នាក់ជាតិ និងកម្មវិធីភូមិមួយផលិតផលផលផលមួយថ្នាក់តំបន់ត្រូវបានរៀបចំឡើង និងដាក់ឱ្យអនុវត្ត | សកម្មភាពភូមិមួយផលិតផលផលផលមួយ ត្រូវបានអនុវត្តសាកល្បង និងពិនិត្យឡើងវិញសម្រាប់ការអនុវត្តនៅទូទាំងប្រទេស | សកម្មភាពភូមិមួយផលិតផលផលផលមួយត្រូវបានអនុវត្តសាកល្បង និងពិនិត្យឡើងវិញសម្រាប់ការអនុវត្តនៅទូទាំងប្រទេស |
| ៧.១២ គោលការណ៍ណែនាំបច្ចេកទេសស្តីពីស្តង់ដារផលិតផល និងការអនុវត្តល្អ និង ឧបករណ៍សម្ភារៈមន្ទីរពិសោធន៍សម្រាប់គាំទ្រដល់អ្នកពាក់ព័ន្ធក្នុងវិស័យ | ២០០៩ :<br>ស្តង់ដារបច្ចេកទេស ចំនួន៥ និងស្តង់ដារផលិតផលចំនួន ៩មុខ | • ជំនួយការបច្ចេកទេស និងសេវាមន្ទីរពិសោធន៍ងាយស្រួលសម្រាប់អ្នកកែច្នៃនិងអ្នកនាំចេញផលនេសាទក្នុងការប្រើប្រាស់<br>• បទដ្ឋានច្បាប់អំពីអនាម័យការត្រួតពិនិត្យជាផ្លូវការផលិតផលជាតិ និងស្តង់ដារបច្ចេកទេសត្រូវបានអនុវត្ត | ប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យគុណភាព និងសុវត្ថិភាពដ៏ពេញលេញត្រូវបានអនុវត្ត និងប្រើប្រាស់ដោយអ្នកពាក់ព័ន្ធ | គ្រប់ប្រព័ន្ធត្រួតពិនិត្យគុណភាពត្រី និងស្តង់ដារសុវត្ថិភាពទាំងអស់ត្រូវបានអនុវត្តដោយគ្រប់អ្នកពាក់ព័ន្ធទាំងអស់ក្នុងកម្រិតដ៏សមស្របមួយដែលបំពេញបាននូវគ្រប់លក្ខខណ្ឌថ្នាក់ជាតិសម្រាប់ការនាំចេញ |
| ៧.១៣ ការអភិវឌ្ឍធនធានមនុស្ស និងសមត្ថភាពនៅក្នុងរដ្ឋបាលជលផល | ពុំមានព័ត៌មាន | ផែនការកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្សត្រូវបានរៀបចំចប់សព្វគ្រប់ | កម្មវិធីគ្រប់គ្រងសមត្ថភាពត្រូវបានអនុវត្តពេញលេញនៅថ្នាក់ក្រោមជាតិ | ចំណុចដៅនៃការអភិវឌ្ឍធនធានមនុស្ស និងសមត្ថភាពគឺសម្រេចបានទាំងស្រុង |

# ឧបសម្ព័ន្ធ ២

# សាវតារនៃក្របខណ្ឌផែនការយុទ្ធសាស្ត្រ

ក្របខណ្ឌផែនការយុទ្ធសាស្ត្រនេះត្រូវបានបង្កើតឡើងដោយមានការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានានៅក្នុងវិស័យជលផលអស់រយៈពេលជាច្រើនឆ្នាំ។ រដ្ឋបាលជលផលបានបំពេញការងារយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីស្វែងយល់ពីគោលបំណង និងសេចក្ដីប្រាថ្នារបស់អ្នកពាក់ព័ន្ធទាំងនោះ ហើយបានធ្វើការពិគ្រោះយោបល់ និងរៀបចំវេទិកាស្ដីពីជលផល ដើម្បីពិភាក្សា និងកំណត់នូវបញ្ហាចំបងៗដែលកើតឡើងនៅក្នុងវិស័យ និងជាពិសេសការកំណត់នូវកាលានុវត្តភាព និងបញ្ហាប្រឈមនានា។

រដ្ឋបាលជលផលបានធ្វើការយ៉ាងជិតស្និទ្ធជាមួយសហគមន៍ និងឃុំ សង្កាត់នានា ដែលប្រជាពលរដ្ឋរស់នៅទីនោះមានការពឹងអាស្រ័យលើធនធានជលផលសម្រាប់ជាប្រភពស្បៀងអាហារ និងប្រភពផ្ដល់ការងារធ្វើ ដើម្បីស្វែងយល់អំពីតម្រូវការរបស់សហគមន៍ទាំងនេះសម្រាប់ការងារអភិវឌ្ឍន៍ និងការងារគ្រប់គ្រងធនធានជលផល។ កិច្ចការនេះត្រូវបានធ្វើឡើងតាមរយៈ ការវាយតម្លៃអំពីតម្រូវការ ការប៉ាន់ប្រមាណអំពីផលប៉ះពាល់ និងកិច្ចប្រជុំពិគ្រោះយោបល់នានាជាច្រើនទៀត។

ក្របខណ្ឌផែនការយុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈម និងដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍វិស័យជលផលនៅកម្ពុជា។ ដើម្បីធានាបាននូវទំនាក់ទំនង និងបន្តផ្ដល់នូវការណែនាំដ៏សមស្របសម្រាប់ដំណើរការកសាងផែនការជារួម និងវឌ្ឍនភាពដែលសម្រេចបាន ធៀបនឹងចំណុចដៅដែលបានកំណត់ ក្របខណ្ឌនៃផែនការយុទ្ធសាស្ត្រនេះនឹងត្រូវពិនិត្យមើលឡើងវិញបន្ទាប់ពីរយៈពេល ៣ ឆ្នាំ ប្រសិនបើចាំបាច់ ហើយការកែតម្រូវនឹងត្រូវធ្វើឡើងដើម្បីគាំទ្រដល់ផែនការសកម្មភាព និងផែនការអភិវឌ្ឍ។ លើសពីនេះផ្អែកតាមមាត្រាទី ១៥ នៃច្បាប់ស្ដីពីជលផល ក្របខណ្ឌផែនការយុទ្ធសាស្ត្រនឹងត្រូវធ្វើបច្ចុប្បន្នភាពជាផ្លូវការរៀងរាល់ ៥ ឆ្នាំ ម្ដង។

### ដំណើរការកសាងផែនការវិស័យជលផលៈ

ក្របខណ្ឌផែនការយុទ្ធសាស្ត្រនេះ គឺជាចំណុចចាប់ផ្ដើមក្នុងការរៀបចំផែនការសកម្មភាព និងអភិវឌ្ឍវិស័យជលផលនៃរដ្ឋបាលជលផល។ ទោះបីជាយ៉ាងដូច្នេះក្ដី រាល់ផែនការរយៈពេលវែង គឺតម្រូវឱ្យមានការកែសម្រួល ដើម្បីឱ្យស្របទៅនឹងការប្រែប្រួលនៃស្ថានភាពនយោបាយ សង្គម សេដ្ឋកិច្ច និងបរិស្ថានដែលនឹងធ្វើឱ្យមានការប៉ះពាល់ដល់វិស័យជលផលនៅក្នុងឆ្នាំខាងមុខ។ ដូចនេះ ក្របខណ្ឌផែនការយុទ្ធសាស្ត្រនេះគឺកំណត់នូវបំណងប្រាថ្នាដ៏ទូលំទូលាយ និងគោលដៅសម្រាប់អនាគត ដែលជាមូលដ្ឋានបង្អែកសម្រាប់រៀបចំផែនការសកម្មភាពលម្អិត។ ដំណើរការកសាងផែនការនេះ មានធាតុជាច្រើនរួមបញ្ចូលគ្នាៈ

១ **ផែនការសកម្មភាពអភិវឌ្ឍន៍វិស័យជលផលៈ** ផែនការនេះមានវិសាលភាពគ្របដណ្ដប់រយៈពេល ៣ ឆ្នាំ ហើយត្រូវធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំដើម្បីគ្របដណ្ដប់រយៈពេល ៣ ឆ្នាំ ខាងមុខ។ ដូច្នេះផែនការនេះ គឺជា ផែនការរំកិលដែលផ្ដល់ឱ្យនូវទិសដៅលម្អិត និងជាឧបករណ៍សំខាន់សម្រាប់រៀបចំផែនការសកម្មភាពលម្អិតរបស់រដ្ឋបាលជលផល និងបង្ហាញដល់ដៃគូអភិវឌ្ឍន៍ទាំងអស់អំពីកម្មវត្ថុអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលចំពោះវិស័យជលផលនៅពេលទៅខាងមុខ។ នេះ គឺជាផែនការដែលនឹងត្រូវប្រើប្រាស់ដើម្បីធានាការអនុវត្ត គឺស្របតាមចំណុចដៅដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រ ហើយស្ថិតនៅលើផ្លូវដ៏ត្រឹមត្រូវមួយ ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលចំពោះវិស័យជលផល។

២ **ផែនការវិស័យជលផលប្រចាំឆ្នាំៈ** នេះគឺជាផែនការលម្អិតដែលបង្ហាញនូវលទ្ធផលរំពឹងទុកដែលនឹងសម្រេចឱ្យបាន និងសកម្មភាពដែលត្រូវអនុវត្តនៅក្នុងឆ្នាំនីមួយៗ សំដៅសម្រេចឱ្យបាននូវគោលបំណងរួម។ ផែនការនេះរួមមាន ផែនការអនុកម្មវិធីតាមផ្នែកនីមួយៗរបស់វិស័យជលផល ដូចជាផ្នែកវារីវប្បកម្ម សហគមន៍នេសាទ កិច្ចការនេសាទ គុណភាពនិងកែច្នៃ អភិរក្ស និងគ្រប់គ្រងធនធានជលផល លើសពីនេះនៅមានផែនការលម្អិតទៅតាមសកម្មភាពជាក់លាក់នីមួយៗថែមទៀត។

៣ **ផែនការសកម្មភាពប្រចាំឆ្នាំរបស់ខណ្ឌរដ្ឋបាលជលផលៈ** ការគ្រប់គ្រងវិស័យជលផលនៅតាមបណ្តាខេត្តនីមួយៗ គឺត្រូវបានគាំទ្រដោយខណ្ឌរដ្ឋបាលជលផល។ ខណ្ឌរដ្ឋបាលជលផលបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គការក្នុងស្រុក និងប្រជាពលរដ្ឋ ហើយនេះគឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការផ្តល់នូវសេវាកម្មជូនដល់អ្នកពាក់ព័ន្ធទាំងនោះ។ រដ្ឋបាលជលផលកំពុងធ្វើការងារតាមរយៈខណ្ឌរដ្ឋបាលជលផល ដើម្បីបង្ខិតផែនការសកម្មភាពទៅជិតប្រជាជនដែលជាក្រុមអ្នកទទួលផលតាមគោលដៅកំណត់ ហើយកិច្ចការនេះត្រូវបានធ្វើឡើងស្របជាមួយនឹងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល។

ផែនការទាំងអស់នេះ គឺផ្អែកតាមវិធីសាស្ត្រនៃតារាងសុក្រឹតភាព ហើយផែនការទាំងអស់តម្រូវឱ្យមានសង្គតិភាព និងស្របទៅនឹងគោលដៅនៃការអភិវឌ្ឍរួម។ របាយការណ៍វឌ្ឍនភាពនឹងត្រូវធ្វើឡើងជាទៀតទាត់ ដើម្បីវាស់វែងពីលទ្ធផលដែលបានអនុវត្ត ហើយការត្រួតពិនិត្យឯករាជ្យ និងក្រុមវាយតម្លៃផ្ទៃក្នុងរដ្ឋបាលជលផលនឹងធ្វើការត្រួតពិនិត្យយ៉ាងទៀងទាត់ផងដែរ។

ផែនការជលផលពិពណ៌នាអំពីអ្វីដែលនឹងត្រូវអនុវត្ត ប៉ុន្តែវាក៏ជាការចាំបាច់ផងដែរចំពោះការផ្តល់នូវការបកស្រាយថាតើត្រូវធ្វើយ៉ាងណា។ ដូចនេះ កាំកូដត្រូវបានបង្កើតឡើងដើម្បីផ្តល់ការណែនាំអំពីគោលការណ៍សម្រាប់អ្នកពាក់ព័ន្ធទាំងអស់ដែលមានការពាក់ព័ន្ធនៅក្នុងវិស័យជលផលកម្ពុជា។ កាំកូដ ត្រូវបានបង្កើតឡើងដោយផ្អែកលើក្រមប្រតិបត្តិថ្នាក់តំបន់ ស្តីពីការនេសាទដោយមានការទទួលខុសត្រូវដែលបានរៀបចំឡើងដោយអង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ។ ប៉ុន្តែកាំកូដ ត្រូវបានរៀបចំឡើងទៅតាមតម្រូវការជាក់លាក់របស់ប្រជាជនកម្ពុជា។ និយាយជារួមទាំងដំណើរការរៀបចំផែនការអភិវឌ្ឍវិស័យជលផល និងកាំកូដ គឺផ្តល់នូវការណែនាំសម្រាប់អ្នកពាក់ព័ន្ធទាំងអស់នៅក្នុងវិស័យជលផល។

# ឧបសម្ព័ន្ធ ៣

# លក្ខខណ្ឌយោងសម្រាប់ការអនុវត្ត ផែនការខណ្ឌរដ្ឋបាលជលផល និងការសម្របសម្រួល

មានការទទួលស្គាល់ថា តួនាទីរបស់រដ្ឋបាលជលផលចាំបាច់ត្រូវតែពង្រឹង និងពង្រីកនៅក្នុងកម្មវិធីជាតិសម្រាប់គាំទ្រដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងគោលនយោបាយពាក់ព័ន្ធនឹងរបបវិមជ្ឈការ និងវិសហមជ្ឈការដើម្បីរួមចំណែកក្នុងការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យនៅកម្ពុជាឱ្យកាន់តែមានភាពប្រសើរឡើង។ រដ្ឋបាលជលផលនឹងត្រូវចំណាយពេលវេលា ធនធាន ការប្រឹងប្រែងយ៉ាងយកចិត្តទុកដាក់ និងធនធានមនុស្សក្នុងការបង្កើតយន្តការសមស្របមួយដើម្បីឱ្យក្លាយជាស្ថាប័នផ្តល់សេវាកម្មបានយ៉ាងល្អប្រសើរទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ចំពោះវិស័យជលផលនៅថ្នាក់ក្រោមជាតិ ជាពិសេសការផ្តល់នូវសេវាកម្មដល់ប្រជាជននៅមូលដ្ឋាន គឺពឹងផ្អែកយ៉ាងខ្លាំងទៅលើតួនាទី និងលទ្ធភាពរបស់ខណ្ឌរដ្ឋបាលជលផលនាពេលបច្ចុប្បន្ន ក៏ដូចជាទៅអនាគត ពីព្រោះខណ្ឌរដ្ឋបាលជលផល គឺជាអង្គភាពដែលត្រូវអនុវត្តសកម្មភាពដោយផ្ទាល់នៅមូលដ្ឋាន និងគ្រប់គ្រងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងយល់ដឹងអំពីតម្រូវការ និងបញ្ហាប្រឈមរបស់ប្រជាពលរដ្ឋមូលដ្ឋាន ហើយមានបទពិសោធន៍ក្នុងការរិះរកវិធានការសមស្របសម្រាប់ដោះស្រាយនូវបញ្ហាប្រឈមទាំងនោះ។ ទោះបីជាយ៉ាងដូច្នេះក្តី សមត្ថភាពរបស់មន្ត្រីខណ្ឌរដ្ឋបាលជលផលពាក់ព័ន្ធនឹងការគ្រប់គ្រងបច្ចេកទេសជំនាញ និងការធ្វើទំនាក់ទំនងជាមួយនឹងអ្នកពាក់ព័ន្ធសំខាន់ៗនៅក្នុងខេត្តនៅមានកម្រិត។

ដូច្នេះ ដើម្បីគាំទ្រខណ្ឌរដ្ឋបាលជលផលក្នុងការបំពេញតួនាទីរបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត នោះរដ្ឋបាលជលផលចាំបាច់ត្រូវធ្វើការបណ្តុះបណ្តាលសមត្ថភាពមន្ត្រីខណ្ឌរដ្ឋបាលជលផលដើម្បី៖ (១) រៀបចំផែនការខណ្ឌឱ្យស្របជាមួយនឹងគោលដៅនៃក្របខណ្ឌផែនការយុទ្ធសាស្ត្ររបស់វិស័យជលផលរយៈពេល ១០ ឆ្នាំ និងស្របជាមួយនឹងផែនការថ្នាក់ក្រោមជាតិ និងតម្រូវការអាទិភាពរបស់មូលដ្ឋានតាមរយៈដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ (២) បង្កើតយន្តការសមស្របមួយដែលអាចចែករំលែកព័ត៌មាន និងសម្របសម្រួលជាមួយនឹងអ្នកពាក់ព័ន្ធសំខាន់ៗ រួមមាន៖ អង្គការមិនមែនរដ្ឋាភិបាល សហគមន៍វិស័យឯកជន ក្រុមប្រឹក្សាឃុំជាដើម ដើម្បីផ្តល់នូវការគាំទ្រផ្នែកសេវាកម្មសម្រាប់ការធ្វើផែនការ និងការអនុវត្តផែនការថ្នាក់ខេត្ត ស្រុក ឃុំ ហើយអាចកាត់បន្ថយនូវសកម្មភាពត្រួតគ្នា និងជាការរួមកម្លាំងដែលផ្តល់នូវផលជាអតិបរមា (៣) ចែករំលែកព័ត៌មាន និងចូលរួមនៅក្នុងដំណើរការរៀបចំផែនការ ឬកម្មវិធីវិនិយោគខេត្ត និងចូលរួមនៅក្នុងយន្តការសម្របសម្រួលនៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត (គ.អ.ជ.ខ) ឬគណៈកម្មការប្រតិបត្តិ (គ.ប្រ) (៤) ចូលរួមនៅក្នុងយន្តការសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ដើម្បីជ្រើសរើសគម្រោងដែលត្រូវអនុវត្ត និងផ្តល់នូវសេវាកម្មបច្ចេកទេស ដើម្បីគាំទ្រដល់ការអនុវត្តគម្រោងពាក់ព័ន្ធនឹងជលផលថ្នាក់ឃុំ និងថ្នាក់ស្រុក និង (៥) តាមដានការអនុវត្តគម្រោងជលផល ហើយផ្តល់ព័ត៌មានជូនថ្នាក់ជាតិ (ក្រុមការងារបច្ចេកទេសចម្រុះស្តីពីកំណែទម្រង់នេសាទ) អំពីវឌ្ឍនភាពនិងបញ្ហាប្រឈមដែលជួបប្រទះ ជាពិសេសបញ្ហាដែលត្រូវការអន្តរាគមន៍បន្ថែមទៀត។

លក្ខខណ្ឌយោងនេះ គឺរៀបរាប់អំពីយន្តការ និងដំណើរការដែលអាចផ្សារភ្ជាប់ជាមួយនឹងផែនការថ្នាក់ក្រោមជាតិនានា និងយន្តការវិភាជន៍ថវិកាដែលអាចគាំទ្រដល់ការរៀបចំ និងការអនុវត្តផែនការខណ្ឌរដ្ឋបាលជលផល ហើយអាចផ្តល់នូវសេវាកម្មជូនដល់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ប្រកបដោយប្រសិទ្ធភាព និងមានការសម្របសម្រួលល្អ។

## យន្តការ

- ប្រធានៈ នាយខណ្ឌរដ្ឋបាលជលផល
- អ្នកសម្របសម្រួលៈ ដៃគូអភិវឌ្ឍន៍/អង្គការមិនមែនរដ្ឋាភិបាល ឬវិស័យឯកជនដែលបំពេញការងារយ៉ាងសកម្មនៅក្នុងវិស័យជលផលនៅថ្នាក់ខណ្ឌរដ្ឋបាលជលផល
- លេខាធិការដ្ឋានៈ ការិយាល័យផែនការរបស់ខណ្ឌរដ្ឋបាលជលផល។

### ផលិតផលគោលដៅឆ្នាំ២០១០-២០១៩[៧]




| | | | |
|---|---|---|---|
| **ក.ក.ប.ជ.ផ** | ក្រុមការងារបច្ចេកទេសចម្រុះស្តីពីកំណែទម្រង់នេសាទ | **ស.ន** | សហគមន៍នេសាទ |
| **គ.ប្រ** | គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត | **ស.គ.ម** | សហគមន៍មូលដ្ឋាន |
| **គ.អ.ជ.ខ** | គណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត | **គ.ជ.អ.ប** | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| **ន.អ.ស** | នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទ | | |

## ការបកស្រាយខ្លឹមសារគំនូសតាងខាងលើ

គំនូសតាងស្តីពីការសម្របសម្រួល និងការកសាងផែនការខណ្ឌខាងលើនេះរួមមានៈ នៅផ្នែកខាងស្តាំ បង្ហាញអំពីដំណើរការកសាងផែនការថ្នាក់ក្រោមជាតិ និងផ្នែកខាងឆ្វេង គឺបង្ហាញអំពីអ្នកពាក់ព័ន្ធ និងការកសាងផែនការខណ្ឌរដ្ឋបាលជលផល។ គំនូសតាងនេះបង្ហាញអំពីដំណើរការកសាងផែនការនៅថ្នាក់ក្រោមជាតិ ដែលផ្តើមចេញពីការរៀបចំតារាងសកម្មភាពអាទិភាពស្រុក ដែលតារាងនេះត្រូវបានផ្ញើជូនទៅ គ.អ.ជ.ខ ឬ គ.ប្រ ដើម្បីពិនិត្យហើយតារាងនេះ នឹងក្លាយជាមូលដ្ឋានសម្រាប់គម្រោងអាទិភាពដែលត្រូវដាក់បញ្ចូលនៅក្នុងផែនការវិនិយោគខេត្ត ស្រុក និងឃុំដោយទទួលបានមូលនិធិគាំទ្រតាមរយៈ មូលនិធិវិនិយោគខេត្ត ស្រុក និងឃុំ។

នៅក្នុងការរៀបចំផែនការអភិវឌ្ឍ ឬផែនការវិនិយោគខេត្ត គណៈកម្មការប្រតិបត្តិខេត្ត ត្រូវពិនិត្យមើលតារាងសកម្មភាពអាទិភាពស្រុក ជាមួយនឹងមន្ទីរ និងភ្នាក់ងារពាក់ព័ន្ធនៅជុំវិញខេត្ត ដើម្បីកំណត់ឱ្យបាននូវគម្រោងណាមួយដែលពាក់ព័ន្ធនឹងអាទិភាពនៃអង្គភាពរបស់ខ្លួន ហើយកំណត់ឱ្យបាននូវគម្រោងណាដែលខ្លួននឹងត្រូវអនុវត្ត។ ខណ្ឌរដ្ឋបាលជលផលត្រូវធ្វើការទាក់ទងជាមួយនឹង គ.ប្រ ក្នុងរយៈពេលនៃដំណើរការកសាងផែនការអភិវឌ្ឍ ឬផែនការវិនិយោគខេត្ត ដើម្បីបង្ហាញជូនអំពីសកម្មភាពអាទិភាពរបស់ខណ្ឌរដ្ឋបាលជលផល និងគោលដៅនៃក្របខណ្ឌផែនការយុទ្ធសាស្ត្ររបស់វិស័យជលផល ១០ ឆ្នាំ ហើយកំណត់នូវគម្រោងដែលនឹងត្រូវរៀបចំសម្រាប់អនុវត្ត។ នៅក្នុងរយៈពេលនៃការអនុវត្ត ខណ្ឌរដ្ឋបាលជលផល ត្រូវចូលរួមកិច្ចប្រជុំដើម្បីសម្របសម្រួលជាមួយនឹងអ្នកពាក់ព័ន្ធទាំងអស់នៅក្នុងខេត្ត។ បន្ទាប់ពី គ.ប្រ និងមន្ទីរពាក់ព័ន្ធធ្វើការពិនិត្យតារាងសកម្មភាពអាទិភាពស្រុករួចមក តារាងនេះនឹងត្រូវយកមកពិភាក្សានៅក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ដើម្បីឱ្យមានការបញ្ជាក់ពីអង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន មន្ទីរវិស័យ និងក្រុមប្រឹក្សាស្រុកក្នុងការជ្រើសរើសសម្រាប់ផ្តល់ការគាំទ្រ។

សិក្ខាសាលានេះ មានបំណងទទួលបាននូវកិច្ចព្រមព្រៀងជាមួយនឹងមន្ទីរវិស័យ ក៏ដូចជាអង្គការដៃគូក្នុងការផ្តល់នូវការគាំទ្រ។ គម្រោងដែលក្រុមប្រឹក្សាស្រុកជ្រើសរើស នឹងត្រូវដាក់បញ្ចូលនៅក្នុងផែនការស្រុក ហើយផ្តល់មូលនិធិតាមរយៈមូលនិធិវិនិយោគស្រុក។ ដោយឡែក ចំពោះគម្រោងដែលពុំមានការគាំទ្រ ក្រុមប្រឹក្សាឃុំនឹងផ្តល់នូវមូលនិធិក្នុងការអនុវត្តទៅតាមលទ្ធភាពដែលអាចធ្វើបានតាមរយៈមូលនិធិវិនិយោគឃុំ។ ខណ្ឌរដ្ឋបាលជលផល ត្រូវធ្វើការទាក់ទងជាប្រចាំជាមួយនឹងក្រុមប្រឹក្សាស្រុក ដើម្បីពិភាក្សាអំពីបញ្ហា និងសកម្មភាពអាទិភាពរបស់វិស័យជលផល និងការស្វែងយល់អំពីបញ្ហា និងសកម្មភាពអាទិភាពរបស់ស្រុក។ ខណ្ឌរដ្ឋបាលជលផលត្រូវចូលរួមសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ដើម្បីធ្វើការទាក់ទង និងសម្របសម្រួលជាមួយនឹងក្រុមប្រឹក្សាស្រុក និង ក្រុមប្រឹក្សាឃុំ ក្នុងការជ្រើសរើសគម្រោង និងការផ្តល់នូវសេវាកម្ម។ តាមរយៈការចូលរួមសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌរដ្ឋបាលជលផល អាចរៀបចំផែនការខណ្ឌរដ្ឋបាលជលផលដែលស្របជាមួយនឹង ក្របខណ្ឌផែនការយុទ្ធសាស្ត្ររបស់វិស័យជលផល ១០ ឆ្នាំផង និងដោះស្រាយបាននូវបញ្ហាអាទិភាពនៅថ្នាក់ក្រោមជាតិផង។

## លទ្ធផលរំពឹងទុកសំខាន់ៗ

លក្ខខណ្ឌយោងនេះមានគោលបំណង ដើម្បីសម្រេចឱ្យបាននូវលទ្ធផលរំពឹងទុកចំនួន ៦ តាមរយៈការអនុវត្តនូវសកម្មភាពដែលបានកំណត់។ លទ្ធផលរំពឹងទាំង ៦ និងសកម្មភាពពាក់ព័ន្ធមានចែងដូចខាងក្រោមៈ

**១ ព័ត៌មានពាក់ព័ន្ធត្រូវបានធ្វើការចែករំលែក រវាងអ្នកពាក់ព័ន្ធនៅថ្នាក់ខណ្ឌ**

- **ចែករំលែកព័ត៌មានពាក់ព័ន្ធនឹងជលផលៈ** ធ្វើបច្ចុប្បន្នភាពជាប្រចាំជាមួយនឹងអ្នកពាក់ព័ន្ធរួមមាន គ.អ.ជ.ខ ឬ គ.ប្រ. ដៃគូអភិវឌ្ឍន៍ និងអង្គការពាក់ព័ន្ធអំពីច្បាប់ គោលនយោបាយ ផែនការ លទ្ធផលនៃការអនុវត្តសកម្មភាពការងារ និងព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងវិស័យជលផល។
- **រៀបចំវេទិកាជលផលៈ** រៀបចំវេទិកាដើម្បីពិភាក្សាអំពីប្រធានបទជាក់លាក់ណាមួយ ពាក់ព័ន្ធនឹងវិស័យជលផល (ឧទាហរណ៍ៈ សហគមន៍នេសាទ ការអភិរក្សជលផល ជាដើម) ដែលផ្តល់ឱកាសដល់អ្នកពាក់ព័ន្ធបានចូលរួមហើយធ្វើឱ្យកាន់តែប្រសើរឡើងនូវផែនការខណ្ឌរដ្ឋបាលជលផល។ ផ្តល់ព័ត៌មានដល់ក្រុមការងារបច្ចេកទេសចម្រុះស្តីពីកំណែទម្រង់នេសាទ អំពីភាពចាំបាច់ក្នុងការកែសម្រួលក្របខណ្ឌផែនការយុទ្ធសាស្ត្រវិស័យជលផលរយៈពេល ១០ឆ្នាំ និងគោលការណែនាំផ្សេងៗ។

**២ ផែនការខណ្ឌរដ្ឋបាលជលផលត្រូវបានរៀបចំឡើង និងធ្វើឱ្យស្របជាមួយនឹងក្របខណ្ឌផែនការយុទ្ធសាស្ត្ររបស់វិស័យជលផល ១០ ឆ្នាំ និងផែនការអភិវឌ្ឍថ្នាក់ក្រោមជាតិ (ផ្អែកលើប្រព័ន្ធបច្ចុប្បន្ន)**

- ពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនៅក្នុងវិស័យជលផលៈ ប្រជុំជាមួយអ្នកពាក់ព័ន្ធដើម្បីពិភាក្សាអំពីបញ្ហា និងកាលានុវត្តភាពនៃវិស័យជលផលនៅថ្នាក់ខណ្ឌ គោលដៅនៃក្របខណ្ឌផែនការយុទ្ធសាស្ត្ររបស់វិស័យជលផល និងសក្តានុពល

នៃវិស័យជលផល កិច្ចអន្តរាគមន៍ សកម្មភាពអាទិភាព និងការសម្របសម្រួល (អាទិភាពរបស់រដ្ឋបាលជលផល គម្រោងរបស់អង្គការ សហគមន៍មូលដ្ឋាន និងវិស័យឯកជន) និងលទ្ធភាពនៃការកៀរគរប្រភពមូលនិធិ (អង្គការ ឯកជន ថវិការបស់រដ្ឋបាលជលផល ។ ល។)

- **ទំនាក់ទំនងជាមួយ គ.អ.ជ.ខ/គ.ប្រ និងក្រុមប្រឹក្សាៈ** ចែករំលែកគោលដៅនៃក្របខណ្ឌផែនការយុទ្ធសាស្ត្ររបស់វិស័យជលផល ១០ ឆ្នាំ ជាមួយនឹង គ.អ.ជ.ខ ឬ គ.ប្រ និងក្រុមប្រឹក្សា ហើយពិភាក្សាអំពីបញ្ហា និងកាលានុវត្តភាពរបស់វិស័យជលផល។ ពិភាក្សាអំពីតម្រូវការអាទិភាពរបស់វិស័យជលផលថ្នាក់ស្រុកកិច្ចអន្តរាគមន៍ បែបបទនៃការអនុវត្ត និងប្រភពមូលនិធិ។

- **ចូលរួមដំណើរការរៀបចំផែនការអភិវឌ្ឍខេត្តៈ** ចូលរួមជាមួយ គ.អ.ជ.ខ ឬ គ.ប្រ និងដៃគូអភិវឌ្ឍន៍នានា ក្នុងការរៀបចំផែនការអភិវឌ្ឍ ឬកម្មវិធីវិនិយោគខេត្ត។ ចែករំលែកព័ត៌មានអំពីក្របខណ្ឌផែនការយុទ្ធសាស្ត្ររបស់វិស័យជលផល ១០ ឆ្នាំ ជាមួយនឹង គ.អ.ជ.ខ ឬ គ.ប្រ និងអ្នកពាក់ព័ន្ធដែលចូលរួមនៅក្នុងដំណើរការរៀបចំផែនការខេត្ត កំណត់នូវបញ្ហា និងកាលានុវត្តភាពវិស័យជលផលនៅថ្នាក់ខេត្ត។ ពិនិត្យមើលតម្រូវការអាទិភាព ដែលបានលើកឡើងនៅក្នុងតារាងអាទិភាពរបស់ឃុំ និងពិភាក្សាអំពីតម្រូវការអាទិភាពផ្សេងទៀតដែលឆ្លុះបញ្ចាំងអំពីសកម្មភាពអាទិភាពរបស់រដ្ឋបាលជលផលអង្គការដៃគូ សហគមន៍។ ល។ ពិភាក្សាអំពីសកម្មភាពដែលអាចទទួលបាននូវថវិកាពីកញ្ចប់ថវិកាវិនិយោគខេត្ត និងពីប្រភពថវិកាផ្សេងទៀត។

- **ទំនាក់ទំនងជាមួយក្រុមប្រឹក្សាស្រុកៈ** ចែករំលែកព័ត៌មានអំពីក្របខណ្ឌផែនការយុទ្ធសាស្ត្ររបស់វិស័យជលផល ១០ ឆ្នាំ ជាមួយនឹងក្រុមប្រឹក្សាស្រុក ហើយពិភាក្សាអំពីបញ្ហា និងសក្តានុពលនៃវិស័យជលផល។ ពិភាក្សាអំពីតម្រូវការអាទិភាពរបស់វិស័យជលផលថ្នាក់ស្រុក កិច្ចអន្តរាគមន៍ បែបបទនៃការអនុវត្ត និងប្រភពមូលនិធិ។

- **ធ្វើចំណាត់ថ្នាក់ប្រភេទអន្តរាគមន៍ចំពោះវិស័យជលផលៈ** កំណត់នូវសក្តានុពលនៃកិច្ចអន្តរាគមន៍ចំពោះវិស័យជលផល ផ្អែកតាមកម្រិតនៃការអនុវត្ត (ថ្នាក់ជាតិ ខេត្ត ស្រុក និងថ្នាក់ឃុំដែលស្របនឹងគោលដៅ និងអាទិភាពនៃក្របខណ្ឌផែនការយុទ្ធសាស្ត្ររបស់វិស័យជលផល ១០ ឆ្នាំ) ។

- **ចូលរួមនៅក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុកៈ** កំណត់គម្រោងអាទិភាពអន្តរឃុំនៅក្នុងតារាងសកម្មភាពអាទិភាព និងកំណត់គម្រោងដែលត្រូវបានជ្រើសរើសដោយអង្គការសង្គមស៊ីវិល វិស័យឯកជននិងម្ចាស់ជំនួយ។ កំណត់នូវសកម្មភាពដែលត្រូវអនុវត្ត ដោយផ្អែកលើសកម្មភាពអាទិភាពរបស់ស្រុក និងក្របខណ្ឌផែនការយុទ្ធសាស្ត្ររបស់វិស័យជលផល១០ឆ្នាំនិងពិភាក្សាអំពីប្រភពមូលនិធិជាមួយ នឹងស្រុករៀបចំបែបបទនៃការអនុវត្តជាមួយអង្គការវិស័យឯកជនទៅតាមការចាំបាច់។ ចុះហត្ថលេខាលើកិច្ចសន្យាបណ្តោះអាសន្នជាមួយស្រុក និងពិភាក្សាអំពីគម្រោងអាទិភាពសម្រាប់ការអនុវត្តនៅថ្នាក់ឃុំ និងពិភាក្សា ឬ ចរចាអំពីបញ្ហាថវិកា និងការផ្តល់នូវសេវាកម្ម ហើយបន្ទាប់មកចុះហត្ថលេខាលើកិច្ចសន្យាបណ្តោះអាសន្នជាមួយនឹងក្រុមប្រឹក្សាឃុំ។ ពិភាក្សាឡើងវិញនូវសកម្មភាពដែលត្រូវអនុវត្ត និងប្រភពមូលនិធិជាមួយនឹងតំណាង គ.អ.ជ.ខ ឬ គ.ប្រ ហើយចុះហត្ថលេខាលើកិច្ចសន្យាបណ្តោះអាសន្នជាមួយនឹងខេត្ត។

- **រៀបចំផែនការខណ្ឌ ស្របជាមួយនឹងក្របខណ្ឌផែនការយុទ្ធសាស្ត្ររបស់វិស័យជលផល និងផែនការអាទិភាពរបស់ថ្នាក់ក្រោមជាតិៈ** តម្រឹមសកម្មភាពអន្តរាគមន៍របស់ខណ្ឌក្នុងការគាំទ្រផែនការអាទិភាពថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំជាមួយនឹងក្របខណ្ឌផែនការយុទ្ធសាស្ត្ររបស់វិស័យជលផល។បញ្ចូលកិច្ចអន្តរាគមន៍ពីអ្នកពាក់ព័ន្ធផ្សេងៗហើយតម្រឹមជាមួយនឹងក្របខណ្ឌផែនការយុទ្ធសាស្ត្ររបស់វិស័យជលផល។ កំណត់ប្រភពមូលនិធិ (ខេត្ត ស្រុក ឃុំ រដ្ឋបាលជលផលថ្នាក់កណ្តាល អង្គការ ម្ចាស់ជំនួយ និងឯកជន) និងការទទួលខុសត្រូវក្នុងការផ្តល់នូវសេវាកម្ម។ បង្ហាញផែនការខណ្ឌជូនអ្នកពាក់ព័ន្ធដើម្បីពិនិត្យមើល ហើយដាក់ជូនរដ្ឋបាលជលផលថ្នាក់កណ្តាលដើម្បីទទួលបានថវិកាគាំទ្រ។ ជាមួយគ្នានេះ ត្រូវដាក់ផែនការខណ្ឌជូន គ.អ.ជ.ខ ឬ គ.ប្រ ដើម្បីដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍ និងផែនការវិនិយោគខេត្ត។

## ៣ ប្រព័ន្ធតាមដាន និងវាយតម្លៃប្រកបដោយប្រសិទ្ធភាពត្រូវបានរៀបចំ និងដាក់ឱ្យដំណើរការ

- គាំទ្រ គ.អ.ជ.ខ ឬ គ.ប្រ ក្នុងការបង្កើតឡើងនូវយន្តការតាមដាន និងវាយតម្លៃដែលឆ្លើយតបបាននូវតម្រូវការរបស់ក្របខណ្ឌផែនការយុទ្ធសាស្រ្តរបស់វិស័យជលផល និងផែនការខេត្ត។
- ប្រមូលព័ត៌មានជាប់ជាប្រចាំពាក់ព័ន្ធនឹងជលផល និងការអនុវត្តរបស់រដ្ឋបាលជលផល ហើយធ្វើការវិភាគព័ត៌មានទាំងនោះ ព្រមទាំងធ្វើការចែករំលែកជាមួយនឹង គ.អ.ជ.ខ. ឬ គ.ប្រ. រដ្ឋបាលជលផល និងអ្នកពាក់ព័ន្ធនានា។

## ៤ ការអនុវត្តន៍ផែនការខណ្ឌត្រូវបានសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធ (គអជខ ឬ គ.ប្រ ដៃគូអភិវឌ្ឍ អង្គការវិស័យឯកជន ។ល។)

- ត្រួតពិនិត្យកិច្ចអន្តរាគមន៍របស់ខណ្ឌ និងរៀបចំកិច្ចប្រជុំប្រចាំត្រីមាស ឬ ឆមាស ជាមួយនឹងអ្នកពាក់ព័ន្ធថ្នាក់ខេត្ត ដើម្បីពិនិត្យមើលវឌ្ឍនភាពនៃការអនុវត្តផែនការខណ្ឌ និងការលំបាក ដើម្បីធានាបាននូវការអនុវត្តប្រកបដោយប្រសិទ្ធភាព។
- ចូលរួមកិច្ចប្រជុំសម្របសម្រួលប្រចាំត្រីមាសរបស់ គ.អ.ជ.ប ឬ គ.ប្រ ដើម្បីកំណត់បាននូវបញ្ហាសម្របសម្រួល និងតម្រូវការក្នុងការគាំទ្រពីអ្នកពាក់ព័ន្ធ ដើម្បីទទួលបាននូវប្រសិទ្ធភាពនៃការអនុវត្តផែនការអភិវឌ្ឍ ឬកម្មវិធីវិនិយោគខេត្ត។

## ៥ ការកសាងសមត្ថភាពត្រូវបានផ្តល់ជូនដល់មន្ត្រី

- រៀបចំធ្វើការវាយតម្លៃតម្រូវការកសាងសមត្ថភាពរបស់មន្ត្រី
- ផ្តល់ការកសាងសមត្ថភាពជាប្រចាំដល់មន្ត្រី
- បង្កើតក្របខណ្ឌ ដូចជាមូលដ្ឋានទិន្នន័យដើម្បីចែករំលែកនូវព័ត៌មាន និងលទ្ធផលសម្រេចបានតាមរយៈវគ្គបណ្តុះបណ្តាល។

## ៦ ទីប្រឹក្សាបច្ចេកទេស និងសេវាកម្មត្រូវបានផ្តល់ជូនតាមការចាំបាច់

- កំណត់នូវតម្រូវការទីប្រឹក្សាបច្ចេកទេសនៅគ្រប់ថ្នាក់
- ផ្តល់ទីប្រឹក្សាបច្ចេកទេសតាមការចាំបាច់។

# ៤ ឧបសម្ព័ន្ធ

# ទំនាក់ទំនងរវាងវិស័យជលផល ជាមួយនឹងវិស័យផ្សេងទៀតរបស់ រាជរដ្ឋាភិបាល និងសង្គម

ការអភិវឌ្ឍវិស័យជលផលក្នុងរយៈពេលថ្មីៗកន្លងមកនេះ ត្រូវបានគាំទ្រដោយអ្នកផ្តល់សេវាកម្មមួយចំនួន។ ចំពោះរាជរដ្ឋាភិបាលអ្នកដែលផ្តល់សេវាកម្មដ៏សំខាន់សម្រាប់វិស័យជលផលគឺរដ្ឋបាលជលផល។ ទោះបីជាយ៉ាងដូច្នេះក្តី ការអភិវឌ្ឍវិស័យនេះគឺត្រូវពឹងផ្អែកលើសកម្មភាពគាំទ្រជាច្រើនពីស្ថាប័ននិងភ្នាក់ងារផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល(ដូចមាននៅក្នុងគំនូសតាងខាងក្រោមនេះ)។ គំនូសតាងនេះ គឺបង្ហាញថាស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវរួមសហការគ្នា ដើម្បីជំរុញវិស័យជលផលឱ្យសម្រេចបាននូវសក្តានុពលរបស់ខ្លួននៅក្នុងបរិបទជាតិទាំងមូល។

អ្នកពាក់ពន្ធ័ជាច្រើនផ្សេងទៀត ក៏មានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍនេះផងដែរ។ អ្នកពាក់ព័ន្ធទាំងនោះ រួមមានៈ វិស័យឯកជនចាប់ពីកម្រិតគ្រួសាររហូតដល់ឧស្សាហកម្មធុនធំ សហគមន៍មូលដ្ឋាន និងអង្គការសង្គមស៊ីវិល រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ដែលជាដៃគូអភិវឌ្ឍ ដែលបាននិងកំពុងបំពេញការងារនៅក្នុងការងារអភិវឌ្ឍពាក់ព័ន្ធនឹងវិស័យជលផល ហើយនឹងបន្តអនុវត្តទៅថ្ងៃអនាគតបន្តទៀត។




វិស័យជលផលមិនអាចផ្តាច់ចេញពីទំនាក់ទំនងជាមួយវិស័យនានារបស់រាជរដ្ឋាភិបាលកម្ពុជា និងសង្គមបានឡើយ[៤៤]

*៤៤. សហគមន៍មូលដ្ឋាន គណៈកម្មាធិការជាតិទន្លេមេគង្គ រដ្ឋបាលព្រៃឈើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងពាណិជ្ជកម្ម ក្រសួងបរិស្ថាន ក្រសួងសុខាភិបាល ក្រសួងមហាផ្ទៃ ក្រសួងធនធានទឹក និងឧតុនិយម គណៈកម្មការទន្លេមេគង្គ អង្គការមិនមែនរដ្ឋាភិបាល គណៈកម្មការជាតិភូមិមួយផលិផលមួយ*

# ឧបសម្ព័ន្ធ ៥

# យុទ្ធសាស្ត្របន្ថែមសម្រាប់វិស័យជលផល កម្ពុជាសម្រាប់ឆ្នាំ ២០១០

### វិស័យជលផលៈ

កន្លងមក វិស័យជលផលក្នុងប្រទេសកម្ពុជាបានរួមចំណែកយ៉ាងធំធេងចំពោះប្រទេសជាតិ មិនតែប៉ុណ្ណោះ វិស័យនេះអាចពង្រីកបាននូវសក្តានុពលរបស់ខ្លួនកាន់តែច្រើនថែមទៀតទៅថ្ងៃអនាគត។ ទោះបីជាផលនេសាទចាប់ពីធម្មជាតិឈានជិតដល់កម្រិតអតិបរមានៃការធានានិរន្តរភាពក៏ដោយ ប៉ុន្តែការលើកកម្ពស់ការគ្រប់គ្រងអាចធ្វើឱ្យកើនឡើងនូវគុណភាព និងស្ថេរភាពនៃផលចាប់ដែលជាមធ្យោបាយមួយយ៉ាងល្អក្នុងការកាត់បន្ថយនូវការចំណាយ និងបង្កើនប្រយោជន៍ដល់អ្នកប្រើប្រាស់។ វិស័យជលផលក៏បានរួមចំណែកដល់ប្រព័ន្ធផលិតកម្មខ្នាតតូច មធ្យម និង ខ្នាតធំ។ ម៉្យាងទៀត ការចូលរួមរបស់សហគមន៍គឺជាសក្តានុពលយ៉ាងធំធេង ក្នុងការគ្រប់គ្រងវិស័យជលផលប្រកបដោយប្រសិទ្ធភាព។ ការប្រើប្រាស់ធនធានវារិជាតប្រកបដោយនិរន្តរភាពគឺជាការថែរក្សា និងបង្កើននូវផលិតភាពរបស់វិស័យជលផលជាច្រើនថែមទៀត។

វារីវប្បកម្មទាំងខ្នាតតូច មធ្យម និងធំ គឺមានសក្តានុពលយ៉ាងសំខាន់ក្នុងការបង្កើននូវផលិតកម្មផលនេសាទ ដើម្បីរក្សាបាននូវសុវត្ថិភាពស្បៀង បង្កើនឱកាសការងារ និងជំរុញការនាំចេញ។ ដូចគ្នានេះដែរ ការនេសាទតាមវាលស្រែក៏មានសក្តានុពលដ៏ធំធេងសម្រាប់ការរីកចម្រើន និងផ្តល់នូវផលប្រយោជន៍ដល់សេដ្ឋកិច្ចនៅតំបន់ជនបទ។

ទំហំនៃផលប្រយោជន៍ដែលបានមកពីផលនេសាទធម្មជាតិ និងវារីវប្បកម្ម ក៏អាស្រ័យផងដែរទៅលើវិធីសាស្ត្រនៃការលើកដាក់ ការថែរក្សា ការកែច្នៃ ដឹកជញ្ជូន និងការជួញដូរ។ ផលប្រយោជន៍ដែលអាចទទួលបានពីការកែច្នៃឱ្យបានធំធេង គឺត្រូវផ្សារភ្ជាប់ជាមួយនឹងទីផ្សារក្នុងតំបន់ និងទីផ្សារអន្តរជាតិ។

### រាជរដ្ឋាភិបាលតាមរយៈរដ្ឋបាលជលផលនឹងៈ

១ ធ្វើការជាមួយអ្នកពាក់ព័ន្ធនៅក្នុងវិស័យជលផលដើម្បីរៀបចំ និងអនុវត្តកម្មវិធីអភិវឌ្ឍន៍វិស័យជលផល ដោយគិតគូរអំពីបញ្ហាសមភាព និងយកជនក្រីក្រជាគោល ស្របតាមក្របខណ្ឌផែនការយុទ្ធសាស្ត្រនេះ។

២ ចាត់វិធានការជាបន្ទាន់ដើម្បីកាត់បន្ថយការពឹងផ្អែកលើដែនទឹកធម្មជាតិ ដែលងាយនឹងរងគ្រោះពីការគំរាមកំហែងនៃកត្តាខាងក្រៅ (រួមមានការប្រែប្រួលអាកាសធាតុ) ដោយបង្កើននូវការប្រើប្រាស់ធនធានដែលអាចគ្រប់គ្រងបាន ដូចជានេសាទតាមវាលស្រែ និងវារីវប្បកម្ម។

៣ ធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងរវាងផលិតផល សង្វាក់ផលិតកម្ម និងទីផ្សារនៅក្នុងវិស័យជលផល។

៤ ធានានូវគុណភាពផលផលិតផលជលផល ស្របតាមលក្ខខណ្ឌនៃការនាំចេញ នាំចូលជាអន្តរជាតិ ហើយមានបរិមាណគ្រប់គ្រាន់ដើម្បីជំរុញការលូតលាស់នៃការនាំចេញ។

៥ អនុវត្តការងារដោយផ្អែកលើក្រមប្រតិបត្តិថ្នាក់តំបន់ស្តីពីការនេសាទដោយមានការទទួលខុសត្រូវ ដែលបានរៀបចំឡើងដោយអង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ និងក្រុមប្រតិបត្តិរបស់សមាគមនៃប្រជាជាតិអាស៊ីអាគ្នេយ៍ និងកាំកូដ។

៦ សហការជាមួយគណៈកម្មការជាតិសម្រាប់ការអនុវត្តន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរបស់ក្រសួងមហាផ្ទៃដើម្បីអនុវត្ត និងគាំទ្រដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ។

៧ ធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ដើម្បីស្រាវជ្រាវ និងបង្កើនការយល់ដឹងអំពីវិស័យជលផលឱ្យកាន់តែល្អថែមទៀតសម្រាប់ជាប្រយោជន៍ដល់យើងទាំងអស់គ្នា។

៨ បង្កើតភាពជាដៃគូជាមួយបណ្តាអង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជន ដើម្បីផ្តល់សេវាកម្មជូនដល់ក្រុមប្រឹក្សាឃុំ និងសហគមន៍។

៩ អនុវត្តកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្សយ៉ាងទូលំទូលាយ ដើម្បីកសាងជំនាញចាំបាច់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលធ្វើឱ្យប្រសើរឡើងទាំងសេវាកម្ម និងកាត់បន្ថយការពឹងផ្អែកលើជំនួយការបច្ចេកទេសអន្តរជាតិ។

១០ ធ្វើឱ្យមានសង្គតិភាពផែនការ និងសកម្មភាពជាមួយដៃគូអភិវឌ្ឍន៍ តាមរយៈក្រុមការងារបច្ចេកទេសចម្រុះស្តីពីកំណែទម្រង់នេសាទ[៤៥] ។

## យើងរំពឹងថាដៃគូអភិវឌ្ឍន៍នឹង :

១១ គាំទ្រអភិក្រមផ្អែកតាមកម្មវិធីរបស់រាជរដ្ឋាភិបាល និងធ្វើការជាមួយរដ្ឋបាលជលផលក្នុងការរួមចំណែកដល់ការអនុវត្ត។

១២ ធ្វើការដោយយោងទៅតាមសេចក្តីប្រកាសទីក្រុងបារីសស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រត្តិការ និងផែនការ**អាក្រា** នៅពេលរៀបចំ និងអនុវត្តកម្មវិធីរបស់ខ្លួន។

១៣ គាំទ្រ និងធ្វើការជាមួយក្រុមការងារបច្ចេកទេសចម្រុះស្តីពីកំណែទម្រង់នេសាទ។

## បញ្ហាអន្តរវិស័យ :

វិស័យជលផលកម្ពុជាមិនអាចស្ថិតនៅដាច់ដោយឡែកពីវិស័យដទៃទៀតបានឡើយ ពីព្រោះវិស័យជលផលក៏មានឥទ្ធិពលទៅវិញទៅមកជាមួយនឹងវិស័យផ្សេងទៀតដែរ។ ដូចគ្នានេះដែរ ចំពោះប្រជាជនដែលពឹងផ្អែកលើវិស័យជលផលក៏ត្រូវពឹងផ្អែកមួយផ្នែកធំលើវិស័យផ្សេងៗទៀតក្នុងការចិញ្ចឹមជីវិត។ ដូចនេះ ការអភិវឌ្ឍ ការគ្រប់គ្រង និងការអភិរក្សវិស័យជលផលមិនអាចផ្តាច់ចេញពីឥទ្ធិពលនៃវិស័យផ្សេងៗបានឡើយ។

នៅក្នុងប្រទេសកម្ពុជាផលប៉ះពាល់ពីការអភិវឌ្ឍនៃផ្នែកឧស្សាហកម្ម ការបំផ្លិចបំផ្លាញធនធានវារិជាត ការបំលែងតំបន់ដីសើមឱ្យទៅជាតំបន់កសិកម្ម ការធ្វើអាជីវកម្មរ៉ែ ការប្រើជីគីមីក្នុងវិស័យកសិកម្ម ការកាប់បំផ្លាញព្រៃឈើ និងកំណើនប្រជាជន គឺជាកត្តាដែលកំពុងកើតមានឡើងដែលធ្វើឱ្យមានផលវិបាកដល់ប្រព័ន្ធផលិតកម្ម និងលំហូរសេវាកម្មពីប្រព័ន្ធអេកូឡូស៊ី។

ទន្ទឹមនឹងបញ្ហាប្រឈមដែលវិស័យជលផលកំពុងជួបប្រទះ ការលូតលាស់របស់វិស័យជលផលទៅថ្ងៃអនាគតនឹងជួបប្រទះនូវបញ្ហាពាក់ព័ន្ធនឹងសិទ្ធិគ្រប់គ្រងដីធ្លី ភាពទន់ខ្សោយនៃហេដ្ឋារចនាសម្ព័ន្ធទូទៅ សមត្ថភាពវិនិយោគមានកម្រិត ភាពទន់ខ្សោយនៃចំណេះដឹងដើម្បីចាប់យកនូវឱកាសសម្រាប់ការគាំទ្រ គោលនយោបាយ និងលិខិតបទដ្ឋានច្បាប់។

៤៥. នេះគឺជាក្រុមការងារមួយដែលមានសមាសភាពរដ្ឋាភិបាលជាដៃគូជាមួយនឹងតំណាងម្ចាស់ជំនួយ ដែលបំពេញការងារជាយន្តការសម្របសម្រួលការធ្វើឱ្យមានសុខដុមនីយកម្មរាល់ផែនការសកម្មភាព និងផែនការអភិវឌ្ឍនៅក្នុងវិស័យជលផល

ម្យ៉ាងទៀត ការអភិវឌ្ឍជម្រើសមុខរបរចិញ្ចឹមជីវិតក្រៅពីវិស័យជលផលផ្តល់នូវផលប្រយោជន៍ពីរយ៉ាងគឺ ការបង្វែរមុខរបរប្រជាជនចេញពីការធ្វើនេសាទ ដើម្បីលើកកម្ពស់ការគ្រប់គ្រង និងបង្កើនផលប្រយោជន៍ដល់បុគ្គលផង ហើយបង្កើតបាននូវធនធាន និងភាពសម្បូររុងរឿងសម្រាប់តំបន់ជនបទដែលស្តែងឡើងនៅតាមគ្រួសារនីមួយៗផង។

### រាជរដ្ឋាភិបាលនឹង :

១ ប្រើប្រាស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីសម្របសម្រួលគោលនយោបាយ ផែនការ និងសកម្មភាពរបស់ក្រសួង នាយកដ្ឋាន ភ្នាក់ងារ និងស្ថាប័នទាំងឡាយដែលប្រើប្រាស់ ឬមានឥទ្ធិពលលើធនធានទឹក។

២ ធ្វើការតាមរយៈគណៈកម្មការជាតិទទួលខុសត្រូវផ្នែកបម្រែបម្រួលអាកាសធាតុដើម្បីរៀបចំ និងអនុវត្តផែនការជាតិសម្រាប់ការបន្សាំទៅនឹងបម្រែបម្រួលអាកាសធាតុ។

៣ បង្កើតក្រុមការងារអន្តរនាយកដ្ឋានតាមការចាំបាច់ ដើម្បីដោះស្រាយការគំរាមកំហែងដែលអាចកើតមានឡើងមកលើធនធានទឹក ដូចជាការសាងសង់ទំនប់វារីអគ្គិសនី និងការបំពុលបរិស្ថានជាដើម។

៤ ចាត់វិធានការជាអន្តរក្រសួង និងនាយកដ្ឋានទៅតាមការទទួលខុសត្រូវរៀងខ្លួន ដើម្បីជំរុញកំណើននៃការនាំចេញផលនេសាទតាមរយៈយុទ្ធសាស្រ្តពាណិជ្ជកម្មបើកទូលាយរបស់រាជរដ្ឋាភិបាល។

៥ ធ្វើការជាមួយដៃគូអភិវឌ្ឍន៍ដើម្បីកំណត់ និងធ្វើអន្តរាគមន៍ក្នុងការផ្តល់នូវជម្រើសនានា ការលើកកម្ពស់ និងការធានាបាននូវមុខរបរចិញ្ចឹមជីវិតសម្រាប់ជនក្រីក្រ ជនគ្មានទីពឹង និងជនងាយរងគ្រោះ។

### យើងរំពឹងថាដៃគូអភិវឌ្ឍន៍របស់យើងនឹង :

១ ពិចារណាអំពីផលប៉ះពាល់មកលើវិស័យជលផល នៅពេលដែលរៀបចំផែនការរបស់ខ្លួនសម្រាប់វិស័យផ្សេងទៀត។

២ ធ្វើការជាមួយ និងតាមរយៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក្នុងការធ្វើសុខដុមនីយកម្មគោលដៅអភិវឌ្ឍន៍ និងធ្វើអន្តរាគមន៍ចំពោះសកម្មភាពនានាដែលមានឥទ្ធិពលមកលើវិស័យជលផល។

### បញ្ហាឆ្លងដែន :

ផ្នែកនេះក៏ត្រូវប្រឈមនឹងបញ្ហាជាច្រើន ដែលជាបញ្ហាកើតឡើងជាសកល ដូចជាបម្រែបម្រួលអាកាសធាតុ ការឡើងថ្លៃប្រេងឥន្ធនៈ ការខ្វះខាតស្បៀងអាហារ ។ល។ ទន្ទឹមនេះ ក៏មានបញ្ហាប្រឈមផ្សេងៗទៀតដែលមាន ទំនាក់ទំនងនៅក្នុងតំបន់ដូចជា បទល្មើសនេសាទដែលបង្កឡើងដោយទូកនេសាទបរទេស និងការអភិវឌ្ឍវារីអគ្គិសនីនៅដងទន្លេមេគង្គប៉ែកខាងលើ។

ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ គឺត្រូវសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង នាយកដ្ឋាន ស្ថាប័ន ភ្នាក់ងារនានា និងជាមួយប្រទេសជិតខាង ដើម្បីដោះស្រាយបញ្ហាអន្តរវិស័យផង និងបញ្ហាឆ្លងដែនផង។ ទន្ទឹមនេះ យើងត្រូវបង្កើតឱ្យមានបរិយាកាសគោលនយោបាយល្អ លិខិតបទដ្ឋានច្បាប់សមស្រប ដើម្បីដោះស្រាយនូវបញ្ហាទាំងនេះ។

ការយកចិត្តទុកដាក់ដ៏ជាក់លាក់នឹងត្រូវធ្វើឡើងដើម្បីកំណត់នូវផ្នែកនានា និងជនដែលងាយរងគ្រោះជាងគេពីផលប៉ះពាល់ដោយសារបម្រែបម្រួលអាកាសធាតុ និងកំណត់អាទិភាពនៃការធ្វើអន្តរាគមន៍ទៅតាមគោលដៅជាក់លាក់ទាំងនោះ ដើម្បីកាត់បន្ថយភាពងាយរងគ្រោះនេះ។

**រាជរដ្ឋាភិបាលនឹង** :

១ ចាត់វិធានការជាបន្ទាន់ ដើម្បីស្វែងយល់ពីបញ្ហាកម្រិតថ្នាក់ជាតិ ទន្ទឹមនឹងការចូលរួមជាមួយប្រទេសផ្សេងៗ តាមរយៈយន្តការអាស៊ាន អង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានាជាច្រើន។

២ ធ្វើការជាមួយគណៈកម្មការទន្លេមេគង្គដើម្បីរៀបចំ និងអនុវត្តផែនការអាងទន្លេមេគង្គ។

៣ ធ្វើការជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីបំពេញកាតព្វកិច្ចក្នុងក្របខណ្ឌអនុសញ្ញាអន្តរជាតិ ស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះ អនុសញ្ញាស្តីពីការគ្រប់គ្រងជីវចម្រុះ និងកិច្ចព្រមព្រៀងនៃប្រទេសជាសមាជិករបស់គណៈកម្មការទន្លេមេគង្គ ស្តីពីការប្រើប្រាស់ទឹកក្នុងអាងទន្លេមេគង្គ។

**យើងរំពឹងថាដៃគូអភិវឌ្ឍន៍នឹង** :

១ ពិចារណាអំពីផលប៉ះពាល់ចំពោះប្រទេសដែលស្ថិតនៅផ្នែកខាងក្រោមនៃដងទន្លេមេគង្គ ដោយសារសកម្មភាពអភិវឌ្ឍន៍របស់បណ្តាប្រទេសខាងលើទន្លេមេគង្គ។

២ គោរពកាតព្វកិច្ចរបស់ខ្លួនក្នុងក្របខណ្ឌនៃពិធីការក្យូតូ នៃសន្និសញ្ញាអង្គការសហប្រជាជាតិ ស្តីពីបម្រែបម្រួលអាកាសធាតុ។

# ឧបសម្ព័ន្ធ ៦

# ថវិកាប៉ាន់ប្រមាណ សេចក្តីសង្ខេបអំពីកញ្ចប់ថវិកាតាមគោលដៅ

| | កញ្ចប់ថវិកាតាមគោលដៅ | ថវិកាដែលបានគណនាសម្រាប់ ២០១០-២០១២ | ថវិកាប៉ាន់ស្មានសម្រាប់ ២០១៣-២០១៥ | ថវិកាប៉ាន់ស្មានសម្រាប់ ២០១៦-២០១៩ | ថវិកាប៉ាន់ស្មានសម្រាប់ ២០១០-២០១៩ | គិតជាភាគរយ |
|---|---|---|---|---|---|---|
| ១ | ការរួមចំណែករបស់វិស័យជលផលដល់ការរីកចម្រើនជាតិមានកម្រិតខ្ពស់និងមានចីរភាព | ៦.៦៨៦.៧៩៥ | ៥.៨០២.៥៤៣ | ៧.៦៦៦.៧៨២ | ២០.១៥៦.១២០ | ២៦% |
| ២ | ជីវភាពរស់នៅរបស់ប្រជាជនក្នុងវិស័យនេះកំពុងត្រូវបានធ្វើឱ្យប្រសើរឡើង និងមានកម្រិតខ្ពស់ជាងកម្រិតមធ្យមដែលបានកំណត់នៅថ្នាក់ជាតិ | ៣.៥៤១.៥៦៤ | ៣.៣៨៧.៧៦៣ | ៤.១២១.២៦៨ | ១១.០៥០.៥៩៥ | ១៤% |
| ៣ | ដែននេសាទ និងប្រភពធនធានជលផលផ្សេងទៀតមានលក្ខខណ្ឌល្អ និងមានភាពរឹងមាំ ហើយអាចត្រូវបានគ្រប់គ្រងប្រកបដោយចីរភាព | ៤.៨៤២.៨៦២ | ៤.៤៥៦.៩០៥ | ៥.០៣៤.៥២៥ | ១៤.៣៣៤.២៩ | ១៨% |
| ៤ | ត្រីគឺជាប្រភពនៃចំណីអាហារដ៏សម្បូរបែបមានសុខភាព និងថ្លៃថ្នូរ | ៤.០៨០.៥៥៨ | ៣.៧៩០.៩២៩ | ៦.៣១០.៥២០ | ១៤.១៨២.០០៧ | ១៨% |
| ៥ | មុខជំនួញក្នុងវបរនេសាទ គឺមានភាពចំណេញស្ថិរភាព និងមានភាពទទួលខុសត្រូវ | ១.៥៥៥.៥៣៩ | ១.៤៣៣.៦៤៣ | ១.៧៤៧.៥៦០ | ៤.៧៣៦.៧៤២ | ៦% |
| ៦ | ដែននេសាទត្រូវបានគ្រប់គ្រង អភិវឌ្ឍ និងអភិរក្សដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយប្រទេសជិតខាង | ១.៦៧៥.១៩១ | ១.៥៥២.៨៩០ | ១.៨៧០.៥២០ | ៥.០៩៨.៦០១ | ៦% |
| ៧ | បរិយាកាសគោលនយោបាយច្បាប់ និងការជួយគាំទ្រចំពោះវិស័យគឺមានភាពគ្រប់គ្រាន់ សមស្រប និងមានសមត្ថភាពអាចអនុវត្តបាន | ២.៨០៨.៧៤៣ | ២.៧៥៨.១១០ | ៣.៤២៨.៤៣៦ | ៨.៩៩៥.២៨៩ | ១១ % |
| | តម្លៃសរុប | ២៥.១៩១.២៥២ | ២៣.១៨២.៧៨៣ | ៣០.១៧៩.៦១១ | ៧៨.៥៥៣.៦៤៦ | ១០០% |

## ជំនាញការថ្នាក់អន្តរជាតិ

| ល.រ | បរិយាយ/ប្រភេទ | ចំនួនមនុស្ស | ចំនួនខែ |
|---|---|---|---|
| ១ | ជំនាញការផ្នែកគ្រប់គ្រងធនធានធម្មជាតិ/ប្រធានក្រុម | ១ | ១០០ |
| ២ | អ្នកធ្វើរបាយការណ៍អំពីលទ្ធភាពនៃផលនេសាទ | ១ | ៤៨ |
| ៣ | ជំនាញការផ្នែកសហគមន៍នេសាទ | ១ | ៤៨ |
| ៤ | ជំនាញការផ្នែកវារីវប្បកម្ម | ១ | ៤៨ |
| ៥ | ជំនាញការផ្នែកសេដ្ឋកិច្ចសង្គម | ១ | ៤៩ |
| ៦ | ជំនាញការផ្នែកកែច្នៃផលជលផល | ១ | ៤៨ |
| ៧ | ជំនាញការផ្នែកត្រួតពិនិត្យ និងវាយតម្លៃ | ១ | ៤៨ |
| ៨ | ជំនាញការផ្នែកនីតិវិធីគោលនយោបាយ និងផែនការ | ១ | ៩០ |
| | សរុប | ៨ | ៤៧៩ |

## ជំនាញការថ្នាក់ជាតិ

| ល.រ | បរិយាយ/ប្រភេទ | ចំនួនមនុស្ស | ចំនួនខែ |
|---|---|---|---|
| ១ | ជំនាញការផ្នែកផលិតផលនេសាទ | ៣ | ៣៦០ |
| ២ | ជំនាញការផ្នែកសហគមន៍នេសាទ | ៣ | ៣៦០ |
| ៣ | ជំនាញការផ្នែកវារីវប្បកម្ម | ៣ | ៣៦០ |
| ៤ | ជំនាញការផ្នែកកែច្នៃផលជលផល | ៣ | ៣៦០ |
| ៥ | អ្នកសិក្សាអំពីលទ្ធភាពនៃផលនេសាទ | ១ | ១២០ |
| ៦ | ជំនាញការផ្នែកអភិវឌ្ឍន៍សង្គម | ៣ | ៣៦០ |
| ៧ | ជំនាញការផ្នែកការរៀបចំផែនទី | ៣ | ៣៦០ |
| ៨ | ជំនាញការផ្នែកត្រួតពិនិត្យ និងវាយតម្លៃ | ១ | ១២០ |
| ៩ | ជំនាញការផ្នែកបច្ចេកវិទ្យាកែច្នៃ | ៣ | ៣៦០ |
| ១០ | ជំនាញការផ្នែកនីតិវិធីគោលនយោបាយ និងផែនការ | ១ | ១២០ |
| | សរុប | ២៤ | ២.៨៨០ |

## មន្ត្រីគោលថ្នាក់មូលដ្ឋាន

| ល.រ | បរិយាយ/ប្រភេទ | ចំនួនមនុស្ស | ចំនួនខែ |
|---|---|---|---|
| ១ | ជំនាញការផ្នែកផលិតផលនេសាទ | ១២ | ១.៤៤០ |
| ២ | ជំនាញការផ្នែកសហគមន៍នេសាទ | ១២ | ១.៤៤០ |
| ៣ | ជំនាញការផ្នែកវារីវប្បកម្ម | ១២ | ១.៤៤០ |
| ៤ | ជំនាញការផ្នែកកែច្នៃផលជលផល | ១២ | ១.៤៤០ |
| ៥ | ជំនាញការផ្នែករៀបចំផែនទី | ១២ | ១.៤៤០ |
| ៦ | ជំនាញការផ្នែកត្រួតពិនិត្យ និងវាយតម្លៃ | ១២ | ១.៤៤០ |
| ៧ | ជំនាញការផ្នែកបច្ចេកវិទ្យាកែច្នៃ | ១២ | ១.៤៤០ |
| | សរុប | ៨៤ | ១០.០៨០ |

**រដ្ឋបាលជលផល**

**រដ្ឋបាលជលផល**
អាសយដ្ឋាន អាគារលេខ ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៥៨២
ទូរសារលេខ: (៨៥៥) ២៣ ២១៥ ៤៧០ គេហទំព័រ: www.fia.maff.gov.kh



ផ្តល់មូលនិធិ និងគាំទ្រដោយ DANIDA / DFID / NZAid